ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# សមិទ្ធផលនៃការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា
# របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នា ឆ្នាំ២០០៦

រៀបចំដោយ

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សម្រាប់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១ នាថ្ងៃទី១៩-២០ ខែមិថុនា ឆ្នាំ២០០៧

ខែឧសភា ឆ្នាំ២០០៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ  សាសនា  ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# សមិទ្ធផលនៃការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា
# របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នា ឆ្នាំ២០០៦

រៀបចំដោយ

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សម្រាប់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១ នាថ្ងៃទី១៩- ២០ ខែមិថុនា ឆ្នាំ២០០៧

ខែឧសភា ឆ្នាំ២០០៧

# មាតិការឿង

ទំព័រ

| | | |
|---|---|---|
| I- | សេចក្តីផ្តើម | ១ |
| II- | សារវតានៃសូចនាករតាមដានរួមគ្នា | ២ |
| III- | វឌ្ឍនភាពបន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់ នាថ្ងៃទី២៣ ខែមិនា ឆ្នាំ២០០៦ | ៤ |
| ឧបសម្ព័ន្ធ | | I-XII |

## I- សេចក្ដីផ្ដើម

១- របាយការណ៍នេះនឹងរៀបរាប់ពីវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នា (Join Monitoring Indicators) ចាប់ពីកិច្ចប្រជុំពិគ្រោះយោបល់សម្រាប់កម្ពុជា នាថ្ងៃទី២-៣ ខែមិនា ឆ្នាំ២០០៦ រហូតមកដល់ខែមេសា ឆ្នាំ២០០៧ ។

២- របាយការណ៍នេះត្រូវបានរៀបចំ ដោយផ្អែកតាមធាតុចូលសំខាន់ៗនៃរបាយការណ៍របស់ក្រុមការងារ បច្ចេកទេសចម្រុះ (TWGs) តាមសំណើរបស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.ន/ក.អ.ក) ក្នុងតួនាទីជាលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ។ ទន្ទឹមនឹងនេះ របាយការណ៍ស្ដីពីវឌ្ឍនភាពបានដកស្រង់ព័ត៌មានចេញពីសេចក្ដីថ្លែងការណ៍ សុន្ទរកថា អនុសាសន៍និងព័ត៌មានដទៃទៀត នៅក្នុងពេលប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដែលបានប្រព្រឹត្តទៅ ក្នុងឆ្នាំ២០០៦ និងឆ្នាំ២០០៧ ។ លើសពីនេះ របាយការណ៍នេះត្រូវបានរៀបចំឡើង ដោយផ្អែកលើធាតុចូល និងការបំភ្លឺនានារបស់ក្រុមការងារបច្ចេកទេសចម្រុះផងដែរ។

៣- ជារួម រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពជាដុំកំភួន ក្នុងការអនុវត្តន៍សូចនាករតាមដានរួមគ្នា ។ ប៉ុន្តែរាជរដ្ឋាភិបាលក៏បានទទួលស្គាល់ផងដែរ អំពីភាពចាំបាច់ក្នុងការចាត់វិធានការណ៍បន្ទាន់ បន្ថែមទៀតនៅតាមវិស័យខ្លះ ដោយការចូលរួមប្រកបដោយស្មារតីស្ថាបនាពីដៃគូអភិវឌ្ឍន៍ ។ រាជរដ្ឋាភិបាលបានប្រឹងប្រែងរៀបចំ និងដាក់ឱ្យអនុវត្តនូវបណ្ដាយន្តការនានា សំដៅពង្រឹងភាពដៃគូឱ្យបានរឹងមាំថែមទៀត តាមរយៈការពិគ្រោះយោបល់ និងការចូលរួមយ៉ាងទូលំទូលាយ ដើម្បីឈានទៅមានការយល់ដឹងរួមគ្នា ក្នុងគោលដៅសម្រេចឱ្យបានភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ក្នុងដំណើរការកិច្ចអភិវឌ្ឍន៍ និងការពង្រឹងសមត្ថភាព ។ រាជរដ្ឋាភិបាលបានអនុវត្តសូចនាករតាមដានរួមគ្នាជាច្រើន ប្រកបដោយប្រសិទ្ធភាព ហើយសម្រេចលទ្ធផលគួរឱ្យកត់សំគាល់ ទោះបីវឌ្ឍនភាពលើសូចនាករតាមដានរួមគ្នាខ្លះទៀត មិនទាន់បានពិភាក្សានៅក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួល រវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍កន្លងមកក៏ដោយ ។

៤- ទោះបីជាមានវឌ្ឍនភាពជាវិជ្ជមានជាច្រើនក៏ដោយ ក៏នៅពេលខ្លះ ដៃគូអភិវឌ្ឍន៍មួយចំនួនពុំបានប្រកាន់ខ្ជាប់យកភាពជាដៃគូប្រកបដោយសុឆន្ទៈឡើយ ។ ធាតុពិត មានបញ្ហាមួយចំនួនអាចពិភាក្សានិងផ្លាស់ប្ដូរយោបល់គ្នា តាមរយៈការពិគ្រោះយោបល់ដ៏ជិតស្និទ្ធនៅកម្រិតថ្នាក់បច្ចេកទេស ប៉ុន្តែ បែរជាដៃគូអភិវឌ្ឍន៍ខ្លះយកបញ្ហាទាំងនេះទៅផ្សព្វផ្សាយមុន ក្នុងបំណងលើកតំកើនខ្លួនថា ជាអ្នករកឃើញបញ្ហាសម្រាប់តស៊ូមតិ ។ ហេតុផលខាងនយោបាយនៃបញ្ហានេះ បានបន្ទុចបង្អាក់ប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងភាពជាម្ចាស់នៅក្នុងដំណើរការកំណែទម្រង់និងកិច្ចអភិវឌ្ឍន៍។ រាជរដ្ឋាភិបាលជឿជាក់ថា បញ្ហាកំណែទម្រង់ដ៏ស្មុគ្រស្មាញ និងយូរអង្វែង ដែលបានបញ្ជាក់ក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ មិនត្រឹមតម្រូវឱ្យមានតែឆន្ទៈខាងនយោបាយដ៏មុតមាំពីសំណាក់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍

ប៉ុណ្ណោះទេ ប៉ុន្តែ ភាគីទាំងពីរត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ភាពជាដៃគូ ដូចដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសនិងសេចក្តីប្រកាសឆ្នាំ២០០៦ស្តីពីការបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។

## II- សាវតារនៃសូចនាករតាមដានរួមគ្នា

៥- សូចនាករតាមដានរួមគ្នាត្រូវបានបង្កើតឡើង តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីត្រួតពិនិត្យរួម គ្នាអំពីវឌ្ឍភាពលើកំណែទម្រង់តាមវិស័យសំខាន់ៗរបស់រាជរដ្ឋាភិបាល ។ វឌ្ឍនភាពក្នុងការអនុវត្តន៍សូចនាករតាមដានរួមគ្នា បានក្លាយជាមូលដ្ឋានគ្រឹះ សម្រាប់ការពិភាក្សារវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ដែលការពិភាក្សានេះបានផ្តោតលើគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ ព្រមទាំងតម្រូវការហិរញ្ញប្បទានសហប្រតិបត្តិការ ។ ចាប់ពីឆ្នាំ២០០៤មក កិច្ចប្រជុំពិគ្រោះយោបល់មានលក្ខណៈខុសពីលើកមុនៗ ដោយរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍បានពិនិត្យនិងឯកភាពរួមគ្នាលើសូចនាករទាំងនេះ មុនស្នើជូនកិច្ចប្រជុំពិគ្រោះយោបល់អនុម័ត ។ រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក៏បានពិនិត្យរួមគ្នានូវវឌ្ឍនភាពនៃសូចនាករតាមដានរួមគ្នាផងដែរ តាមកាលបរិច្ឆេទទៀងទាត់ ។ ការប្រែប្រួលនេះបានកើតឡើង បន្ទាប់ពី **សម្តេចនាយករដ្ឋមន្ត្រី** បានអនុម័តយន្តការសម្របសម្រួល ឬយន្តការសម្រាប់ពិភាក្សា រវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក្នុងខែកញ្ញា ឆ្នាំ២០០៤ ដែលរួមមានក្រុមការងារបច្ចេកទេសចម្រុះ និងគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។

៦- កិច្ចប្រជុំលើកទី១ នៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ (នាថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៤) បានពិនិត្យ និងឯកភាពលើសូចនាករតាមដានរួមគ្នា ដើម្បីស្នើជូនកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧ អនុម័ត ។ កិច្ចប្រជុំពិគ្រោះយោបល់នេះបានប្រារព្ធនាថ្ងៃទី៦-៧ ខែធ្នូ ឆ្នាំ២០០៤ ។ ចាប់ពីពេលនោះមក គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ បានប្រជុំរៀងរាល់ត្រីមាស ដើម្បីពិនិត្យវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នា ។ កិច្ចប្រជុំនេះត្រូវបានចូលរួមពីតំណាងរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ រួមមាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ឬថ្នាក់ដឹកនាំនៃក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាល ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត ឬប្រធានស្ថាប័នផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ។ កិច្ចប្រជុំនេះបានផ្តល់កាលានុវត្តភាព សម្រាប់ភាគីទាំងសងខាង ពិនិត្យរួមគ្នានូវវឌ្ឍនភាពដែលសម្រេចបាន និងលើកបញ្ហាលំបាកដែលជួបប្រទះ ដើម្បីចាត់វិធានការចាំបាច់នានា ។

៧- ដូចបានរាយការណ៍ជូនកិច្ចប្រជុំពិគ្រោះយោបល់កាលពីថ្ងៃទី២- ៣ ខែមិនា ឆ្នាំ២០០៦ រាជរដ្ឋាភិបាលសម្រេចបាននូវវឌ្ឍនភាពជាច្រើនក្នុងការអនុវត្តន៍សូចនាករតាមដានរួមគ្នា ។ របាយការណ៍វឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នាបានគូសបញ្ជាក់ថា វឌ្ឍនភាពបានកើតមានឡើងនៅពេល ដែល ÷

១- ផែនការសកម្មភាពបានផ្សាភ្ជាប់នឹងធនធានដែលមាន

២- ការកំណត់ច្បាស់លាស់ អំពីស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្តន៍សូចនាករតាមដានរួមគ្នា

៣- ពេលវេលាសម្រាប់អនុវត្តសូចនាករតាមដានរួមគ្នាមានលក្ខណៈជាក់ស្តែង ។
ផ្ទុយទៅវិញ ក្នុងករណីដែលមិនបានបំពេញចំណុចណាមួយ ឬចំណុចទាំង៣ខាងលើ យើងសង្កេតឃើញថា ការអនុវត្តន៍សូចនាករតាមដានរួមគ្នាពុំសូវមានវឌ្ឍនភាព ឬក៏ជួបប្រទះការលំបាកជាច្រើន។

៨- ផ្អែកតាមបទពិសោធន៍ទាំងនេះ រាជរដ្ឋាភិបាលបានបង្កើតជាលើកដំបូង នូវគោលការណ៍ជាមូលដ្ឋាន និងនីតិវិធីសម្រាប់រៀបចំសូចនាករទាំងនេះ ក្នុងស្មារតីពង្រឹងភាពជាដៃគូនិងគណនេយ្យភាពទ្វេទិស ។ នៅក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ កាលពីថ្ងៃ ទី១២ ខែធ្នូ ឆ្នាំ២០០៥ ក្នុងនាមរាជរដ្ឋាភិបាល ឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាប្រធានកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ បានលើកឡើងនូវគោលការណ៍មូលដ្ឋាន ដូចខាងក្រោម ÷

១- គោលដៅសម្រាប់ពិនិត្យវឌ្ឍនភាពត្រូវផ្អែកលើអាទិភាពរបស់រាជរដ្ឋាភិបាល ដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
២- ត្រូវកំណត់ស្ថាប័នទទួលខុសត្រូវឱ្យបានច្បាស់លាស់ សម្រាប់អនុវត្តសកម្មភាពនីមួយៗ
៣- ពេលវេលាដើម្បីសម្រេចបានផែនការសកម្មភាព ត្រូវមានលក្ខណៈជាក់ស្តែង ដោយត្រូវពិចារណាពីកម្រិតសមត្ថភាពរបស់ស្ថាប័នពាក់ព័ន្ធ និងភាពស្មុគ្រស្មាញនៃបញ្ហា
៤- ត្រូវកំណត់ឱ្យច្បាស់លាស់ពីតំរូវការធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងប្រភពនៃធនធានទាំងនេះ ។

៩- ទន្ទឹមនឹងនេះ សូចនាករតាមដានរួមគ្នាទាំងនេះក៏ត្រូវរៀបចំ ដោយប្រើប្រាស់យន្តការសម្របសម្រួលដែលមានស្រាប់ ។ លេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានស្នើប្រធានក្រុមការងារបច្ចេកទេសទាំងអស់ ឱ្យរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នាតាមវិស័យដែលទទួលខុសត្រូវរៀងៗខ្លួន និងរៀបចំសូចនាករថ្មី ។ ផ្អែកតាមព័ត៌មានដែលផ្តល់ដោយបណ្តាក្រុមការងារបច្ចេកទេស លេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ បានរៀបចំសេចក្តីព្រាងសូចនាករតាមដានរួមគ្នាសម្រាប់ពិភាក្សា ក្នុងកិច្ចប្រជុំនៃប្រធានក្រុមការងារបច្ចេកទេស ។ បន្ទាប់ពីបានឯកភាពគ្នាមក ប្រធានក្រុមការងារបច្ចេកទេសនិមួយៗយកសេចក្តីព្រាងនេះ ទៅពិគ្រោះជាមួយអ្នកសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ប្រចាំក្រុមការងារបច្ចេកទេសចម្រុះនិមួយៗ ។ បន្ទាប់មកទៀត សេចក្តីព្រាងនេះត្រូវបាន ពិនិត្យនិងកែសម្រួលឡើងវិញ ដោយផ្អែកតាមមតិយោបល់ និងអនុសាសន៍នានា ហើយបន្ទាប់មកត្រូវបានសម្រេច ក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៦ ។ ទោះបីជាបានឆ្លងកាត់ការពិគ្រោះយោបល់ជាច្រើនលើកក៏ដោយ ក៏សូចនាករតាមដានរួមគ្នានៅត្រូវពិភាក្សាអស់ពេលយូរបន្ថែមទៀត នៅក្នុង កិច្ចប្រជុំពិគ្រោះយោបល់ ។

## III- វឌ្ឍនភាពបន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់ នាថ្ងៃទី២-៣ មិនា ឆ្នាំ២០០៦

១០- សូចនាករតាមដានរួមគ្នាដែលបានសម្រេចដោយកិច្ចប្រជុំពិគ្រោះយោបល់ថ្ងៃទី២-៣ ខែមិនា ឆ្នាំ២០០៦ មានគោលដៅចំនួន១២ ដោយភ្ជាប់ជាមួយសកម្មភាពចាំបាច់មួយចំនួន ដើម្បីសម្រេចគោលដៅទាំង នេះ ។ ទន្ទឹមនេះ ក៏បានកំណត់ស្ថាប័នទទួលខុសត្រូវសម្រាប់អនុវត្តសូចនាករតាមដានរួមគ្នា ក្រុម ការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ ក្របខ័ណ្ឌពេលវេលានិងការកំណត់ធនធាន ។ ឧបសម្ព័ន្ធភ្ជាប់នឹងរបាយការណ៍នេះបញ្ជាក់យ៉ាងពិស្តារ នូវសូចនាករតាមដានរួមគ្នាដែលបានឯកភាពក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ដោយឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពជាក់ស្តែងតាមគោលដៅនិមួយៗ ។

**គោលដៅ** : តាមដានជារៀងរាល់ឆ្នាំការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

**សកម្មភាពចាំបាច់** :

- រៀបចំ និងអនុវត្តក្របខ័ណ្ឌសម្រាប់តាមដានការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងពិនិត្យវឌ្ឍនភាពនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិប្រចាំឆ្នាំ

១១- ដោយមានការគាំទ្រពីក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ផែនការនិងកាត់បន្ថយភាពក្រីក្រ ក្រសួងផែនការបានរៀបចំក្របខ័ណ្ឌមួយ សម្រាប់ពិនិត្យការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយបានពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ។ ក្របខ័ណ្ឌនេះដែលរាជរដ្ឋាភិបាលបាន អនុម័ត បានឆ្លុះបញ្ចាំងអំពីការប្តេជ្ញារបស់រាជរដ្ឋាភិបាល ក្នុងការពិនិត្យវឌ្ឍនភាពនៃការអនុវត្តន៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តាមរយៈការរៀបចំនូវរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំរហូតដល់ឆ្នាំ ២០១០ ដោយផ្ទៀបនឹងគោលដៅទាំងឡាយដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រនេះ និងគោលដៅ អភិវឌ្ឍន៍សហវត្សកម្ពុជាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ លទ្ធផលនៃការត្រួតពិនិត្យឡើង វិញនូវវឌ្ឍនភាពទាំងនេះ នឹងក្លាយជាមូលដ្ឋានសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ សម្រាប់រយៈពេល ៥ឆ្នាំបន្ទាប់ ។

១២- របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំលើកទី១ស្តីពីការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ហៅកាត់ ថា របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០០៦) ត្រូវបានរៀបចំឡើងក្រោមការដឹកនាំរបស់ក្រសួងផែនការ ដោយសហការយ៉ាងជិតស្និតជាមួយនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា/ក.អ.ក) និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ។ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០០៦ បានពិនិត្យឡើងវិញ និងបានធ្វើបច្ចុប្បន្នភាពលើ ÷

១- វឌ្ឍនភាពក្នុងការអនុវត្តន៍យុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗតាមវិស័យដែលបានបញ្ជាក់ក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ និងវឌ្ឍនភាពក្នុងការរៀបចំផែនការតាមវិស័យនៅថ្នាក់ ជាតិ ថ្នាក់ក្រោមជាតិ ដែលមិនទាន់មាន

២- វឌ្ឍនភាពក្នុងការសម្រេចបាននូវសូចនាករសំខាន់ៗមួយចំនួន ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

៣- កម្រិតនៃការតម្រឹមការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ជាមួយនឹងអាទិភាព នៅតាមវិស័យនានានៃ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏ដូចជាអនុសាសន៍ និងសំណើកែតម្រូវនានាទៅលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

១៣- ដូចគ្នានឹងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដែរ រាជរដ្ឋាភិបាលបានអនុវត្តប្រកបដោយប្រសិទ្ធភាព នូវភាពជាម្ចាស់ក្នុងការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០០៦នេះ ។ បន្ទាប់ពីត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលរួចហើយ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំលើកនេះនឹងក្លាយជាឯកសារដ៏សំខាន់មួយ សម្រាប់បង្ហាញក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី១៩-២០ ខែមិថុនា ឆ្នាំ២០០៧ ។

**គោលដៅ** : ពង្រឹងភាពជាដៃគូ ដើម្បីបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងគណនេយ្យភាពទ្វេទិស

**សកម្មភាពចាំបាច់** :

- អនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆមាស ក្នុងការអនុវត្តន៍ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្ម
- ត្រួតពិនិត្យឡើងវិញ និងពង្រឹងយន្តការសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ រួមមាន កិច្ចប្រជុំពិគ្រោះយោបល់ គណៈកម្មការសម្របសម្រួលជំនួយរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

១៤- រាជរដ្ឋាភិបាលសម្រេចបាននូវវឌ្ឍនភាពសំខាន់ៗជាច្រើន ក្នុងការកសាង និងពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់ ដើម្បីបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ ។ គំនិតផ្តួចផ្តើមសំខាន់ត្រូវបានអនុវត្ត ដើម្បីបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងគណនេយ្យភាពទ្វេទិស ។ គំនិតផ្តួចផ្តើមទាំងនេះ រួមមាននិធានការ និងគោលនយោបាយ ដើម្បីរៀបចំក្របខ័ណ្ឌខាងគោលនយោបាយ និងស្ថាប័ន សម្រាប់គ្រប់គ្រងសកម្មភាពសហប្រតិបត្តិការអភិវឌ្ឍន៍ ក្នុងន័យពង្រឹងភាពជាម្ចាស់ និងភាពដឹកនាំរបស់រាជរដ្ឋាភិបាល បង្កើនការតម្រឹមការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ជាមួយនឹងបណ្តាអាទិភាពអភិវឌ្ឍន៍ជាតិ ក៏ដូចជាការធ្វើសុខដុមនីយកម្មនៃការអនុវត្តន៍ទំរង់-ការសហប្រតិបត្តិការ ដើម្បីបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ក្នុងយន្តការគណ-នេយ្យភាពទ្វេទិស សម្រាប់ចូលរួមអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្រ ។

១៥- ក្នុងបរិការណ៍នៃវឌ្ឍនភាពនេះ សមិទ្ធផលមួយក្នុងចំណោមសមិទ្ធផលសំខាន់ជាច្រើន គឺការអនុមតិនូវក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលសម្រាប់គ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ កាលពីខែមករាឆ្នាំ២០០៦ ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះបានបញ្ជាក់អំពីការប្តេជ្ញាចិត្តដ៏មុឹងមាត់របស់រាជរដ្ឋាភិបាលក្នុងភាពជាម្ចាស់ និងភាពដឹកនាំយ៉ាងពេញលេញនៅក្នុងដំណើរការនៃកិច្ចអភិវឌ្ឍន៍ប្រទេសជាតិ ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះបានបញ្ជាក់ថែមទៀត អំពីតួនាទី និងការទទួលខុសត្រូវរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ក្នុងការកៀរគរ និងសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ ដោយអនុលោម

តាមច្បាប់ និងបទបញ្ញាជាធរមានរបស់រាជរដ្ឋាភិបាល ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះបានបញ្ជាក់ផងដែរ អំពីគោលដៅនិងគោលការណ៍ជាមូលដ្ឋាន និងក្របខ័ណ្ឌគោលនយោបាយ ដែលជាមគ្គុទ្ទេសក៍ សម្រាប់គ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា ។ នៅកំរិតស្ថាប័ន ក្របខ័ណ្ឌយុទ្ធសាស្ត្រ សម្រាប់គ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ក៏បានកំណត់យ៉ាងពិស្តារសារជាថ្មី អំពីតួនាទីរបស់ គ.ជ.ន/ក.អ.ក ដែលជាស្ថាប័នស្នូលរបស់រាជរដ្ឋាភិបាល សម្រាប់កៀរគរធនធានហិរញ្ញប្បទាន សហប្រតិបត្តិការ តាមរយៈការសម្របសម្រួលជាមួយនឹងដៃគូអភិវឌ្ឍន៍ (រួមមានដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគី និងអង្គការក្រៅរដ្ឋាភិបាល) ព្រមទាំងសម្របសម្រួលជាមួយនឹងក្រសួងនិងស្ថាប័នរបស់ រាជរដ្ឋាភិបាល ក្នុងការតម្រង់ ការបែងចែកនិងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការទាំងនេះ ។

១៦- ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ត្រូវបាននិងកំពុងអនុវត្ត ក្រោម ការដឹកនាំរបស់ គ.ជ.ន/ក.អ.ក ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍មួយចំនួន ដោយផ្តោតការ យកចិត្តទុកដាក់ទៅលើការពង្រឹងសមត្ថភាពរបស់ គ.ជ.ន/ក.អ.ក ដែលជាស្ថាប័នស្នូលរបស់រាជ រដ្ឋាភិបាល សម្រាប់សម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីឱ្យស្ថាប័ននេះអាចបំពេញ តួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ។ ទន្ទឹមនេះ ការយកចិត្តទុកដាក់ក៏ត្រូវបានផ្តោតលើការ ពង្រឹងសមត្ថភាពរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធនានាផងដែរ ដើម្បីឱ្យក្រសួងនិងស្ថាប័នទាំងនេះ អាចគ្រប់គ្រងសកម្មភាពសហប្រតិបត្តិការអភិវឌ្ឍន៍តាមវិស័យ ឬតាមផ្នែកដែលស្ថិតក្រោមការទទួល ខុសត្រូវរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព ។ ការគាំទ្រដល់រាជរដ្ឋាភិបាលក្នុងការអនុវត្តន៍ក្របខ័ណ្ឌ យុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នេះ អាចទទួលបានជោគជ័យ លុះត្រាតែ ភាគីទាំងអស់ព្រមព្រៀងគ្នា និងអនុវត្តតាមគោលនយោបាយនិងគោលការណ៍ទាំងឡាយ ដែលមាន ចែងក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ។ ប្រការដែលមិនប្រកាន់ភ្ជាប់នូវបទបញ្ញត្តិ និងលិខិតបទដ្ឋាននានា ដែលមានស្រាប់ មិនត្រឹមតែជាការរំខានដល់ការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួល ជំនួយឱ្យមានប្រសិទ្ធភាពប៉ុណ្ណោះទេ ប៉ុន្តែ ធ្វើឱ្យសមត្ថភាពនៃស្ថាប័នរាជរដ្ឋាភិបាលមានភាពអន់ ខ្សោយទៀតផង ។ នេះជាប្រការដែលធ្វើឱ្យការសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ ស្ថិត ក្នុងហានិភ័យ ។ ដើម្បីបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ រាជរដ្ឋាភិបាលបានជំរុញ និង លើកទឹកចិត្តដៃគូអភិវឌ្ឍន៍ ឱ្យសហការជាមួយនឹងស្ថាប័នស្នូលរបស់រាជរដ្ឋាភិបាល សម្រាប់កៀរគរ និងសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ ។

១៧- ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹមនិងលទ្ធផល ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល នាថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៦ បន្ទាប់ពីបានពិភាក្សាយ៉ាងទូលំទូលាយជាមួយនឹងក្រសួងពាក់ព័ន្ធ និង ដៃគូអភិវឌ្ឍន៍ ។ ផែនការសកម្មភាពនេះត្រូវបានរៀបចំឡើង ដោយផ្អែកលើគោលការណ៍នៃភាពជា ដៃគូទាំង៥ និងការប្តេជ្ញាចិត្តនៃសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ។ ផែនការសកម្មភាពស្តីពីសុខដុម- នីយកម្ម ការតម្រឹម និងលទ្ធផល បានកំណត់សកម្មភាពជាក់លាក់ ដែលមានទំនាក់ទំនងជាមួយនឹង អាទិភាពនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដោយបានកំណត់

ស្ថាប័នទទួលខុសត្រូវអនុវត្តយ៉ាងច្បាស់លាស់ ក្នុងបំណងពង្រឹងប្រព័ន្ធ នីតិវិធី និងសមត្ថភាពជាតិ សម្រាប់ធ្វើសុខដុមនីយកម្មនៃការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ ដោយតម្រឹមជាមួយនឹងអាទិភាពអភិវឌ្ឍន៍ជាតិ និងដើម្បីធានាឱ្យបាននូវគណនេយ្យភាពទ្វេទិសនៃលទ្ធផលអភិវឌ្ឍន៍ ។ ការអនុវត្តន៍ផែនការសកម្មភាពនេះ ក៏ជាការចូលរួមគាំទ្រដល់ការអនុវត្តន៍ ដើម្បីសម្រេចឱ្យបាននូវគោលដៅទាំងឡាយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ឆន្ទៈក្នុងការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផលនេះ ត្រូវបានបញ្ជាក់ឡើង តាមរយៈការចុះហត្ថលេខាលើសេចក្តីប្រកាសស្តីពីការបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ រវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ចំនួន១៤ នាថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៦ ។ ក្នុងសេចក្តីប្រកាសនោះ រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍បានប្តេជ្ញាធ្វើការត្រួតពិនិត្យលើការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹមនិងលទ្ធផល ។

១៨- ក្រុមការងារបច្ចេកទេសចម្រុះបានរាយការណ៍ អំពីវឌ្ឍនភាពនៃការអនុវត្តន៍ផែនការសកម្មភាពសូចនាករតាមជានរួមគ្នា ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល និងតម្រូវការធនធាន តាមការស្នើសុំរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ ដោយផ្អែកតាមព័ត៌មានទាំងនេះ គ.ជ.ទា/ក.អ.ក បានរៀបចំរបាយណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹមនិងលទ្ធផលដែលជាផ្នែកមួយនៃរបាយការណ៍ «ការពិនិត្យឡើងវិញអំពីវឌ្ឍនភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់» ដើម្បីចែករំលែកក្នុងអង្គប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ ជាក់ស្តែងរបាយការណ៍នេះបានជំរាបជូនក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ កាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៦ និងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៧ ។

១៩- នៅមុនឆ្នាំ២០០៤ ក្រៅពីយន្តការនៃកិច្ចប្រជុំពិគ្រោះយោបល់ យើងមិនទាន់មានយន្តការច្បាស់លាស់ណាមួយ សម្រាប់ឱ្យរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ពិភាក្សាជាប្រចាំឡើយ លើកលែងតែក្រុមការងារបច្ចេកទេសចម្រុះមួយចំនួន ។ នាពេលនោះ កិច្ចប្រជុំទាំងអស់ត្រូវបានផ្តួចផ្តើម និងដឹកនាំស្ទើរតែទាំងស្រុងដោយដៃគូអភិវឌ្ឍន៍ ដោយមានការចូលរួមមានកំរិតពីក្រសួង/ស្ថាប័នរបស់រាជរដ្ឋាភិបាល ។ យន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ បានលេចជារូបរាងឡើង នាខែកញ្ញា ឆ្នាំ២០០៤ នៅពេលដែល **សម្តេច នាយករដ្ឋមន្ត្រី** បានសម្រេចឱ្យបង្កើតក្រុមការងារបច្ចេកទេសចម្រុះដែលក្រុមការងារនីមួយៗត្រូវដឹកនាំដោយរាជរដ្ឋាភិបាល និងចូលរួមដោយដៃគូអភិវឌ្ឍន៍ និងក្រសួងនិងស្ថាបន័ពាក់ព័ន្ធ ។ រហូតមកដល់បច្ចុប្បន្ននេះ យើងមានក្រុមការងារបច្ចេកទេសចំនួន ១៨ តាមវិស័យនានា ។ ក្រុមការងារបច្ចេកទេសចម្រុះទាំងនេះ បានចាប់ដំណើរការបានរយៈពេលជាង២ឆ្នាំមកហើយ ។ កិច្ចការរបស់ក្រុមការងារបច្ចេកទេសចម្រុះត្រូវបានសម្របសម្រួល ដោយគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដែលរួមមាន រដ្ឋមន្ត្រី និងប្រធានស្ថាប័នតំណាងឱ្យភាគីរាជរដ្ឋាភិបាល ព្រមទាំងឯកអគ្គរដ្ឋទូត និងប្រធានទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ ដែល

តំណាងឱ្យដៃគូអភិវឌ្ឍន៍ប្រចាំនៅកម្ពុជា ។ យន្តការនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ និងក្រុមការងារបច្ចេកទេសចម្រុះ បានបង្ហាញនូវការផ្លាស់ប្តូរជាសារវ័ន្តនៃការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា ដែលក្នុងនោះ ភាពជាម្ចាស់និងភាពដឹកនាំនៃដំណើរការ និងសកម្មភាពអភិវឌ្ឍន៍ ត្រូវបានពង្រឹងនៅតាមវិស័យ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលអាចដឹកនាំការរៀបចំផែនការ ការគ្រប់គ្រង និងការពិនិត្យលើសកម្មភាពអភិវឌ្ឍន៍តាមវិស័យ រួមគ្នាជាមួយនឹងដៃគូអភិវឌ្ឍន៍ ។

២០- ចាប់តាំងពីកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ លើកទី១ នាខែធ្នូ ឆ្នាំ២០០៤មក យន្តការគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ និងក្រុមការងារបច្ចេកទេសបានដំណើរការលើមូលដ្ឋាន «រៀនផងធ្វើផង» ។ គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ តាមរយៈលេខាធិការដ្ឋានរបស់ខ្លួន គឺ គ.ជ.ន/ក.អ.ក បានបង្កើតវេទិកាជាទៀងទាត់ សម្រាប់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ វាយតម្លៃរួមគ្នាលើវឌ្ឍនភាពនៃការអនុវត្តន៍ការប្តេជ្ញាចិត្តដែលបានព្រមព្រៀង និងដោះស្រាយបញ្ហានានា ដើម្បីឈានទៅរកការយល់ដឹងរួមគ្នាលើគោលនយោបាយ និងកំណែទំរង់តាមវិស័យសំខាន់ៗ ។ លើសពីនេះ កិច្ចប្រជុំពិគ្រោះយោបល់ដែលបានប្រព្រឹត្តទៅ នាថ្ងៃទី២-៣ ខែមិនា ឆ្នាំ២០០៦ កន្លងមកនេះ គឺជាលើកទី១នៅក្នុងប្រវត្តិសាស្ត្រ ដែលការរៀបចំសូចនាករតាមដានរួមគ្នា ត្រូវបានដឹកនាំដោយរាជរដ្ឋាភិបាលតាមរយៈក្រុមការងារបច្ចេកទេសចម្រុះ និងគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ ក្នុងឆ្នាំ២០០៦ គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ បានជួបប្រជុំយ៉ាងទៀងទាត់ ដើម្បីពិនិត្យវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នា ដែលបានឯកភាពគ្នាកន្លងមក ។

២១- ការធ្វើសនិទានកម្មសម្រាប់ពង្រឹងកិច្ចដំណើរការនៃយន្តការ ក៏ដូចជាការបង្កើនប្រសិទ្ធភាពនៃយន្តការ គឺជាការចាំបាច់ដែលត្រូវអនុវត្តឱ្យបានម៉ត់ចត់ ។ យើងត្រូវពិនិត្យមើលអំពីតួនាទី និងមុខងាររបស់ក្រុមការងារបច្ចេកទេសចម្រុះ គោលការណ៍ស្តីពីការប្រព្រឹត្តទៅរបស់ក្រុមការងារ និងទំនាក់ទំនងរបស់ក្រុមការងារជាមួយនឹងក្រសួងនិងស្ថាប័នពាក់ព័ន្ធ ។ យើងក៏ត្រូវពិនិត្យមើលឡើងវិញផងដែរ នូវវេទិកាសម្រាប់ពិភាក្សា ដូចជាកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ កិច្ចប្រជុំពិគ្រោះយោបល់ ដែលត្រូវបានប្តូរមកជា «វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា» វិញ ។ ក្នុងសុន្ទរកថាបើកកិច្ចប្រជុំពិគ្រោះយោបល់លើកទី៨ នាថ្ងៃទី២-៣ ខែមិនា ឆ្នាំ២០០៦ **សម្តេច នាយករដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍ឱ្យពិនិត្យយន្តការទាំងនេះឡើងវិញ ។

២២- ការពិនិត្យយន្តការឡើងវិញ ដោយមានការចូលរួមពីដៃគូអភិវឌ្ឍន៍ ត្រូវចំណាយរយៈពេលអស់ជិត មួយឆ្នាំ ។ ជាលទ្ធផល រាជរដ្ឋាភិបាលបានសម្រេច ÷

១- កិច្ចប្រជុំពិគ្រោះយោបល់ ត្រូវបានប្តូរជា «វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា» ដែល

ស្ថិតក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ។ នេះជាវេទិកាសម្រាប់ពិភាក្សាគោលនយោបាយសាធារណៈ ការងារកំណែទម្រង់ និងក្របខ័ណ្ឌហិរញ្ញប្បទានដែលពាក់ព័ន្ធ ។ វេទិកានេះក៏ជាមូលដ្ឋានសម្រាប់ពិគ្រោះយោបល់ដ៏ទូលំទូលាយមួយ រវាងរដ្ឋាភិបាលនិងភាគីពាក់ព័ន្ធផ្សេងៗទៀត ដោយរាប់បញ្ចូលទាំងវិស័យឯកជន ក្នុងបរិការណ៍នៃការអភិវឌ្ឍន៍ជាតិនាពេលអនាគត ។

២- ផ្អែកតាមលទ្ធផលនៃការពិនិត្យឡើងវិញ នូវយន្តការនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ និងក្រុមការងារបច្ចេកទេសចម្រុះ រាជរដ្ឋាភិបាលបានរៀបចំ និងបានអនុម័ត «ឯកសារណែនាំសម្រាប់ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមការងារបច្ចេកទេសចម្រុះ»នាខែកុម្ភៈ ឆ្នាំ២០០៧ ដើម្បីធ្វើសនិទានកម្មនិងពង្រឹងក្រុមការងារទាំងនេះ ។ ឯកសារណែនាំនេះបានបញ្ជាក់យ៉ាងច្បាស់លាស់ អំពីមុខងារ និងតួនាទីនៃក្រុមការងារ ដែលពាក់ព័ន្ធនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ អាទិភាពនៃការបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិត្តិការ ការគ្រប់គ្រងនិងការសម្របសម្រួលកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងការពង្រឹងសមត្ថភាព បញ្ហាខាងរចនាសម្ព័ន្ធនិងខាងប្រតិបត្តិការទំនាក់ទំនងរវាងក្រុមការងារបច្ចេកទេសចម្រុះ ជាមួយនឹងក្រសួងនិងស្ថាប័ន គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ កម្ពុជា ។

២៣- ការចំណាយថាមពល និងពេលវេលា ព្រមទាំងជំហានការងារសម្រាប់ពិនិត្យឡើងវិញ នូវយន្តការខាងលើនេះ ក៏បញ្ជាក់អំពីទស្សនៈខុសឆ្គងរបស់មជ្ឈដ្ឋានមួយចំនួន ដែលបានលើកឡើងកន្លងមកថា មិនទាន់ដល់ពេលឱ្យរាជរដ្ឋាភិបាលពិនិត្យយន្តការនេះឡើងវិញឡើយ ។ **សម្តេច នាយករដ្ឋមន្ត្រី** បានថ្លែងសុន្ទរកថាក្នុងឱកាសបើកកិច្ចប្រជុំពិគ្រោះយោបល់លើកទី៨ (ថ្ងៃទី២-៣ ខែមិនា ឆ្នាំ២០០៦) ដោយមានប្រសាសន៍ថាៈ «បច្ចុប្បន្ន យើងបានសម្លឹងឃើញយ៉ាងច្បាស់លាស់នូវជើងមេឃនៃក្តីសង្ឃឹមរបស់យើង» ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺជាយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រទេសតែមួយគត់ដែលផ្សាភ្ជាប់នឹងក្របខ័ណ្ឌត្រួតពិនិត្យ ។ លើសពីនេះ ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍បានគូសបញ្ជាក់ អំពីអាទិភាពក្នុងការបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីឈានទៅសម្រេចឱ្យបាននូវទិសដៅ និងគោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍សហវត្សកម្ពុជា ។ រីឯផែនការសកម្មភាពស្តីពីសុខដុមនីយកម្មការតម្រឹម និងលទ្ធផល ក៏ជាយន្តការសម្រាប់ពិភាក្សាអំពីយុទ្ធសាស្ត្រនិងសកម្មភាពអភិវឌ្ឍន៍ជាតិផង និងសម្រាប់អនុវត្តអាទិភាពនានាដើម្បីបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានប្តេជ្ញាយ៉ាងមុតមាំក្នុងការអនុវត្តន៍សេចក្តីប្រកាសស្តីពីការបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលមានសុទិដ្ឋិនិយមចំពោះការពង្រឹងភាពជាដៃគូ ជាមួយនឹងដៃគូអភិវឌ្ឍន៍ទាំងអស់ ។ ដោយផ្អែកលើទស្សនទានស្តីពីគណនេយ្យទ្វេទិសភាពជាដៃគូនេះនឹងរួមចំណែកបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ក៏ដូចជាកាត់បន្ថយ

ភាពក្រីក្ររបស់ប្រជាជនកម្ពុជាផងដែរ ។

**គោលដៅ** : ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

**សកម្មភាពចាំបាច់** :

- រៀបចំបញ្ចប់ និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ស្របតាមបទដ្ឋានអន្តរជាតិ ព្រមទាំង :
  - ក- រៀបចំផែនការដើម្បីអនុវត្តច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ
  - ខ- ផ្សព្វផ្សាយជាទៀងទាត់ ៦ខែម្តង នូវព័ត៌មានស្តីពីករណីអំពើពុករលួយ និងការផ្តន្ទាទោស

២៤- ការពន្យារពេលអនុម័តក្រមព្រហ្មទណ្ឌ បានជះឥទ្ធិពលដល់ការអនុវត្តន៍ឱ្យសម្រេចសូចនាករនេះ ព្រោះការធានាឱ្យមានសង្គតិភាពក្នុងក្រមព្រហ្មទណ្ឌ គឺជាមូលដ្ឋាននៃការរៀបចំបញ្ចប់សេចក្តីព្រាងច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ ក្នុងស្មារតីនេះ សេចក្តីព្រាងច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ពុំទាន់ត្រូវបានអនុម័តពីគណៈរដ្ឋមន្ត្រី ហើយនេះគឺជាប្រការមួយដែលនាំឱ្យមានការយឺតយ៉ាវក្នុងការរៀបចំផែនការសម្រាប់គ្រប់គ្រងការអនុវត្តន៍ច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនេះ។ ទោះជាយ៉ាងនេះក្តី ក៏ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានដឹកនាំរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រ សម្រាប់អនុវត្តច្បាប់ប្រឆាំងនឹងអំពើពុករលួយតាំងពីខែមិនា ឆ្នាំ ២០០៧ ។

២៥- ទោះបីជាមានការយឺតយ៉ាវបែបនេះក្តី ក៏យើងអាចកត់សំគាល់អំពីវឌ្ឍនភាពក្នុងកិច្ចដំណើរការរៀបចំសេចក្តីព្រាងច្បាប់ និងការកែលំអសេចក្តីព្រាងច្បាប់ដូចខាងក្រោម ÷

- ក- យោងតាមរបាយការណ៍ក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ នាថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៦ សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយត្រូវបានរៀបចំរួចជាស្រេច សម្រាប់កិច្ចប្រជុំអន្តរក្រសួង មុននឹងដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យនិងអនុម័ត ។
- ខ- ក្នុងសេចក្តីព្រាងច្បាប់បច្ចុប្បន្ន បញ្ហាសំខាន់បីទាក់ទងនឹងស្ថាប័នប្រឆាំងនឹងអំពើពុករលួយ (ឯករាជ្យភាព ធម្មនុញ្ញភាព និងសង្គតិភាពនៃសេចក្តីព្រាងច្បាប់ជាមួយនឹងក្រមព្រហ្មទណ្ឌ) ត្រូវបានពិនិត្យ និងកែសម្រួល ។
- គ- ប្រសិទ្ធភាព និងឯករាជ្យភាពនៃស្ថាប័នប្រឆាំងនឹងអំពើពុករលួយ ដូចមានចែងក្នុងសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ ត្រូវបានធានា ។ តួនាទីជានគរបាល យុត្តិធម៌ និងអំណាចនៃការចោទប្រកាន់ ត្រូវបានផ្តល់ជូនអគ្គលេខាធិការដ្ឋាននៃស្ថាប័នប្រឆាំងនឹងអំពើពុករលួយ សម្រាប់ធ្វើការងារស៊ើបអង្កេត និងចោទប្រកាន់ ។
- ឃ- សេចក្តីព្រាងក្រមព្រហ្មទណ្ឌដែលកំពុងបានបញ្ចប់នេះ បានបញ្ជាក់យ៉ាងពិស្តារអំពីបទបញ្ញត្តិស្តីពីអំពើពុករលួយដែលគ្របដណ្តប់លើបទឧក្រិដ្ឋ ជាងសេចក្តីព្រាងបឋមច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ ។ ដោយមានកិច្ចសហប្រតិបត្តិការពីប្រទេសបារាំង ក្រសួង យុត្តិធម៌ និងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច បាននិងកំពុងកែ

សម្រួលសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ ដោយដកស្រង់បទបញ្ញត្តិខ្លះចេញពីសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ។

២៦- ទោះបីជាមានការយឺតយ៉ាវក្នុងការអនុម័តច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ រាជរដ្ឋាភិបាលបានចាត់វិធានការជាច្រើន សម្រាប់ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ វិធានការណ៍ទាំងនេះរួមមាន ÷

ក- រៀបចំរចនាសម្ព័ន្ធ និងពង្រឹងអង្គភាពប្រឆាំងនឹងអំពើពុករលួយឡើងវិញ (អនុក្រឹត្យលេខ៨៤ ចុះថ្ងៃ ទី២២ ខែសីហា ឆ្នាំ២០០៦)

ខ- ដាក់ទណ្ឌកម្មរដ្ឋបាលដល់មន្ត្រី៧រូប ដែលបានប្រព្រឹត្តល្មើសច្បាប់ព្រៃឈើ ក្នុងនោះមន្ត្រី៤រូបត្រូវបានផ្លាស់ចេញពីតំណែង ហើយមន្ត្រី៣រូបផ្សេងទៀតត្រូវបានព្យួរការងារ

គ- មន្ត្រី២រូបត្រូវបានចោទប្រកាន់ និងកាត់ទោសឱ្យជាប់ពន្ធនាគារពីបទរំលោភលើអចលនទ្រព្យឯកជន

ឃ- មន្ត្រី១រូបត្រូវបានចោទពីបទទទួលសំណូក សមគំនិតក្នុងការរំលោភលើដីរដ្ឋនិងព្រៃឈើ និងពីបទក្លែងបន្លំ

ង- មន្ត្រី១រូបត្រូវបានតុលាការចោទពីបទបំផ្លិចបំផ្លាញធនធានធម្មជាតិ និងបរិស្ថាន (ស្របតាមមាត្រា២២ នៃច្បាប់ស្តីពីការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ) និងពីបទឧក្រិដ្ឋព្រៃឈើ (ស្របតាមមាត្រា១០១ នៃច្បាប់ព្រៃឈើ)

ច- មន្ត្រីជាន់ខ្ពស់១រូប (ក្រសួងអភិវឌ្ឍន៍ជនបទ) ត្រូវបានចោទពីបទគេបន្លំថវិកាជាតិ (ស្របតាមមាត្រា៣៧ នៃច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល)

ឆ- មន្ត្រី១១រូបត្រូវបានតុលាការកាត់ទោសពីបទកាប់ឈើខុសច្បាប់ នៅតំបន់កន្ទុយនាគនៃខេត្តរតនគីរី (ស្របតាមមាត្រា៣៨នៃច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល) ។

ដោយទទួលស្គាល់អំពីសារៈសំខាន់ និងភាពចាំបាច់ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ រាជរដ្ឋាភិបាលនឹងព្យាយាមកែលំអ និងពង្រឹងប្រព័ន្ធរាយការណ៍អំពើពុករលួយបន្ថែមទៀត ដើម្បីរាយការណ៍អំពីករណីពុករលួយឱ្យបានទៀងទាត់ ។

**គោលដៅ** : កសាងប្រព័ន្ធយុត្តិធម៌ និងតុលាការ ឱ្យដំណើរការប្រកបដោយតម្លាភាពនិងគណនេយ្យភាព ដែលការពារសិទ្ធិបុគ្គល ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ

**សកម្មភាពចាំបាច់** :

- រៀបចំក្របខ័ណ្ឌច្បាស់លាស់ស្តីពីសិទ្ធិទទួលព័ត៌មាន
- រៀបចំបញ្ចប់សេចក្តីព្រាងច្បាប់ដែលនៅសេសសល់ដើម្បីអនុមត៌ (ក្រមស្តីពីនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់តុលាការ )

- រៀបចំកាលបរិច្ឆេទ ដើម្បីបញ្ចប់សេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋាននានា ដែលជាតម្រូវការចាំបាច់សម្រាប់បំពេញតម្រូវការនៃអង្គការពាណិជ្ជកម្មពិភពលោក និងអនុវត្តការងារតាមកាលបរិច្ឆេទដែលបានកំណត់
- រៀបចំកាលបរិច្ឆេទ សម្រាប់រៀបចំសេចក្តីព្រាងច្បាប់ ការពិនិត្យពិភាក្សា និងការអនុមតិច្បាប់ថ្មីៗ និងការធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានដែលមានស្រាប់ និងអនុវត្តការងារតាមកាលបរិច្ឆេទដែលបានកំណត់
- នៅពេលដែលកំពុងរៀបចំបញ្ជីច្បាប់អាទិភាព គួរយកចិត្តទុកដាក់លើ÷
  - ក- បញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងការជួញដូរផ្លូវភេទ ដើម្បីផ្ញើជូនគណៈរដ្ឋមន្ត្រី
  - ខ- បញ្ចប់ និងអនុមតិផែនការជាតិ សម្រាប់អនុវត្តច្បាប់ស្តីពីការប្រឆាំងនឹងអំពើហឹង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ
  - គ- បញ្ចប់លិខិតបទដ្ឋាន សម្រាប់អនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ
  - ឃ- អនុវត្តមាត្រា១៨ នៃច្បាប់ភូមិបាល
  - ង- អនុមតិយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលស្តីពីជនជាតិភាគតិច ។

២៧- កង្វះខាងហិរញ្ញប្បទានសហប្រតិបត្តិការ គឺជាប្រការមួយដែលធ្វើឱ្យការរៀបចំក្របខ័ណ្ឌនយោបាយស្តីពីសិទ្ធិទទួលព័ត៌មានមានការយឺតយ៉ាវ ។ ទោះបីជាយ៉ាងនេះក្តីក៏ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច កំពុងសិក្សាដំណើរការ សម្រាប់រៀបចំក្របខ័ណ្ឌនយោបាយនេះដែរ ។ សិក្ខាសាលាមួយត្រូវបានរៀបចំ ដើម្បីបង្ហាញពីសារៈសំខាន់របស់ព័ត៌មាននិងគោលការណ៍ជាសកលដែលត្រូវដាក់បញ្ចូលក្នុងសេចក្តីព្រាងច្បាប់ ។ នាបច្ចុប្បន្ន ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច កំពុងស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍន៍ ។

២៨- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភានិង អធិការកិច្ច បានរៀបចំផែនការសកម្មភាពអាទិភាពដែលរួមមាន សេចក្តីព្រាងច្បាប់អធិការកិច្ច និងសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ដើម្បីជួយគាំទ្ររាជរដ្ឋាភិបាល ក្នុងកិច្ចខិតខំប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដូចបានគូសបញ្ជាក់ក្នុងយុទ្ធសាស្ត្រចតុកោណ ។ ចំពោះសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច ក្រុមការងារនៃក្រសួងទំនាក់ទំនងជាមួយ រដ្ឋសភា ព្រឹទ្ធសភានិង អធិការកិច្ច បានជួបពិភាក្សាជាមួយអ្នកជំនាញការជប៉ុន ហើយបានផ្តល់ អនុសាសន៍ថាសេចក្តីព្រាងច្បាប់នេះនឹងត្រូវរៀបចំឡើង បន្ទាប់ពីបានអនុម័តច្បាប់ស្តីពីការប្រឆាំង នឹងអំពើពុករលួយ ។

២៩- ការរៀបចំច្បាប់គ្រឹះក៏មានវឌ្ឍនភាពគួរឱ្យកត់សំគាល់ ដើម្បីរៀបចំប្រព័ន្ធច្បាប់មួយប្រកបដោយប្រសិទ្ធភាព ថ្វីត្បិតតែសកម្មភាពមួយចំនួនមិនទាន់បានអនុវត្តតាមកាលបរិច្ឆេទក៏ដោយ ។ ក្រុមចំនួន៣ រួមមាន ក្រុមនីតិវិធីព្រហ្មទណ្ឌ ក្រុមរដ្ឋប្បវេណី និងក្រុមនីតិវិធីរដ្ឋប្បវេណី (ដែលត្រូវអនុមតិដោយគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦) ស្របតាមកាលបរិច្ឆេទកំណត់ ដែល

បានឯកភាពគ្នាក្នុងកិច្ចប្រជុំពិគ្រោះយោបល់ឆ្នាំ២០០៦ ។ ទន្ទឹមនេះ ក៏មានការយឺតយ៉ាវ ក្នុងការស្នើជូនគណៈរដ្ឋមន្ត្រីអនុម័តក្រមព្រហ្មទណ្ឌ ដោយមូលហេតុថា ច្បាប់គ្រឹះមួយចំនួនត្រូវបានអនុម័តមុនក្រមព្រហ្មទណ្ឌ ។ ដូចនេះហើយ ទើបតម្រូវឱ្យមានការពិនិត្យសេចក្ដីព្រាងក្រមព្រហ្មទណ្ឌជាច្រើនដងដើម្បីធានាសង្គតិភាពជាមួយនឹងច្បាប់ទាំងនោះ ។ បច្ចុប្បន្ន សេចក្ដីព្រាងក្រមព្រហ្មទណ្ឌត្រូវបានស្នើទីស្ដីការគណៈរដ្ឋមន្ត្រី សម្រាប់ពិភាក្សាអន្តរក្រសួង ។ លើសពីនេះ ក៏មានការយឺតយ៉ាវក្នុងការបញ្ចប់សេចក្ដីព្រាងច្បាប់នានាដែលទាក់ទងនឹងប្រព័ន្ធតុលាការផងដែរ (ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃអង្គតុលាការ ច្បាប់វិសោធនកម្មលើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា) ។ មូលហេតុនៃការយឺតយ៉ាវនេះ គឺបណ្ដាលមកពីកង្វះខាតអ្នកជំនាញការក្នុងក្រសួងយុត្តិធម៌ និងបញ្ហាពេលវេលាផងដែរ ។

៣០- រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ និងអនុមតិច្បាប់និងលិខិតបទដ្ឋានសំខាន់ៗដែលចាំបាច់ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់អង្គការពាណិជ្ជកម្មពិភពលោក ។ ច្បាប់ទាំងនោះរួមមាន ÷

- សេចក្ដីព្រាងច្បាប់ស្ដីពីប្រតិបត្តិការមានការធានា នឹងត្រូវអនុម័តនៅពាក់កណ្ដាលឆ្នាំ២០០៧
- ច្បាប់ស្ដីពីមជ្ឈត្តកម្មពាណិជ្ជកម្មត្រូវបានប្រកាសឱ្យប្រើនាថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៦
- ច្បាប់ស្ដីពីសហគ្រាសពាណិកម្មត្រូវបានប្រកាសឱ្យប្រើនៅខែមិថុនា ឆ្នាំ២០០៥
- អនុក្រឹត្យសម្រាប់រៀបចំគណៈកម្មាធិការអន្តរក្រសួងថ្មី ដើម្បីអនុវត្តការប្ដេជ្ញានៃអង្គការពាណិជ្ជកម្មពិភពលោក ត្រូវបានអនុមតិនាថ្ងៃទី៧ ខែមិនា ឆ្នាំ២០០៧
- អនុក្រឹត្យស្ដីការអនុវត្តច្បាប់ស្ដីពីផ្លាកសញ្ញាពាណិជ្ជកម្ម ពាណិជ្ជកម្មនាម និងការប្រកួតប្រជែងមិនស្មើភាព ត្រូវបានអនុមតិនាខែកក្កដា ឆ្នាំ២០០៦
- អនុក្រឹត្យស្ដីពីតំបន់សេដ្ឋកិច្ចពិសេស ត្រូវបានអនុមតិនាខែធ្នូ ឆ្នាំ២០០៥

៣១- បន្ទាប់ពីកម្ពុជាបានផ្ដល់សច្ចាប័នលើពិធីសារ Palermo នៃអង្គការសហប្រជាជាតិស្ដីពីការទប់ស្កាត់លុបបំបាត់ និងផ្ដន្ទាទោសលើការជួញដូរមនុស្ស ពិសេស ការជួញដូរស្ត្រី និងកុមារ និងបន្ទាប់ពីបានរៀបចំសេចក្ដីព្រាងក្រមព្រហ្មទណ្ឌរួចមក យើងក៏ត្រូវកែសម្រួលសេចក្ដីព្រាងច្បាប់ស្ដីពីការលុបបំបាត់ការជួញដូរមនុស្ស និងការជួញដូរផ្លូវភេទ ដើម្បីឱ្យមានសង្គតិភាពជាមួយនឹងបទដ្ឋានគតិយុត្តិទាំង នេះ ។ ច្បាប់ព្រហ្មទណ្ឌត្រូវតែមានសង្គតិភាពជាមួយនឹងច្បាប់ក្នុងស្រុក ទាំងបច្ចេកទេស គតិយុត្តិ និងទាំងតម្លៃនៃប្រព័ន្ធ ។ សេចក្ដីព្រាងដែលបានកែតម្រូវនេះកំពុងត្រូវបានពិភាក្សា ។ ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារីកំពុងសហការគ្នាលើបញ្ហានេះ ។ ទន្ទឹមនេះ ក្រុមការងារអន្តរក្រសួងសម្រាប់ទប់ស្កាត់ការជួញដូរមនុស្សត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ដំណើរការនេះ ។

៣២- ផែនការសកម្មភាពជាតិស្ដីពីការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាលើស្ត្រី ត្រូវបានរៀបចំឡើង ហើយកំពុងត្រូវបានពិភាក្សានៅផ្ទៃក្នុងក្រសួងកិច្ចការនារី ហើយការផ្សព្វផ្សាយជាផ្លូវការនូវផែនការសកម្មភាពជាតិក៏កំពុងរៀបចំផងដែរ ។ ដើម្បីត្រៀមលក្ខណៈអនុវត្តផែនការសកម្មភាពនេះ វគ្គបណ្ដុះបណ្ដាលត្រូវបានរៀបចំឡើងសម្រាប់គ្រូបង្គោល ដែលជានគរបាល ចៅក្រមនៅបណ្ដាខេត្តនានា ព្រមទាំងមេឃុំ

និងប្រធានភូមិទាំងអស់ ។ លើសពីនេះទៀត ក្រសួងមហាផ្ទៃ និងក្រសួងកិច្ចការនារីបានសហការគ្នារៀបចំអនុក្រឹត្យស្តីពីការសម្រេចខាងរដ្ឋបាល និងកិច្ចសហការរវាងអាជ្ញាធរមូលដ្ឋាន និងនគរបាលពាក់ព័ន្ធនឹងបញ្ហាអំពើហិង្សាក្នុងគ្រួសារ ។ អនុក្រឹត្យនេះក៏តម្រូវឱ្យមានការពិភាក្សាដ៏សមស្របមួយដើម្បីធានាឱ្យមានសង្គតិភាពជាមួយនឹងច្បាប់អង្គការស្តីពីវិមជ្ឈការនិងវិសហមជ្ឈការ ។ ប៉ុន្តែ ដោយសារច្បាប់ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារបានចូលជាធរមាន អស់រយៈពេលជាង១ឆ្នាំមកហើយ ការអនុមតិអនុក្រឹត្យនេះគួរតែជាការងារអាទិភាពដើម្បីអនុវត្តច្បាប់ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារនេះ ។

៣៣- ការរៀបចំលិខិតបទដ្ឋាន សម្រាប់អនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ ត្រូវបានបញ្ចប់តាមកាលបរិច្ឆេទកំណត់ ចំពោះចំណុចដែលថា "ការចុះបញ្ជីដីរដ្ឋអាចចាប់ដំណើរការ"។ លិខិតបទដ្ឋានដែលបានអនុមតិរួមមាន ៖ ១- ប្រកាសលេខ៤២ ចុះថ្ងៃទី១០ ខែមិនា ឆ្នាំ ២០០៦ ស្តីពីការបញ្ជាក់ទីតាំងដីរដ្ឋផែនទីដីរដ្ឋ និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ។ ២- សេចក្តីសំរេច លេខ៥២ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីលក្ខខ័ណ្ឌវិនិច្ឆ័យសម្រាប់ការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ជាឧបសម្ព័ន្ធនៃប្រកាសលេខ៤២ ចុះថ្ងៃទី១០ ខែ មិនា ឆ្នាំ២០០៦ ។

៣៤- ដើម្បីអនុវត្តមាត្រា១៨នៃច្បាប់ភូមិបាល **សម្តេចនាយករដ្ឋមន្ត្រី** បានចុះហត្ថលេខាលើសារាចរ ណែនាំមួយកាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នឹងបន្តផ្សព្វផ្សាយសារាចរនេះឱ្យបានទូលំទូលាយ ។

៣៥- សេចក្តីព្រាងបឋមស្តីពីគោលនយោបាយក្នុងការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិច ត្រូវបានរៀបចំរួចហើយ ។ សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនិងថ្នាក់តំបន់ ត្រូវបាន រៀបចំនៅចុងខែធ្នូ ឆ្នាំ២០០៦ ហើយវេទិកាអន្តរជាតិបានប្រារព្ធនៅចុងខែមករា និងដើមខែកុម្ភៈ ឆ្នាំ២០០៧ ដោយមានការចូលរួមពីមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល តំណាងជនជាតិដើមភាគតិច បណ្តាស្ថាប័នពាក់ព័ន្ធ សង្គមស៊ីវិល អង្គការជាតិ និងអន្តរជាតិ ប្រមាណ៤០០នាក់ ។ អគ្គលេខាធិការនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លីបានកែសម្រួលសេចក្តីព្រាងបឋមនេះ ដោយផ្អែកតាមអនុសាសន៍ដែលប្រមូលបានពីសិក្ខាសាលាពិគ្រោះយោបល់ទាំងនេះ ។ ក្រុមប្រឹក្សាគោលនយោបាយដីធ្លីបានពិភាក្សាសេចក្តីព្រាងគោលនយោបាយនេះ កាលពីថ្ងៃទី២៥ខែមេសាឆ្នាំ២០០៧ ។ បន្ទាប់ពីបានអនុម័តដោយក្រុមប្រឹក្សាគោលនយោបាយដីធ្លី សេចក្តីព្រាងបឋមនេះនឹងត្រូវផ្ញើជូនគណៈរដ្ឋមន្ត្រី ដើម្បី ពិនិត្យ និងអនុម័ត ។

៣៦- ក្រុមការងារអន្តរក្រសួងបានសាកល្បងរៀបចំលក្ខន្តិកៈ សហគមន៍ជនជាតិដើមភាគតិច ក្នុងភូមិ៣ ។ លក្ខន្តិកៈជនជាតិដើមភាគតិចនេះ គឺជាមូលដ្ឋានគ្រឹះនៃការបង្កើត និងការទទួលស្គាល់សហគមន៍ជនជាតិដើមភាគតិច ដើម្បីអាចឱ្យពួកគេមានសិទ្ធិស្របច្បាប់ក្នុងការចុះបញ្ជី និងកាន់កាប់ដីសហគមន៍ ។ ជាលទ្ធផល ក្នុងការអនុវត្តន៍សាកល្បងក្នុងសហគមន៍ទំពួន ភូមិឡាអឺនក្នុងស្រុកកូនមុំ និងសហគមន៍ទំពួន ភូមិឡាអេនក្រេនក្នុងស្រុកអូរជុំ ខេត្តរតនៈគីរី និងភូមិអណ្តូងក្រលែង ខេត្តមណ្ឌលគីរី លក្ខន្តិកៈបីត្រូវបានចុះបញ្ជី ដោយមានការទទួលស្គាល់ជាផ្លូវការពីក្រសួងមហាផ្ទៃ ។

៣៧- ដើម្បីឆ្លើយតបនឹងសំណួរ « តើរាជរដ្ឋាភិបាលមានយុទ្ធសាស្ត្រអ្វីខ្លះដើម្បីការពារដីសហគមន៍ជនជាតិដើមភាគតិច មុនពេលធ្វើការចុះបញ្ជី?» នេះ យោងតាមស្មារតីនៃសិក្ខាសាលាថ្នាក់ជាតិ និងថ្នាក់តំបន់ រាជរដ្ឋាភិបាលបានសម្រេច អនុវត្តតាមនីតិវិធី និងយន្តការដែលចែងនៅក្នុងអនុក្រឹត្យលេខ១១៨ ស្តីពីការគ្រប់គ្រងដីរដ្ឋ ។ យោងតាមអនុក្រឹត្យនេះ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ពិសេស ក្រុមការងារសម្រាប់គ្រប់គ្រងដីរដ្ឋថ្នាក់ស្រុក នឹងបន្តដំណើរការបញ្ជាក់ដីធ្លី រៀបចំផែនទី និងចំណាត់ថ្នាក់ ដីធ្លី ។ លទ្ធផលដំបូងនៃដំណើរការនេះ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈដល់សហគមន៍ ដើម្បីបង្ហាញពីទីតាំងដី ដែលសហគមន៍នីមួយៗបាននិងកំពុងរស់ជាប្រចាំ ដោយមានការទទួលស្គាល់ពីសហគមន៍ជិតខាងនិងអជ្ញាធរមូលដ្ឋាន ។ បន្ទាប់ពីបានដោះស្រាយបញ្ហានានារួចមក គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តនឹងចេញសេចក្តីសំរេចទទួលស្គាល់ជាបណ្តោះអាសន្ន ។

**គោលដៅ** : បន្តពង្រឹងរដ្ឋបាលសាធារណៈ

ដើម្បីបំរើផលប្រយោជន៍ប្រជាពលរដ្ឋនិងដើម្បីក្លាយជាដៃគូអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព

**សកម្មភាពចាំបាច់** :

- អនុវត្ត "យុទ្ធសាស្ត្ររួមរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ស្តីពីការបញ្ឈប់អនុវត្តជាជំហានៗ នូវការផ្តល់ប្រាក់បៀវត្សរ៍បន្ថែមដោយ :
  - ក- អនុវត្តផែនការសកម្មភាពតាមវិស័យដែលបានឯកភាព និង
  - ខ- បង្កើតកន្សោមអាទិភាព (PMGs) និងអនុវត្តប្រព័ន្ធលាភការផ្អែកលើលទ្ធផលការងារ (PMG/MPBIs) នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងយ៉ាងតិចបំផុតនៅក្រសួង/ស្ថាប័នមួយទៀត
- កែលំអការផ្តល់ប្រាក់បៀវត្សរ៍និងលក្ខខ័ណ្ឌការងាររបស់មន្ត្រីរាជការ :
  - ក- រៀបចំយុទ្ធសាស្ត្រនិងផែនការរយៈពេលមធ្យមសម្រាប់កែលំអបៀវត្សរ៍និង
  - ខ- រៀបចំគោលនយោបាយ និងផែនការសកម្មភាពស្តីពីការពង្រាយមន្ត្រីរាជការ
- រៀបចំ និងអនុវត្តគោលនយោបាយនិងផែនការសកម្មភាពស្តីពីការគ្រប់គ្រងធនធានមនុស្ស ដោយប្រើប្រាស់មគ្គុទេសក៏ស្តីពីការគ្រប់គ្រងធនធានមនុស្ស និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់មន្ត្រីរាជការស៊ីវិល
- កែលំអការផ្តល់សេវា តាមរយៈការង្កើតយន្តការបញ្ជរតែមួយ និងពង្រឹងក្របខ័ណ្ឌច្បាប់ ដោយបង្កើតបញ្ជរតែមួយ ឱ្យបានយ៉ាងតិច៥កន្លែងទៀតនៅទូទាំងប្រទេស

៣៨- ចំពោះការបញ្ឈប់អនុវត្តជាជំហានៗនូវការផ្តល់ប្រាក់បៀវត្សរ៍បន្ថែម ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបានទទួលចម្លើយជាច្រើនដែលពាក់ព័ន្ធនឹងសំណួរស្តីពីការអនុវត្តន៍ប្រាក់បៀវត្សបន្ថែម ។ ដើម្បីបន្តអនុវត្តយុទ្ធសាស្ត្រដែលបានអនុមតិនេះ យើងត្រូវអនុវត្តជំហានដំបូងឱ្យបានចប់សព្វគ្រប់ជាមុនសិន ។ បញ្ហាកង្វះខាតធនធាន និងការផ្តល់ធនធានមិនបានតាមកាលបរិច្ឆេទកំណត់ បានជះឥទ្ធិពលអវិជ្ជមានដល់វឌ្ឍនភាពនៃការអនុវត្តន៍យុទ្ធសាស្ត្រស្តីពីការបញ្ឈប់ជាជំហានៗក្នុងការផ្តល់ប្រាក់បៀវត្សរ៍បន្ថែមនេះ ។

ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសូមស្វាគមន៍ចំពោះការផ្តល់ធនធាននានា ដើម្បីអនុវត្តយុទ្ធសាស្រ្តបញ្ឈប់ជាជំហានៗនូវការផ្តល់ប្រាក់បៀវត្សរ៍បន្ថែមនេះ ។ ការអនុញ្ញាតឱ្យជួលទីប្រឹក្សាសម្រាប់សិក្សាបញ្ហានេះទើបត្រូវបានសម្រេចកាលពីខែកញ្ញា ឆ្នាំ២០០៦ថ្មីៗនេះប៉ុណ្ណោះ ។

៣៩- បន្ទាប់ពីមានការចចារត្រីភាគីរវាងក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ អនុស្សារណៈយោគយល់គ្នាមួយ (រួមទាំងឯកសារណែនាំអំពីប្រព័ន្ធប្រាក់បៀវត្សរ៍តាមប្រសិទ្ធភាពការងារ) ត្រូវបានចុះហត្ថលេខាកាលពីខែឧសភា ឆ្នាំ២០០៥ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានបញ្ចប់ដំណើរការជ្រើសរើស ដូចដែលមានចែងនៅក្នុងអនុក្រឹត្យលេខ៩៨ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០០៥ ស្តីពីការអនុវត្តន៍ប្រព័ន្ធលាភការផ្អែកលើលទ្ធផលការងារ ។ ការផ្តល់លាភការផ្អែកលើលទ្ធផលការងារ បានចាប់ផ្តើមអនុវត្តកាលពីចុងឆ្នាំ២០០៥ ។ ទន្ទឹមនេះ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ប្រព័ន្ធលាភការផ្អែកលើលទ្ធផលការងារត្រូវបានរៀបចំនៅក្រសួងសុខាភិបាល ។ ទោះបីជាក្រសួងសុខាភិបាលបានព្រមព្រៀងជាគោលការណ៍ជាមួយនឹងក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលនិងដៃគូអភិវឌ្ឍន៍ ឱ្យមានការពិភាក្សាបន្តទៀតក៏ដោយ ក៏ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបានគូសបញ្ជាក់ថា ការអនុវត្តន៍ប្រព័ន្ធប្រាក់បៀវត្សរ៍នេះត្រូវធានាឱ្យមានសង្គតិភាពជាមួយនឹងបញ្ញត្តិដែលមានចែងអនុក្រឹត្យលេខ៩៨ ស្តីពីការអនុវត្តន៍ប្រព័ន្ធលាភការផ្អែកលើលទ្ធផលការងារ ។ អនុក្រឹត្យនេះបានចែងថា ជំហានដំបូងត្រូវអនុវត្តកន្សោមអាទិភាពជាមុនសិន ហើយប្រសិនបើដៃគូអភិវឌ្ឍន៍មានបំណងបន្ថែមប្រាក់បំណាច់ដល់មន្រ្តីរាជការ ពួកគេអាចផ្តល់បន្ថែមលើកន្សោមអាទិភាពនេះបាន ។ ប្រព័ន្ធលាភការផ្អែកលើលទ្ធផលការងារ ក្នុងក្រសួងពាណិជ្ជកម្ម ក៏ជាប្រធានបទនៃកិច្ចពិភាក្សាដែរ ។ កិច្ចពិភាក្សាជាមួយនឹងក្រសួងពាណិជ្ជកម្មកំពុងដំណើរការ ដើម្បីរៀបចំប្រព័ន្ធប្រាក់បៀវត្សរ៍នេះនៅក្រសួងពាណិជ្ជកម្ម នាឆ្នាំ២០០៧នេះ ។

៤០- ការសិក្សាចំនួន២ស្តីពីគោលនយោបាយប្រាក់បៀវត្សរ៍ និងគោលនយោបាយពង្រាយមន្រ្តីរាជការ ត្រូវបានអនុវត្តចប់សព្វគ្រប់ ហើយរបាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាទាំងនេះក៏ត្រូវបានផ្សព្វផ្សាយរួចហើយដែរ ។ បច្ចុប្បន្ន ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលកំពុងរៀបចំឯកសារទស្សនទាន ស្តីពីគោលនយោបាយស្តីពីប្រាក់បៀវត្សរ៍សម្រាប់រយៈពេលមធ្យម និងគោលនយោបាយការងារ ។

៤១- ឯកសារទស្សនទានស្តីពីការគ្រប់គ្រងនិងការអភិវឌ្ឍន៍ធនធានមនុស្សត្រូវបានរៀបចំ សម្រាប់ស្នើជូនក្រុមការងារបច្ចេកទេសចម្រុះរបស់ខ្លួន កាលពីខែតុលាឆ្នាំ២០០៦ ដើម្បីផ្តល់យោបល់និងអនុសាសន៍ ។ រហូតមកដល់ពេលនេះ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលមិនទាន់បានទទួលយោបល់ និងអនុសាសន៍លើឯកសារទស្សនទាននេះនៅឡើយ ។ ការពិគ្រោះយោបល់ថ្នាក់អន្តរក្រសួងលើគោលនយោបាយគ្រប់គ្រងធនធានមនុស្សនឹងត្រូវរៀបចំក្នុងពេលឆាប់ៗនេះ ។ គោលនយោបាយថ្មីនេះ នឹងជួយពង្រឹងប្រសិទ្ធភាពការងារ ហើយក៏អាចជួយពង្រឹងយន្តការស្តីពីលទ្ធផលការងារផងដែរ ។ លើសពីនេះ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលក៏មានថវិកាគ្រប់គ្រាន់ សម្រាប់រៀបចំប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យាដែរ ។

៤២- រាជរដ្ឋាភិបាលកំពុងអនុវត្តគោលនយោបាយស្តីពីការផ្តល់សេវាកម្ម ដែលត្រូវបានអនុមតិកាលពីថ្ងៃទី៥ ខែឧសភាឆ្នាំ២០០៦ ។ សេចក្តីព្រាងគោលនយោបាយស្តីពី«សេវាកម្មច្រកចេញ-ចូលតែមួយ» ត្រូវបានរៀបចំ និងបច្ចុប្បន្ននេះ កំពុងធ្វើសមាហរណកម្មជាមួយនឹងទស្សនទានស្តីពី «ភ្នាក់ងារប្រតិបត្តិការពិសេស» ។ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលកំពុងរៀបចំខ្លួន សម្រាប់ក្លាយជាមជ្ឈមណ្ឌលសេវាកម្មដោយផ្អែកតាមប្រព័ន្ធកន្សោមអាទិភាព ។

៤៣- ជារួម គុណភាព និងពេលវេលានៃធនធាន ដែលរួមមានទាំងការជួយពង្រឹងសមត្ថភាពស្ថាប័នរាជរដ្ឋាភិបាលផង គឺជាកត្តាកំណត់នៃជោគជ័យក្នុងការអនុវត្តន៍សូចនាករតាមដានរួមគ្នា ។ យើងបានឃើញច្បាស់ថាធនធានដែលរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍បានផ្តល់ តាមរយៈក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទំរង់រដ្ឋបាលសាធារណៈ បានធ្លាក់ចុះយ៉ាងខ្លាំងបើធៀបនឹងការសន្យារបស់ខ្លួន ។ ការធ្លាក់ចុះនៃធនធាននេះ មិនឆ្លើយតបនឹងតម្រូវការបន្ទាន់នៃកំណែទំរង់រដ្ឋបាលសាធារណៈឡើយ ។ កន្លងមក មានដៃគូអភិវឌ្ឍន៍តែ១គត់ ដែលបានផ្តោតអាទិភាពរបស់ខ្លួន ទៅលើកំណែទំរង់រដ្ឋបាលសាធារណៈ ។ ក្រុមការងារបច្ចេកទេសចម្រុះសំរាប់កំណែទំរង់រដ្ឋបាលសាធារណៈបានឯកភាពលើសូចនាករតាមដានរួមគ្នា អស់រយៈពេល១ឆ្នាំមកហើយ ប៉ុន្តែ ក្រុមការងារបច្ចេកទេសចម្រុះនេះ ត្រូវរង់ចាំអស់រយៈពេល១ឆ្នាំទៀត ទើបបានទទួលហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់អនុវត្តសូចនាកររបស់ខ្លួន ។

៤៤- ទោះបីជាមានវឌ្ឍនភាពក្នុងកំណែទំរង់រដ្ឋបាលស៊ីវិលក៏ដោយ ក៏រាជរដ្ឋាភិបាលបានបន្តប្តេជ្ញាពង្រីក និងបង្កើនល្បឿនកំណែទំរង់ ។ ក្នុងរយៈពេលដ៏ខ្លី រដ្ឋបាលស៊ីវិលនឹងក្លាយជាអ្នកផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងមានទំនុកចិត្តពីដៃគូអភិវឌ្ឍន៍ ។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏កំណែទំរង់គឺជាកំណែទំរង់ដែលត្រូវអនុវត្តតាមលទ្ធភាពដែលអាចធ្វើទៅបាន មិនមែនជាកំណែទំរង់ដែលត្រូវធ្វើតាមចំណង់នោះឡើយ ។ នេះគឺជាបញ្ហានៃការកសាងសមត្ថភាព និងចីរភាពនៃកំណែទំរង់ ។ ដើម្បីឱ្យកំណែទំរង់នេះកាន់តែស៊ីជំរៅបន្ថែមទៀតក្នុងរយៈពេលមធ្យម ក្រុមប្រឹក្សាកំណែទំរង់បានផ្តួចផ្តើមរៀបចំគោលនយោបាយចំនួន៦ និងផែនការអនុវត្តគោលនយោបាយទាំងនេះផងដែរ ។ កំណែទំរង់ទាំងនេះ គឺជាកំណែទំរង់ដ៏មានសារៈសំខាន់ និងមានភាពច្បាស់លាស់ ។ ប៉ុន្តែ ដៃគូអភិវឌ្ឍន៍មួយចំនួននៅមិនទាន់យកចិត្តទុកដាក់ចំពោះ «កម្មវិធីជាតិស្តីពីកំណែទំរង់រដ្ឋបាល» ។ នេះជាយុទ្ធសាស្ត្រមួយប្រកបដោយភាពរលូន និងប្រទាក់ក្រឡា ដែលផ្តោតការយកចិត្តទុកដាក់ដល់កំណែទំរង់ដ៏ទូលំទូលាយ និងសម្រាប់រយៈពេលវែង ដោយមិនផ្តោតទៅលើតែ២-៣ចំណុច សម្រាប់ឆ្លើយតបនឹងតម្រូវការនិងផលប្រយោជន៍ក្នុងរយៈពេលខ្លីឡើយ ។ ដៃគូអភិវឌ្ឍន៍ខ្លះនៅតែបន្តតស៊ូមតិសម្រាប់ជំរើសនៃកំណែទំរង់ដែលគ្មានចីរភាព ហើយមិនឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់កម្ពុជា ។ នេះជាជំហររបស់រាជរដ្ឋាភិបាលដែលយល់ឃើញថា រដ្ឋបាលសាធារណៈមិនអាចត្រូវពង្រឹង តាមរយៈការតម្លើងប្រាក់ខែតែមួយមុខនោះទេ ។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលត្រូវការហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីអភិវឌ្ឍសមត្ថភាពរបស់ខ្លួន មិនមែនត្រូវការការបញ្ជាណែនាំ

ឬក៏អ្នកជំនាញការឱ្យមកធ្វើការជំនួសខ្លួនឡើយ ។ ក្នុងបរិការណ៍នៃកំណែទំរង់រដ្ឋបាល នេះគឺជាពេលវេលាសមស្របសម្រាប់ពិនិត្យនិងកែលំអក្រុមការងារបច្ចេកទេសចម្រុះ ។ ក្រុមប្រឹក្សាកំណែទំរង់ រដ្ឋបាលនឹងសហការជាមួយនឹងដៃគូអភិវឌ្ឍន៍ក្នុងភាពជាដៃគូ ការគោរពគ្នាទៅវិញទៅមក និងគណនេយ្យភាពទ្វេទិស ។

**គោលដៅ** : រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលស្តីពីកំណែទំរង់វិមជ្ឈការនិងវិសហមជ្ឈការ និងបន្តរៀបចំជំហានបឋម ដើម្បីឈានទៅអនុវត្តឱ្យបានពេញលេញ

**សកម្មភាពចាំបាច់** :

- បញ្ចប់សេចក្តីព្រាងច្បាប់អង្គការស្តីពីការពង្រឹងលទ្ធិប្រជាធិបតេយ្យ នៅក្រោមថ្នាក់ជាតិ ដើម្បីស្នើជូនរដ្ឋសភា
- រៀបចំក្របខ័ណ្ឌសម្រាប់អនុវត្តច្បាប់អង្គការស្តីពីកំណែទំរង់វិមជ្ឈការនិងវិសហមជ្ឈការ (បន្ទាប់ពីការអនុមតិពីស្ថាប័ននីតិប្បញ្ញត្តិ)
- ពិនិត្យនិងរៀបចំកម្មវិធីគាំទ្រវិមជ្ឈការនិងវិសហមជ្ឈការ សម្រាប់កំណែទំរង់និងការវិនិយោគសម្រាប់កិច្ចអភិវឌ្ឍន៍មូលដ្ឋាន

៤៥- ចាប់ពីឆ្នាំ២០០៦ រាជរដ្ឋាភិបាលបានសម្រេចនូវវឌ្ឍនភាពក្នុងកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការដើម្បីអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។ វឌ្ឍនភាពសំខាន់ៗចំនួន៣សម្រាប់ពន្លឿនកំណែទំរង់វិមជ្ឈការនិងវិសហមជ្ឈការក្នុងរយៈពលខ្លី ត្រូវបានរាយការណ៍ជូនកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ កាលពីខែមិថុនា ឆ្នាំ២០០៦ ។ វឌ្ឍនភាពទាំងនេះ រួមមាន ÷

- សេចក្តីព្រាងច្បាប់អង្គការបានត្រូវបញ្ចប់ និងដាក់ជូនទៅក្រសួងមហាផ្ទៃដើម្បីពិនិត្យ
- ការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌបឋមសម្រាប់អនុវត្តច្បាប់អង្គការ
- ក្រសួងមហាផ្ទៃបានបញ្ចប់ការសិក្សាឯករាជ្យ ស្តីពីជម្រើសសម្រាប់ដៃគូអភិវឌ្ឍន៍ផ្តល់ហិរញ្ញប្បទាន និងការគាំទ្រដល់កំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ។

៤៦- សេចក្តីព្រាងច្បាប់អង្គការលើកទី១ ដែលមាន៥ជំពូក ត្រូវបានបញ្ចប់កាលពីខែធ្នូ ឆ្នាំ២០០៦ ។ ក្រសួងមហាផ្ទៃកំពុងដឹកនាំការពិភាក្សាលើសេចក្តីព្រាងលើកទីមួយនេះ ។ ដោយផ្អែកលើការពិភាក្សានេះក្រសួងមហាផ្ទៃកំពុងរៀបចំសេចក្តីព្រាងច្បាប់នេះឡើងវិញ ។ ឯកសារមួយដែលស្នើបញ្ច្រាបយេនឌ័រទៅក្នុងសេចក្តីព្រាងច្បាប់អង្គការ រួមទាំងអនុសាសន៍មួយចំនួនផង បានត្រូវរៀបចំឡើង និងស្នើជូនក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការនិងវិសហមជ្ឈការ ជាផ្លូវ ការ ។ កិច្ចប្រជុំសម្រាប់ពិភាក្សាឯកសារនេះត្រូវបានរៀបចំឡើងរវាងគណៈប្រតិភូ ដែលដឹកនាំដោយប្រធានក្រុមការងារសម្រាប់យេនឌ័រនៃក្រសួងកិច្ចការនារី និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ស ខេង** ព្រមទាំងសហការី ។ តាមរយៈកិច្ចប្រជុំនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានគាំទ្រ និងឯកភាព

ដោយផ្ទាល់លើអនុសាសន៍ក្នុងឯកសារនេះ ។ ក្រុមការងារមួយត្រូវបានបង្កើតឡើង សម្រាប់សម្របសម្រួល និងមានតួនាទីផ្តល់អនុសាសន៍ខាងយេនដ័រទៅលើសេចក្តីព្រាងច្បាប់អង្គការ ។ បទបង្ហាញ និងការពិភាក្សាពីទិដ្ឋភាពផ្សេងៗនៃសេចក្តីព្រាងច្បាប់ ត្រូវបានអនុវត្តឡើងក្នុងគណៈកម្មាការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការនិងវិសហមជ្ឈការ និងក្នុងវេទិកាជាមួយនឹងក្រុមប្រឹក្សាឃុំ- សង្កាត់ អង្គការក្រៅរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងក្រសួង/ស្ថាប័នពាក់ព័ន្ធ ។ គោលដៅនៃការស្នើសេចក្តីព្រាងច្បាប់ជូនរដ្ឋសភាពិនិត្យ មិនទាន់អនុវត្តឱ្យបានសម្រេចនៅឡើយ ដោយសារតែភាពស្មុគ្រស្មាញខាងផ្នែកបច្ចេកទេស និងគោលនយោបាយនៃច្បាប់នេះ មានច្រើនជាងការគិតទុក ។ ភាពស្មុគ្រស្មាញនេះតម្រូវឱ្យបញ្ចូលនូវចំណុចពិស្តារជាច្រើនទៀត ដើម្បីចៀសវាងការភ័ណ្ឌច្រឡំ និងភាពមិនច្បាស់លាស់ និងដើម្បីណែនាំទិសដៅសម្រាប់រយៈពេលវែងនាអនាគត ។

៤៧- យុទ្ធសាស្ត្រសម្រាប់អនុវត្តច្បាប់អង្គការ ដែលរួមមានដំណាក់កាលចំនួនបួន ត្រូវបានកំណត់ដោយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ស ខេង** ដែលបានផ្សព្វផ្សាយក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍កាលពីខែកុម្ភៈ ឆ្នាំ២០០៦ ។ យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើង ក្នុងទម្រង់ជាក្របខ័ណ្ឌអនុវត្តបឋម (បណ្តោះអាសន្ន) ។ ក្របខ័ណ្ឌអនុវត្តបឋមនេះត្រូវបានរៀបចំឡើង ក្នុងត្រីមាសទី១ ឆ្នាំ២០០៦ ហើយត្រូវបានអនុម័តដោយគណៈកម្មាការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ នាខែកញ្ញា ឆ្នាំ២០០៦ ។ ក្របខ័ណ្ឌនេះបានកំណត់អំពីសមាសធាតុសំខាន់ៗអាទិភាពនិងសកម្មភាពនានា សម្រាប់អនុវត្តកំណែទំរង់និងអនុវត្តច្បាប់អង្គការ ។ ក្របខ័ណ្ឌនេះក៏បានកំណត់អំពីសកម្មភាពត្រៀមជាច្រើន ក្នុងខណៈដែលច្បាប់អង្គការត្រូវបានរៀបចំឡើងវិញ និងរង់ចាំការអនុមតិពីរដ្ឋសភា ។ សមាសធាតុនៃដំណាក់កាលត្រៀមត្រូវបានផ្សព្វផ្សាយកាលពីខែ មិថុនា ឆ្នាំ២០០៦ ដើម្បីជាមូលដ្ឋានសម្រាប់ដៃគូអភិវឌ្ឍន៍ផ្តល់ការគាំទ្រសម្រាប់ឆ្នាំ២០០៧ ។ ហេតុដូច្នេះ ក្របខ័ណ្ឌនេះគឺជាមគ្គុទេសក៍ និងផ្តល់ជាជម្រើសនិងកាលបរិច្ឆេទ សម្រាប់ក្រសួង ពាក់ព័ន្ធ ភ្នាក់ងារអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ រៀបចំកម្មវិធីអភិវឌ្ឍន៍រយៈពេលខ្លី រយៈពេលមធ្យម រយៈពេលវែង ដោយត្រូវតម្រឹមជាមួយនឹងយុទ្ធសាស្ត្រ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ទោះបីជាយ៉ាងនេះក្តី ដោយសារក្របខ័ណ្ឌអនុវត្តនេះស្ថិតក្នុងដំណាក់កាលដំបូង និងមានលក្ខណៈបណ្តោះអាសន្ន ការអនុវត្តន៍ក្របខ័ណ្ឌនេះប្រាកដជាជួបការលំបាកជាច្រើន ហើយទាមទារឱ្យពិនិត្យនិងកែសំរួលឡើងវិញ ឱស្របនឹងស្មារតីនៃសេចក្តីព្រាងច្បាប់ដែលបានកែលំអ និងគោលនយោបាយបន្ថែម ដូចដែលមានចែងក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលបានអនុមិតដោយរាជរដ្ឋាភិបាលក្នុងឆ្នាំ២០០៥ ។

៤៨- ក្រោមការដឹកនាំរបស់គណៈកម្មាការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ និងផ្អែកតាមក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ និងគោលការណ៍នានាសម្រាប់រៀបចំសេចក្តីព្រាងច្បាប់អង្គការ រាជរដ្ឋាភិបាលបន្តការប្តេជ្ញារៀបចំ និងអនុមតិ «កម្មវិធីជាតិស្តីពីការអភិវឌ្ឍន៍ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ» ឱ្យបានមុនដំណាច់ឆ្នាំ២០០៧ នេះ ។ បន្ទាប់ពី

បានពិនិត្យ និងធ្វើបច្ចុប្បន្នភាពលើលក្ខខ័ណ្ឌយោងសម្រាប់រៀបចំកម្មវិធី យើងរំពឹងទុកថា ទីប្រឹក្សាមួយក្រុមនឹងត្រូវបានជ្រើសរើសឡើងក្នុងត្រីមាសទីបីនៃឆ្នាំ២០០៧ ដើម្បីធ្វើការយ៉ាងជិតស្និតជាមួយនឹងគណៈកម្មាការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ សម្រាប់រៀបចំកម្មវិធី ដោយការពិគ្រោះយោបល់យ៉ាងទៀតទាត់ជាមួយនឹងក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ ។ ក្រោមការដឹកនាំរបស់ក្រុមការងារនៃគណៈកម្មាការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការនិងវិសហមជ្ឈការ កម្មវិធីដែលត្រូវរៀបចំនេះ នឹងក្លាយទៅជាក្របខ័ណ្ឌមួយ សម្រាប់កៀរគរធនធាន ទាំងក្នុងស្រុក និងពីបរទេស ។ ធនធានទាំងនេះគឺជាវិភាគទានសម្រាប់ ÷

១- ការសម្របសម្រួលរវាងគោលនយោបាយសារពើពន្ធ គោលនយោបាយរដ្ឋបាល និងគោលនយោបាយតាមវិស័យ ជាមួយនឹងក្របខ័ណ្ឌគតិយុត្តិនៅក្រោមថ្នាក់ជាតិ

២- កំណែទំរង់រចនាសម្ព័ន្ធខាងស្ថាប័ន និងប្រព័ន្ធអភិបាលកិច្ច

៣- ការវិនិយោគសេដ្ឋកិច្ច- សង្គមកិច្ច ដោយផ្តោតទៅលើការកាត់បន្ថយភាពក្រីក្រ ។

ដើម្បីពង្រឹងអភិក្រមគ្រប់គ្រងតាមកម្មវិធី (Program-based approach) សុខដុមនីយកម្ម និងការតម្រឹម ការរៀបចំកម្មវិធីនេះក៏ត្រូវបញ្ចូលនូវមូលនិធិវិមជ្ឈការនិងវិសហមជ្ឈការ (D&D Fund Facility) និងកិច្ចព្រមព្រៀងក្រោមឆ័តតែមួយស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ សម្រាប់គាំទ្រវិមជ្ឈការ និងវិសហមជ្ឈការ (Umbrella Agreement on Government-Donor Partnership in support to D&D)។

**គោលដៅ** : អនុវត្តកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**សកម្មភាពចាំបាច់** :

- បន្តអនុវត្តកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (បញ្ចប់ដំណាក់កាលទី១/កន្សោម ទី១ និងចាប់ផ្តើមដំណាក់កាលទី២) និងតាមដានលទ្ធផលតាមរយៈសូចនាករដែលបានឯកភាព

៤៩- រាជរដ្ឋាភិបាលសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សំគាល់ ក្នុងកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ វឌ្ឍនភាពសំខាន់ៗរួមមាន លទ្ធផលនៃដំណាក់កាលទី១ក្នុងការបង្កើនជំនឿទុកចិត្តលើថវិកា និងការងាររៀបចំមួយចំនួនសម្រាប់ដំណើរការអនុវត្តដំណាក់កាលទី២ សំដៅពង្រឹងគណនេយ្យភាព ដើម្បីសម្រេចឱ្យបាននូវការគ្រប់គ្រងហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព ។ ក្នុងឆ្នាំ២០០៦ រាជរដ្ឋាភិបាលប្រមូលចំណូលក្នុងស្រុកបាន ១០៥,៤%នៃទិសដៅ និងបានបង្កើនអត្រានិងការតម្រឹមក្នុងប្រតិបត្តិការថវិកា ហើយបានធ្វើអោយបំណុលថយចុះមកត្រឹម៣៨% ។ ទោះបីជាដំណាក់កាលទី១មិនត្រូវសម្រេចបានយ៉ាងពេញលេញក៏ដោយ ក៏សកម្មភាពអាទិភាព និងការងារចាំបាច់ដើម្បីសម្រេចបានដំណាក់កាលទី១ ក្នុងឆ្នាំ២០០៧ ត្រូវបានកំណត់និងឯកភាពគ្នា ក្នុងពេលប្រជុំប្រចាំឆ្នាំ នាថ្ងៃទី០៩-១០ខែមេសាឆ្នាំ២០០៧ នៅខេត្តសៀមរាប សម្រាប់ត្រួតពិនិត្យជាយុទ្ធសាស្ត្រ ។ សកម្មភាពដែលនៅសេសសល់ គឺជាការពង្រឹងសមិទ្ធផលនៃដំណាក់កាលទី១ ក្នុងខណៈពេលដែលត្រូវធ្វើដំណើរឆ្ពោះទៅកាន់ដំណាក់កាលបន្ទាប់ ។ ជាមួយគ្នានេះដែរ ក៏មានការឯកភាពគ្នាលើការ

ចាប់ផ្តើមផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០០៧ ដើម្បីអនុវត្តជំហានបន្ទាប់ សំដៅសម្រេចឱ្យបានលទ្ធផលក្នុងដំណាក់កាលទី២ ។

៥០- លទ្ធផលដែលសម្រេចបានរួមមាន : ការកែលំអការប្រមូលចំណូល ការដាក់ឱ្យប្រើប្រាស់នូវផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ២០០៧ ការពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារ ការចាត់វិធានការដើម្បីពង្រឹងប្រព័ន្ធលទ្ធកម្មសាធារណៈ ការកាត់បន្ថយបែបបទនៃការចំណាយ និងគំនិតផ្តួចផ្តើមថ្មីៗផ្សេងទៀតដូចជា ការរៀបចំនូវចំណាត់ថ្នាក់ថ្មីនៃថវិកា និងប្លង់គណនេយ្យថ្មី ការអនុវត្តន៍សាកល្បងនូវថវិកានីយកម្មកម្មវិធីក្នុងឆ្នាំ២០០៧ ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងតាមក្រសួងនានា ការរៀបចំប្រព័ន្ធព័ត៌មានវិទ្យា និងទូរគមនាគមន៍ថ្មីដោយផ្អែកលើការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មាន ក៏ដូចជាការការពង្រឹងសមត្ថភាព រួមមានការអនុវត្តន៍ប្រព័ន្ធប្រាក់បៀវត្សតាមប្រសិទ្ធភាពការងារ ដើម្បីលើកទឹកចិត្តដល់មន្ត្រីរាជការ ។

៥១- ក្របខ័ណ្ឌនៃការគ្រប់គ្រងប្រមូលចំណូលរដ្ឋមានវឌ្ឍនភាពជាបណ្តើរៗ ។ ប្រាក់ចំណូលដែលប្រមូលបានធៀបនឹងផែនការគឺ ១១៤,៧%ក្នុងឆ្នាំ២០០៥ និង ១០៥,៤%ក្នុងឆ្នាំ២០០៦ ។ ចំណូលពន្ធបានកើនឡើងដល់២០,៤%ក្នុងឆ្នាំ២០០៥ និង២០,២%ក្នុងឆ្នាំ២០០៦ ។ ចំណូលមិនមែនពន្ធបានកើនឡើងដល់៦,៦%ក្នុងឆ្នាំ២០០៥ និង៩,៣%ក្នុងឆ្នាំ២០០៦ ។ កំណើននៃចំណូលនេះកើតឡើងដោយសារលក្ខខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចអំណោយផល និងការប្រឹងប្រែងប្រមូលចំណូលរដ្ឋប្រកបដោយប្រសិទ្ធភាព ក្រោមការគ្រប់គ្រងរបស់ប្រព័ន្ធពន្ធដារដែលមានស្រាប់ ព្រមទាំងការអនុវត្តន៍វិធានការថ្មីៗជាច្រើន ។ វិធានការថ្មីៗរួមមាន ការអនុវត្តន៍ប្រព័ន្ធ ASYCUDA និងការរៀបចំការគ្រប់គ្រងហានិភ័យ សេចក្តីព្រាងច្បាប់ គយ បទបញ្ជារាជរដ្ឋាភិបាលស្តីពីចំណូលមិនមែនពន្ធ និងសេចក្តីព្រាងច្បាប់កាស៊ីណូ អនុក្រឹត្យស្តីពីបទបញ្ញត្តិនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ អនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ៧៣ស្តីពីការកែប្រែអត្រាពន្ធគយ ពន្ធពិសេសលើមុខទំនិញមួយចំនួន និងពន្ធតម្លៃបន្ថែមលើប្រេងឥន្ធនៈ ។ វិធានការទាំងនេះនឹងបន្តពង្រឹងការប្រមូលចំណូលរដ្ឋបន្ថែមទៀត ។

៥២ ផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំឡើង និងដាក់ឱ្យប្រើប្រាស់ ក្នុងពេលរៀបចំថវិកាសម្រាប់ឆ្នាំសារពើពន្ធ២០០៧ ។ ផែនការយុទ្ធសាស្ត្រនេះតម្រូវឱ្យបញ្ចូលនូវថវិកាមូលធន ដែលរាប់បញ្ចូល ទាំងចំណាយមូលធនដែលជាហិរញ្ញប្បទានរបស់រដ្ឋ និងដៃគូអភិវឌ្ឍន៍ រួមទាំងគំរោងដែលកំពុងដំណើរការផងដែរ ។ ដំណើរការប្រឆ្នូបនៃថវិកា និងប្រតិទិនថ្មីត្រូវបានដាក់ឱ្យប្រើប្រាស់ ដែលអនុញ្ញាតឱ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់រៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងការពិភាក្សារវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បណ្តាក្រសួងនិងភាគីពាក់ព័ន្ធ ។

៥៣- រាជរដ្ឋាភិបាលបានសម្រេចវឌ្ឍនភាពជាច្រើនក្នុងការគ្រប់គ្រងសាច់ប្រាក់ និងការពង្រឹងគណនីរបស់ រដ្ឋ និងប្រតិបត្តិការគណនីរតនាគារតែមួយ ការកែលំអប្រព័ន្ធបើកប្រាក់តាមរតនាគារ រៀបចំផែនការសាច់ប្រាក់ និងការគ្រប់គ្រងបំណុល ។ គណនីរបស់រដ្ឋដែលគ្មានការអនុញ្ញាតចំនួនរាប់រយ ត្រូវបាន

បិទចោល ។ ផែនការសកម្មភាពយុទ្ធសាស្ត្រ ដើម្បីបន្តដោះស្រាយ និងបិទគណនីរដ្ឋដែលគ្មានការអនុញ្ញាត កំពុងដំណើរការ ។ ប្រព័ន្ធគណនេយ្យដោយប្រើកុំព្យូទ័រតាមប្លង់គណនេយ្យថ្មី ត្រូវបានដាក់ឱ្យប្រើប្រាស់ ។ ផែនការយុទ្ធសាស្ត្រសម្រាប់កែលំអប្រតិបត្តិការគណនីរតនាគារតែមួយ ។ ការពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារនៅថ្នាក់ជាតិនិងនៅតាមបណ្តាខេត្ត កំពុងដំណើរការ ។ ដោយមានការគាំទ្រពីអង្គភាពគ្រប់គ្រងសាច់ប្រាក់ គណៈកម្មាធិការគ្រប់គ្រងថវិកាត្រូវបានបង្កើតឡើង ដើម្បីត្រួតពិនិត្យការអនុវត្តន៍ថវិកា ពិសេសដើម្បីពិនិត្យការគ្រប់គ្រងសាច់ប្រាក់ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ផែនការសកម្មភាពយុទ្ធសាស្ត្រត្រូវបាន និងកំពុងអភិវឌ្ឍន៍បន្ថែមទៀត ដើម្បីកែលំអនិងពង្រីកតួនាទី និងប្រតិបត្តិការរបស់គណៈកម្មាធិការគ្រប់គ្រងថវិកា និងអង្គភាពគ្រប់គ្រងសាច់ប្រាក់ ។

៥៤- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានកំពុងពន្លឿនកំណែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ។ ដើម្បីបំពេញចន្លោះប្រហោងនៃអនុក្រឹត្យលទ្ធកម្មឆ្នាំ១៩៩៥ និងបទបញ្ញត្តិ ឆ្នាំ១៩៩៨ ក៏ដូចជាដើម្បីធ្វើបច្ចុប្បន្នភាពបទដ្ឋានទាំងនេះឱ្យស្របនឹងការអនុវត្តន៍លទ្ធកម្មសាធារណៈ យើងបានរៀបចំធ្វើវិសោធនកម្មអនុក្រឹត្យព្រមទាំងបទបញ្ញត្តិពាក់ព័ន្ធនានា ។ អនុក្រឹត្យថ្មីដែលបានអនុមតិដោយ **សម្តេច នាយករដ្ឋមន្ត្រី** កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ បានកំណត់គោលការណ៍ទូទៅ និងប្រព័ន្ធលទ្ធកម្មសាធារណៈ ។ អនុក្រឹត្យនេះបានជួយកែលំអក្របខ័ណ្ឌនៃការអនុវត្តន៍លទ្ធកម្មសាធារណៈ ។ នាខែមករា ឆ្នាំ២០០៧ បទបញ្ញត្តិផ្ទៃក្នុង រួមទាំងឯកសារដេញថ្លៃ ត្រូវបានអនុមតិ ដើម្បីគាំទ្រការអនុវត្តន៍អនុក្រឹត្យថ្មីនេះ។ បទបញ្ញត្តិថ្មីបានចែងយ៉ាងពិស្តារ អំពីនីតិវិធីលទ្ធកម្ម និងបានបញ្ជាក់ច្បាស់លាស់អំពីតួនាទី និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងលទ្ធកម្ម ដើម្បីកំណើនសេដ្ឋកិច្ច និងបង្កើនប្រសិទ្ធភាព និងតម្លាភាព ។

៥៥- ទន្ទឹមនេះ ក៏តម្រូវឱ្យប្រឹងប្រែងពង្រឹងសមត្ថភាពជាក់លាក់ ដើម្បីពង្រឹងសមត្ថភាពនៃនាយកដ្ឋានលទ្ធកម្មសាធារណៈ ក៏ដូចជាក្រសួងពាក់ព័ន្ធ និងមន្ទីរខេត្ត- ក្រុង ក្នុងការអនុវត្តន៍ប្រព័ន្ធលទ្ធកម្មថ្មី នេះ ។ កិច្ចប្រឹងប្រែងនេះរួមមានកម្មវិធីបណ្តុះបណ្តាលអំពី ÷ អនុក្រឹត្យលទ្ធកម្មថ្មី បទបញ្ញត្តិថ្មី ឯកសារដេញថ្លៃ និងបទពិសោធន៍ល្អៗនៃការអនុវត្តន៍លទ្ធកម្មសាធារណៈ ។

៥៦- រាជរដ្ឋាភិបាលក៏សម្រេចបានវឌ្ឍនភាពជាច្រើនក្នុងការរៀបចំបែបបទសម្រាប់ប្រតិបត្តិការថវិកា ។ សារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សារាចរអន្តរក្រសួង និងឯកសារណែនាំមួយត្រូវបានដាក់ឱ្យប្រើប្រាស់ និងបានចូលជាធរមានកាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៧ ។ ចំពោះសម្ភារៈដែលមិនត្រូវធ្វើលទ្ធកម្ម យើងបានច្របាច់បញ្ចូលគ្នារវាងការធានាចំណាយនិងការអនុញ្ញាតចំណាយ។ ចំពោះសម្ភារៈដែលត្រូវធ្វើលទ្ធកម្ម ការធានាចំណាយត្រូវបានផ្តល់សម្រាប់រយៈពេល៦ខែ ដោយផ្អែកតាមផែនការលទ្ធកម្ម ។ កំណែទម្រង់នេះបានផ្តល់សិទ្ធិឱ្យមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុតាមក្រសួងពាក់ព័ន្ធ ក្នុងការបញ្ជាក់ និងអនុញ្ញាតឱ្យបើកប្រាក់បៀវត្សរ៍មន្ត្រីរាជការ ។ ដូច្នេះ បានលុបចោលនីតិវិធីនៃការសុំអនុញ្ញាតជាមុនក្នុងការបើកប្រាក់បៀវត្សរ៍ ។ បច្ចុប្បន្ន ប្រព័ន្ធបើកសាច់ប្រាក់ជាមុន (រហូតដល់៣០%នៃថវិកាសរុបសម្រាប់សម្ភារៈដែលមិនត្រូវធ្វើលទ្ធកម្ម និងសម្រាប់ការបើកសាច់

ប្រាក់ម្តងក្នុង១ត្រីមាស (រហូតដល់២០%នៃថវិកាសរុបសម្រាប់សម្ភារៈដែលត្រូវធ្វើលទ្ធកម្ម ) ត្រូវបានដាក់ឱ្យអនុវត្តក្នុងក្រសួងអាទិភាពចំនួន៧ ដែលអនុវត្តសាកល្បងនូវថវិកាតាមកម្មវិធី ។ ការអនុវត្តន៍ពិសេសសម្រាប់ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានរៀបចំឡើងផងដែរ ។ លទ្ធផលថ្មីៗក្នុងឆ្នាំ២០០៧បានបង្ហាញឱ្យឃើញថា រយៈពេលដំណើរការនៃការផ្តល់ធានាចំណាយ និងការអនុមតិចំណាយសំរាប់សម្ភារៈដែលមិនត្រូវធ្វើលទ្ធកម្ម ត្រូវបានកាត់បន្ថយពី២៣ថ្ងៃ មកត្រឹម ៣ថ្ងៃ ឬមកត្រឹម៨៥%។

៥៧- ដើម្បីកែលំអការគ្រប់គ្រងសាច់ប្រាក់ ក៏តម្រូវឱ្យមានការពង្រឹងសមត្ថភាព និងការវិភាគអំពីតួនាទី និងការទទួលខុសត្រូវផងដែរ ។ ការបន្តពង្រឹងគណនីរដ្ឋ និងការអនុវត្តន៍ដោយជោគជ័យនូវគណនីរតនាគារតែមួយ នឹងជួយសម្រួលបន្ថែមទៀតដល់ការប្រើប្រាស់ធនធានដែលមាន ព្រមទាំងជួយកាត់បន្ថយការបាត់តុល្យភាពសាច់ប្រាក់ដែលមិនប្រើប្រាស់ ។ ការបង្កើតប្រព័ន្ធទិន្នន័យបំណុល និងនីតិវិធីនៃការទូទាត់បំណុល អាចជួយលុបបំបាត់បំណុលប្រកបដោយចីរភាព ។

៥៨- ផ្អែកតាមផែនការសកម្មភាពអាទិភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានអនុវត្តសាកល្បងថវិកានីយ-កម្មតាមកម្មវិធី ក្នុងក្រសួងចំនួន៧ (ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្មនិង សំណង់ ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី) ចាប់ពីខែមករា ឆ្នាំ២០០៧ ។ ទោះបីជាការអនុវត្តន៍ថវិកានីយកម្មតាមកម្មវិធីនេះ គឺជាជំហានដំបូងនៃការអនុវត្តន៍ផែនការសកម្មភាពអាទិភាពក៏ដោយ ក៏នេះគឺជាការចាំបាច់ ដែលត្រូវចាប់ផ្តើមសម្រាប់បង្កើតទំនាក់ទំនងគោលនយោបាយថវិកា និងកែលំអកិច្ចដំណើរការរៀបចំថវិកា ។ ថវិកានីយកម្មតាមកម្មវិធីមានសារៈសំខាន់ សម្រាប់ពិនិត្យមើលលទ្ធផលនៃការផ្តល់សេវាកម្មសាធារណៈ ក៏ដូចជាការត្រួតពិនិត្យសូចនាករនៃការអនុវត្តន៍កម្មវិធី ។

៥៩- ទោះបីបានដាក់ឱ្យអនុវត្តយ៉ាងជោគជ័យក៏ដោយ ក៏ការអនុវត្តន៍ប្លង់គណនេយ្យថ្មីបានជួបប្រទះនឹងការលំបាកខ្លះដែរ ។ ដូច្នេះ ត្រូវបន្តពង្រឹងការអនុវត្តន៍ថវិកា និងសមត្ថភាពរបស់ក្រសួងនិមួយៗ ក្នុងការរៀបចំរបាយការណ៍ចំណាយ ។ ជាមួយគ្នានេះ ការពង្រឹងសមត្ថភាពអនុវត្តថវិការបស់ក្រសួងទាំង៧ ក៏ជាកត្តាសំខាន់ សម្រាប់ធានាជោគជ័យក្នុងការអនុវត្តន៍គំរោងសាកល្បង ក៏ដូចជាការពង្រីកការអនុវត្តន៍ថវិកាតាមកម្មវិធីដែរ ។

៦០- ទន្ទឹមនឹងការរៀបចំដំណាក់កាលទី២ ក៏បានសម្រេចវឌ្ឍនភាពលើសវនកម្មផ្ទៃក្នុង និងការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងត្រូវបានបង្កើតនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយអង្គភាពសវនកម្មផ្ទៃក្នុងចំនួន១៩ត្រូវបានបង្កើតតាមក្រសួងនានា ។ បច្ចុប្បន្ន មានតែអង្គភាពសវនកម្មផ្ទៃក្នុងចំនួន៦ប៉ុណ្ណោះ ដែលបានដំណើរការដោយមានបុគ្គលិក និងវគ្គបណ្តុះបណ្តាលត្រឹមត្រូវ ។ ដើម្បីសម្រេចការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា យើងត្រូវសម្រេចបានលទ្ធផលនៃដំណាក់កាលទី២ជាមុនសិន ។ ដំណាក់កាលទី២នេះកំពុងរៀបចំ ទន្ទឹមនឹងការវាយតម្លៃអំពីវឌ្ឍនភាពក្នុងការអនុវត្តន៍ដំណាក់កាលដំបូងរបស់ខ្លួន ។ អង្គភាពថ្មីសម្រាប់គ្រប់គ្រងហិរញ្ញ-

វត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យាត្រូវបានបង្កើតក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយរចនាសម្ព័ន្ធគ្រប់គ្រងក៏កំពុងរៀបចំ ដើម្បីសម្រួលដល់ការអនុវត្តន៍ ។ ទន្ទឹមនេះ ក៏ត្រូវអនុវត្តការងារសំខាន់ៗជាច្រើននៅក្នុងឆ្នាំ២០០៧នេះ ដើម្បីរៀបចំបញ្ចប់នីតិវិធីដំណើរការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា ក៏ដូចជាការបង្កើនសមត្ថភាពការងារក្នុងភាពជាដៃគូជាមួយនឹងភាគីកិច្ចសន្យា ដើម្បីប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព នូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា នៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅតាមរតនាគារខេត្ត និងក្រសួងនានា ។

**គោលដៅ** : លើកកំពស់ជីវភាពរស់នៅរបស់ជនក្រីក្រ និងកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ និងពង្រឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដូចមានក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០

**សកម្មភាពចាំបាច់** :

- រៀបចំយុទ្ធសាស្ត្ររយៈពេលមធ្យមសម្រាប់វិស័យកសិកម្មនិងការស្រោចស្រព ដោយផ្អែកតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រដែលមានស្រាប់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រសួងធនធានទឹក និងឧតុនិយម
- បង្កើតយន្តការផ្សព្វផ្សាយព័ត៌មានស្តីពីសម្បទានដីសេដ្ឋកិច្ច ផ្អែកតាមសេចក្តីសម្រេចរបស់សម្តេចនាយករដ្ឋមន្ត្រី កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៥
- ចាត់វិធានការសមស្របដើម្បីបញ្ចូលអាទិភាពវិស័យជលផលទៅក្នុងផែនការអភិវឌ្ឍន៍ខេត្ត ស្រុក និង ឃុំ ក៏ដូចជាទំហំហិរញ្ញប្បទានសហប្រតិបត្តិការ សំដៅលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ ជនបទ ។
- លើកកំពស់ជីវភាពជនក្រីក្រ៥០០គ្រួសារ ដោយផ្តល់ដីសម្បទានសង្គមកិច្ច រួមជាមួយនឹងការគាំទ្រខាងជីវភាពរស់នៅ ។ រក្សាដីយ៉ាងតិចចំនួន១០.០០០ហិចតាសម្រាប់ដីសម្បទានសង្គមកិច្ច ។
- រៀបចំគោលនយោបាយសុវត្ថិភាពសង្គម ដើម្បីធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់ក្រុមជនងាយរងគ្រោះ
- រៀបចំប្រព័ន្ធតាមដានសុវត្ថិភាពស្បៀង និងអាហារូបត្ថម្ភ

៦១- សេចក្តីព្រាងយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងការស្រោចស្រព (២០០៦-២០១០) ត្រូវបានរៀបចំ ហើយកំពុងស្នើសុំការអនុមតិពីរាជរដ្ឋាភិបាល ។ យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដោយផ្អែកតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រដែលមានស្រាប់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងយុទ្ធសាស្ត្ររបស់ក្រសួងធនធានទឹក និងឧតុនិយម ។ យុទ្ធសាស្ត្រនេះរួមមានសមាសធាតុសំខាន់ៗចំនួន៥ គឺ ÷

- ការពង្រឹងសមត្ថភាពខាងស្ថាប័ន និងខាងការគ្រប់គ្រង និងកម្មវិធីគាំទ្រវិស័យកសិកម្មនិងការស្រោចស្រព ។
- កម្មវិធីគាំទ្រសន្តិសុខស្បៀង (ដោយមានធាតុចូលពីក្រុមការងារបច្ចេកទេសចម្រុះសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ)។
- កម្មវិធីគាំទ្រវិស័យកសិកម្ម និងកសិពាណិជ្ជកម្ម (ខ្សែសង្វាក់ផលិតកម្ម)។

- កម្មវិធីស្តីពីប្រភពធនធានទឹក ធារាសាស្ត្រ និងគ្រប់គ្រងដីធ្លី ។
- កម្មវិធីស្រាវជ្រាវកសិកម្ម និងធនធានទឹក និងគ្រប់គ្រងដីធ្លី ។

៦២- ទន្ទឹមនេះ ក៏កំពុងរៀបចំលក្ខខ័ណ្ឌយោងសម្រាប់រៀបចំកម្មវិធីនិមួយៗ និងតម្រូវការចំណាយ ដែលរំពឹងថា កិច្ចការទាំងនេះនឹងត្រូវបញ្ចប់នៅដើមឆ្នាំ២០០៧ ។ ក្រុមការងារកំពុងរៀបចំបង្កើតឡើងសម្រាប់សុំការអនុមតិពីក្រសួងសាមី ។ ដៃគូអភិវឌ្ឍន៍មួយចំនួនបានសន្យាជាគោលការណ៍ថា នឹងផ្តល់ការគាំទ្រខាងហិរញ្ញប្បទាន សម្រាប់ដំណើរការរៀបចំកម្មវិធីទាំងនេះ ។ វឌ្ឍនភាព និងព័ត៌មានស្តីពីការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ សម្រាប់អនុវត្តយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងការស្រោចស្រព នេះនឹងបញ្ជាក់ឱ្យបានពិស្តារបន្ថែមទៀត នៅពេលក្រោយបញ្ចប់ការរៀបចំចំណាយសម្រាប់កម្មវិធី និមួយៗ ដែលសង្ឃឹមថា នឹងអាចបញ្ចប់នាពាក់កណ្តាលឆ្នាំ២០០៧នេះ ។

៦៣- ព័ត៌មានស្តីពីដីសម្បទានសេដ្ឋកិច្ចបានដាក់ក្នុងគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ (www.maff.gov.kh/elc) ដែលបានធ្វើបច្ចុប្បន្នភាពរៀងរាល់៦ខែម្តង ដោយយោងតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចនាយករដ្ឋមន្ត្រី** កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៥ ។

៦៤- ការចូលរួមពីវិស័យឯកជនក្នុងការអភិវឌ្ឍន៍គឺជាអាទិភាពមួយរបស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលបានចាត់ទុកវិស័យឯកជនជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច ។ ដោយសារបរិស្ថានវិនិយោគក្នុងកម្ពុជាបានត្រូវកែលំអជាបណ្តើរៗ ការផ្តល់ដីសម្បទានសេដ្ឋកិច្ចឱ្យវិស័យឯកជនបានកើនឡើងក្នុងឆ្នាំ២០០៥ និងឆ្នាំ២០០៦ ។ ការកើនឡើងចំនួនដីសម្បទានសេដ្ឋកិច្ច គឺជាលទ្ធផលនៃកិច្ចខិតខំកំណែទំរង់របស់រាជរដ្ឋាភិបាល រួមទាំងការកែលំអសេវាសាធារណៈ ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ។ បន្ទាប់ពីបានអនុម័តអនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច យន្តការជាច្រើនត្រូវបានបង្កើតឡើង ដើម្បីអនុវត្តបទបញ្ញត្តិនិងនីតិវិធីដែលចែងក្នុងអនុក្រឹត្យនេះ ដោយផ្តោតការយកចិត្តទុកដាក់លើផលប៉ះពាល់ខាងផ្នែកសេដ្ឋកិច្ច-សង្គមកិច្ច និងបរិស្ថាននៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច ។ ការងារទាំងនេះត្រូវអនុវត្ត តាមរយៈលេខាធិការដ្ឋានបច្ចេកទេសអន្តរៈក្រសួងស្តីពីដីសម្បទានសេដ្ឋកិច្ច ដែលដឹកនាំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយសហការយ៉ាងជិតស្និតជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធ ។ ការផ្តល់ដីសម្បទានសេដ្ឋកិច្ចនាបច្ចុប្បន្ន និងនាអនាគត ត្រូវអនុវត្តចំពោះដីណាដែលគ្មានជីវជាតិ និងគ្មានលទ្ធភាពសម្រាប់ដាំដើមឈើ ឬសម្រាប់អភិវឌ្ឍព្រៃឈើប៉ុណ្ណោះ ។ ដីឯកជន និងដីរបស់សហគមន៍ជនជាតិភាគតិចមិនត្រូវបានចាត់ទុកជាមុខសញ្ញា សម្រាប់កំណត់ជាដីសម្បទានសេដ្ឋកិច្ចឡើយ ។

៦៥- រាជរដ្ឋាភិបាលបានចាត់វិធានការជាច្រើន ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញអំពីអាទិភាពនៃវិស័យជលផលក្នុងការកែលំអជីវភាពរបស់សហគមន៍ជនបទនៅគ្រប់កម្រិត ។ វិធានការទាំងនោះរួមមាន ÷ ការធ្វើសមាហរណកម្មជលផលទៅក្នុងផែនការអភិវឌ្ឍន៍របស់ក្រសួងនិងស្ថាប័នពាក់ព័ន្ធនានា ក៏ដូចជាដៃគូអភិវឌ្ឍន៍ ។ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្ញើលិខិតមួយជូនក្រសួងពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង និងដៃគូអភិវឌ្ឍន៍ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៦ ដើម្បីស្នើឱ្យមានការគាំទ្រ

ពីភាគីពាក់ព័ន្ធទាំងនេះ សម្រាប់អនុវត្តឱ្យបានសម្រេចនូវសូចនាករតាមដានរួមគ្នា ។ ស្មារតីនៃលិខិតនេះត្រូវបានរៀបចំឡើង ដោយផ្អែកតាមសុន្ទរកថារបស់សម្តេចនាយករដ្ឋមន្ត្រី កាលពីថ្ងៃទី២៩ ខែមិនា ឆ្នាំ២០០៦ ក្នុងសន្និសីទរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ស្តីពី «ការត្រួតពិនិត្យសមិទ្ធផលក្នុងឆ្នាំ២០០៥-២០០៦ និងទិសដៅសម្រាប់ឆ្នាំ២០០៦-២០០៧» ។ ក្នុងឱកាសនោះ សម្តេច នាយករដ្ឋមន្ត្រីបានណែនាំថា : «គ្រប់ក្រសួងនិងស្ថាប័ន សាលាខេត្ត-ក្រុង និងមន្ទីរខេត្ត-ក្រុង ត្រូវពិចារណាអំពីអាទិភាព ដើម្បីបញ្ចូលវិស័យជលផលទៅក្នុងផែនការអភិវឌ្ឍន៍របស់ខ្លួន ដោយត្រូវសហការយ៉ាងជិតស្និទ្ធជាមួយនឹងដៃគូអភិវឌ្ឍន៍» ។

៦៦- រដ្ឋបាលជលផលបានរៀបចំសិក្ខាសាលា សម្រាប់ផ្សព្វផ្សាយច្បាប់ជលផលដល់បណ្តាក្រសួង-ស្ថាប័ន អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ នាថ្ងៃទី២៥-២៧ ខែតុលា ឆ្នាំ២០០៦ នៅរាជធានីភ្នំពេញ ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ បានពិភាក្សា និងអនុមតិលើប្រកាសស្តីពីការប្រព្រឹត្តទៅរបស់រដ្ឋបាលជលផល ។ ទន្ទឹមនឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក៏បានពិនិត្យសេចក្តីព្រាងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមនេសាទ ។ ប្រកាសនេះនឹងត្រូវអនុមតិ បន្ទាប់ពីបានកែប្រែអនុក្រឹត្យសហគមន៍នេសាទស្តីពីការគ្រប់គ្រងជលផល ដើម្បីធានាឱ្យមានសង្គតិភាពជាមួយនឹងច្បាប់ជលផលថ្មី ។

៦៧- ទន្ទឹមនេះ រដ្ឋបាលជលផលក៏បានចាត់វិធានការមួយចំនួន សម្រាប់តំបន់ព្រៃលិចទឹក និងការអភិរក្សតំបន់ឆ្នេរសមុទ្រផងដែរ ។ រដ្ឋបាលជលផលបានរៀបចំកិច្ចប្រជុំ ដើម្បីពិភាក្សាអំពីវិធានការសមស្របនានា ដើម្បីទប់ទល់នឹងការកាប់ព្រៃលិចទឹក និងការរុករានដីក្នុងតំបន់ឡូតិ៍នេសាទ និងក្នុងតំបន់នេសាទរបស់សហគមន៍ ។ រដ្ឋបាលជលផលបានរៀបចំផែនទីកំណត់ព្រំប្រទល់ព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប ហើយក៏បានកៀរគរមូលនិធិសម្រាប់កំណត់ដែនឡូតិ៍នេសាទរួចហើយដែរ ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុមតិផែនការសកម្មភាពសម្រាប់រយៈពេល១០ឆ្នាំ ស្តីពីផ្កាថ្មនិងសារាយសមុទ្រ ហើយបច្ចុប្បន្ន កំពុងរៀបចំផ្សព្វផ្សាយ ។

៦៨- លើសពីនេះ រដ្ឋបាលជលផលក៏កំពុងពិនិត្យរចនាសម្ព័ន្ធខាងស្ថាប័នឡើងវិញដែរ ។ រដ្ឋបាលជលផលបានពិនិត្យក្របខ័ណ្ឌយុទ្ធសាស្ត្រ សម្រាប់ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្នុងផ្នែកជលផល ហើយកំពុងរង់ចាំការអនុមតិពីក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិស័យជលផលនេះ ។ ដើម្បីធានាឱ្យមានសង្គតិភាពជាមួយនឹងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម រដ្ឋបាលជលផលកំពុងរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដែលនឹងត្រូវបញ្ចូលទៅក្នុងផែនការសកម្មភាពឆ្នាំ២០០៧ របស់រដ្ឋបាលជលផល ។ ដើម្បីស្វែងយល់ពីតួនាទីរបស់ស្ថាប័នជលផលនៅថ្នាក់ក្រោមជាតិ រដ្ឋបាលជលផលបានធ្វើការសិក្សាមួយ នាខែកុម្ភៈឆ្នាំ២០០៦ ដើម្បីបំពេញបន្ថែមទៅលើរបាយការណ៍ស្តីពីការពិនិត្យស្ថាប័នឡើងវិញ ។ របាយការណ៍នៃការសិក្សានេះកំពុងរៀបចំសម្រាប់ផ្សព្វផ្សាយ ។ របាយការណ៍នៃការ

សិក្សានេះបានពិនិត្យឡើងវិញ អំពីតួនាទីរបស់រដ្ឋបាលជលផលថ្នាក់មូលដ្ឋាន ក្នុងការផ្តល់សេវាជលផលនៅថ្នាក់ខេត្ត ស្រុក និងឃុំ ។

៦៩- រដ្ឋបាលជលផលបានកៀរគរមូលនិធិដើម្បីអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំរបស់ខ្លួន ដោយចាប់ផ្តើមពីមូលនិធិអង្គការ DFID/DANIDA សម្រាប់រៀបចំវិស័យនេះតាមអភិក្រមគ្រប់គ្រងទូទាំងវិស័យ ។ ទន្ទឹមនឹងនេះ ដោយអនុលោមតាមគោលនយោបាយ និងយុទ្ធសាស្ត្របញ្ញាបយេនឌ័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ គោលនយោបាយនិងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យជលផលក៏ត្រូវបានរៀបចំរួចហើយដែរ ។ គោលនយោបាយ និងយុទ្ធសាស្ត្រនេះនឹងត្រូវអនុមតិ ហើយអនុវត្តនាដំណាច់ឆ្នាំ២០០៧ ។ រដ្ឋបាលជលផលក៏បានរៀបចំរបាយការណ៍ពិភាក្សាស្តីពីការត្រួតពិនិត្យនិងវាយតម្លៃវិស័យជលផល ហើយក៏បានលើកមកពិភាក្សាក្នុងក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិស័យជលផលផងដែរ ។ ជាលទ្ធផល រដ្ឋបាលជលផលបានឯកភាពលើការបង្កើតអង្គភាពត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តន៍សកម្មភាពជលផល ។

៧០- បច្ចុប្បន្ន សហគមន៍អ្នកនេសាទមានចំនួន ៥០៩ ហើយទីជម្រកត្រីសហគមន៍មានចំនួន ៦២ ។ រដ្ឋបាលជលផលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងសមត្ថភាពរបស់សហគមន៍ ដើម្បីធានាការគ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព ។

៧១- គោលដៅនៃការផ្តល់ដីសម្បទានសង្គមកិច្ចដល់ប្រជាពលរដ្ឋចំនួន៥០០គ្រួសារ ដោយផ្តល់ការគាំទ្រដល់ជីវភាពរស់នៅរបស់គ្រួសារជនបទ ត្រូវបានឯកភាពគ្នាក្នុងបរិការណ៍នៃការអនុវត្តន៍សាកល្បងចំនួនពីរសម្រាប់ដីសម្បទានសង្គមកិច្ចនៃគំរោង «ការបែងចែកដីធ្លីសំរាប់អភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម- កិច្ច» ក្នុងស្រុកមេមត់ ខេត្តកំពង់ចាម និងស្រុកក្រចេះ ខេត្តក្រចេះ ។ លទ្ធផលមានដូចតទៅ ÷

ក- នៅក្នុងឃុំជាម នៃស្រុកមេមត់ ខេត្តកំពង់ចាម ដីរដ្ឋចំនួន៩៩០ហិកតា កំពុងត្រូវបានដំណើរការចុះបញ្ជីជាដីឯកជនរបស់រដ្ឋ ។ នៅពេលបញ្ចប់ដំណើរការ គ្រួសារចំនួនជិត១៥០នឹងត្រូវផ្តល់អាទិភាពឱ្យរស់នៅលើដីទាំងនេះ ។

ខ- នៅក្នុងឃុំចំ់ក្រង និងឃុំសំបុកនៃស្រុកក្រចេះ ខេត្តក្រចេះ ដីរដ្ឋចំនួន៤.៤០០ហិកតា ត្រូវបានចុះបញ្ជីជាដីឯកជនរបស់រដ្ឋ សម្រាប់គ្រួសារចំនួន៥០០ស្នាក់នៅ ។

៧២- ទន្ទឹមនេះ ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ បានចេញបទបញ្ញត្តិជាច្រើន សម្រាប់អនុវត្តកម្មវិធីផ្តល់ដីសម្បទានសង្គមកិច្ច ដូចជា ÷ ប្រកាសអន្តរក្រសួងរវាងក្រសួងរៀបចំដែនដីនគររូបនីយកម្មនិងសំណង់ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ លេខ៥០៧ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីយន្តការផ្សព្វផ្សាយកសិកម្មដល់ប្រជាកសិករ ក្នុងក្របខ័ណ្ឌដីសម្បទានសង្គមកិច្ច និងសេចក្តីព្រាងសេចក្តីសំរេចស្តីពីទំរង់បែបបទស្នើសុំដីសម្បទានសង្គមកិច្ច (ទំរង់កិច្ចសន្យាដីសម្បទានសង្គមកិច្ច និងទំរង់ចាំបាច់ផ្សេងៗទៀត) ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ២០០ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីគោលការណ៍ណែនាំសម្រាប់អនុវត្តអនុក្រឹត្យស្តីពីដីសម្បទានសង្គមកិច្ច ។

៧៣- ដើម្បីអនុវត្តគោលនយោបាយស្តីពីការបែងចែកដីធ្លី ក្នុងឆ្នាំ២០០៧នេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ផ្តល់ដីយ៉ាងតិចចំនួន១០.០០០ហិកតា ដល់ក្រុមគ្រួសារគ្មានដីធ្លី ។ វិធានការសម្រាប់អនុវត្ត មានដូចតទៅ ÷

ក- មួយភាគនៃដីព្រៃចំនួន២០០.០០០ហិកតាដែលរាជរដ្ឋាភិបាលបានរឹបអូសមកវិញ ត្រូវបានបំរុងទុកសម្រាប់ជាផ្តល់ដីសម្បទានសង្គមកិច្ច (រង់ចាំការចូលជាធរមាន នូវសារាចរស្តីពីវិធានការទប់ស្កាត់ការកាន់កាប់ដីរដ្ឋខុសច្បាប់ ដើម្បីអនុវត្តមាត្រាទី១៨ នៃច្បាប់ភូមិបាលឆ្នាំ២០០១) ។

ខ- មួយភាគនៃដីសម្បទានសេដ្ឋកិច្ចដែលលុបកិច្ចសន្យាចោល ត្រូវបានបំរុងទុកសម្រាប់ប្រើប្រាស់ក្នុងកម្មវិធីដីសម្បទានសង្គមកិច្ច ក្នុងទំរង់នៃភាពជាដៃគូរវាងកសិឧស្សាហកម្មខ្នាតធំ និងកសិកម្មខ្នាតតូច ។ ក្រសួងរៀបចំដែនដី នគររូបនីយកម្មនិងសំណង់ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងសិក្សាទីតាំងដីទាំងនោះ ។

៧៤- ទន្ទឹមនឹងនេះ យើងក៏កត់សំគាល់នូវវឌ្ឍនភាពតិចតួច ក្នុងការរៀបចំគោលនយោបាយស្តីពីសុវត្ថិភាពសង្គម ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គឺជាស្ថាប័នរដ្ឋាភិបាលដែលទទួលខុសត្រូវលើការងារដែលពាក់ព័ន្ធនឹងសុវត្ថិភាពស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជា ។ កិច្ចប្រជុំជាច្រើនបានត្រូវរៀបចំឡើង សម្រាប់ពិភាក្សាជាមួយនឹងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។ ទន្ទឹមនេះ ក៏បានរៀបចំគំរោងសុំហិរញ្ញប្បទាន សម្រាប់គាំទ្រដល់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយក្នុងការរៀបចំនិងអនុវត្តយន្តការសម្រាប់ការធ្វើអន្តរាគមន៍ខ្នាតធំ ។ ប៉ុន្តែ កន្លងមក ដៃគូអភិវឌ្ឍន៍មិនទាន់ផ្តល់ហិរញ្ញប្បទានបានគ្រប់គ្រាន់នៅឡើយ ។ ក្នុងអំឡុងឆ្នាំ២០០៦ បន្ថែមលើការទទួលខុសត្រូវលើគ្រោះមហន្តរាយធម្មជាតិ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវ ក្នុងការទប់ស្កាត់និងការរីករាលដាលនូវជំងឺគ្រុនផ្តាសាយបក្សី ។ ការធ្វើអន្តរាគមន៍នេះបានដំណើរការល្អ លើសពីសមត្ថកិច្ចរបស់ខ្លួន ដែលទទួលខុសត្រូវត្រឹមតែការធានាសុវត្ថិភាពស្បៀងនិងអាហារូបត្ថម្ភទៅទៀត ។ ដើម្បីទប់ស្កាត់ហានិភ័យនៃជំងឺគ្រុនផ្តាសាយបក្សីដែលអាចកើនឡើង ក្រុមការងារបច្ចេកទេសចម្រុះបានបញ្ជាក់ថា ត្រូវមានចំណាត់ការបន្ទាន់ ហើយសមត្ថភាពរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក៏ត្រូវពង្រឹងបន្ថែមទៀតផងដែរ ។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏បញ្ហានេះស្ថិតហួសសមត្ថកិច្ចនិងការទទួលខុសត្រូវនៃក្រុមការងារបច្ចេកទេសចម្រុះ ។ ដោយសារសារៈសំខាន់នៃបញ្ហា ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់សុវត្ថិភាពស្បៀងនិងអាហារូបត្ថម្ភបានផ្តល់អនុសាសន៍ថា ត្រូវពិនិត្យសូចនាករតាមដានរួមគ្នានេះឡើងវិញ ហើយដាក់ឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រុមការងារបច្ចេកទេសចម្រុះផ្សេងវិញ ។

៧៥- លើសពីនេះ យើងក៏កត់សំគាល់នូវវឌ្ឍនភាពតិចតួច ក្នុងការរៀបចំប្រព័ន្ធតាមដានអាហារូបត្ថម្ភ ។ សេចក្តីព្រាងត្រូវបានរៀបចំ និងពិភាក្សាក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះសម្រាប់សុវត្ថិភាពស្បៀង និងអាហារូបត្ថម្ភ កាលពីថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ។ ក្រុមការងារស្តីពីប្រព័ន្ធតាមដានអាហារូបត្ថម្ភ បានរៀបចំកិច្ចប្រជុំជាបន្តបន្ទាប់ ។ សិក្ខាសាលាមួយត្រូវបានរៀបចំ នាក្នុងខែវិច្ឆិកា

ដោយមានការចូលរួមពីភាគីពាក់ព័ន្ធសំខាន់ៗ ។ តម្រូវការរបស់ភាគីពាក់ព័ន្ធដែលបានចូលរួម សម្រាប់រៀបចំប្រព័ន្ធតាមដានអាហារូបត្ថម្ភ សម្រាប់ត្រួតពិនិត្យសុវត្ថិភាពស្បៀង និងអាហារូបត្ថម្ភ មានទ្រង់ទ្រាយធំទូលំទូលាយ ។ ការរៀបចំប្រព័ន្ធតាមដានអាហារូបត្ថម្ភត្រូវចំណាយខ្ពស់ ។ ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់សុវត្ថិភាពស្បៀងនិងអាហារូបត្ថម្ភ ក៏បានផ្ដល់អនុសាសន៍ថា ការពង្រឹងប្រព័ន្ធតាមដានអាហារូបត្ថម្ភសម្រាប់ត្រួតពិនិត្យសុវត្ថិភាពស្បៀងនិងអាហារូបត្ថម្ភ មិនត្រូវចាត់ទុកជាសូចនាករតាមដានរួមគ្នាបន្តទៀតឡើយ ហើយត្រូវបន្តពង្រឹងយន្តការដែលមានស្រាប់ តាមរយៈវិទ្យាស្ថានស្ថិតិជាតិ និងយន្តការនានា ព្រមទាំងកិច្ចប្រឹងប្រែងដទៃទៀត សម្រាប់ពង្រឹងសុវត្ថិភាពស្បៀងនិងអាហារូបត្ថម្ភ ដែលពាក់ព័ន្ធនឹងប្រព័ន្ធតាមដានត្រួតពិនិត្យនេះ ។

**គោលដៅ** : បន្តស្តារនិងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីអនុវត្តឱ្យបានសំរេចនូវកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ

## ***សកម្មភាពចាំបាច់ :***

- សម្រេចឱ្យបាននូវកិច្ចព្រមព្រៀងស្តីពីយន្តការច្បាស់លាស់ និងតម្លាភាព ក្នុងការបែងចែកថវិកានិងការប្រើប្រាស់ថវិកា និងត្រួតពិនិត្យការជួសជុល និងថែរក្សាផ្លូវថ្នល់
- រៀបចំ និងស្នើច្បាប់ស្តីពីផ្លូវថ្នល់ជូនគណៈរដ្ឋមន្ត្រីអនុមតិ
- រៀបចំ និងស្នើច្បាប់ស្តីពីទូរគមនាគមន៍ជូនគណៈរដ្ឋមន្ត្រីអនុមតិ
- រៀបចំ និងស្នើច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកនិងអនាម័យជូនគណៈរដ្ឋមន្ត្រីអនុមតិ
- រៀបចំសេចក្តីព្រាងគោលនយោបាយជាតិ និងស្ថិតិស្តីពីថាមពលដែលមានប្រភពពីឈើ

៧៦- គណៈកម្មការអន្តរក្រសួងសាធារណៈការនិងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងតាំងពីខែកញ្ញា ឆ្នាំ២០០៦ ដើម្បីសម្របសម្រួលការថែទាំផ្លូវថ្នល់ ។ ជាលទ្ធផលជាក់ស្តែង ការថែទាំផ្លូវថ្នល់ត្រូវបានកែលំអជាបណ្តើរៗ ។ សូចនាករតាមដានរួមគ្នាជាច្រើនត្រូវបានអនុវត្ត និងសម្រេចតាមគោលដៅ ។ ទន្ទឹមនេះ ក៏មានវឌ្ឍនភាពក្នុងការអនុវត្តន៍សូចនាករខ្លះទៀត ដើម្បីឈានទៅសម្រេចតាមគោលដៅដែលបានឯកភាព ។ សមិទ្ធផលទាំងនេះរួមបញ្ចូល ការអនុមតិសេចក្តីព្រាងច្បាប់ស្តីពីទូរគមនាគមន៍ដោយគណៈរដ្ឋមន្ត្រី (ដែលបច្ចុប្បន្ននេះ បានបញ្ជូនដល់រដ្ឋសភារួចហើយ) និងការបញ្ចប់សេចក្តីព្រាងច្បាប់ផ្លូវថ្នល់ដើម្បីជូនគណៈរដ្ឋមន្ត្រី ។ សេចក្តីព្រាងច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកនិងអនាម័យ ក៏បានបញ្ជូនទៅគណៈរដ្ឋមន្ត្រីក្នុងខែមិនាឆ្នាំ២០០៥ ហើយក្រុមសង្កេតការណ៍សេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌នៃគណៈរដ្ឋមន្ត្រី បានពិនិត្យសេចក្តីព្រាងច្បាប់នេះ ។ គណៈរដ្ឋមន្ត្រីបានស្នើឱ្យក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ពិនិត្យឡើងវិញចំណុចចំនួន ១៧ នៃសេចក្តីព្រាងច្បាប់នេះ ។ បច្ចុប្បន្ន សេចក្តីព្រាងច្បាប់នេះកំពុងត្រូវបានកែសំរួលឡើងវិញ ។ ក្រុមការងារមួយត្រូវបានបង្កើត ឡើងក្នុងខែកុម្ភៈ ឆ្នាំ២០០៦ ដើម្បីចាប់ផ្តើមរៀបចំគោលនយោបាយជាតិ និងស្ថិតិស្តីពីថាមពលដែល

មានប្រភពពីឈើ ។ សេចក្ដីព្រាងគោលនយោបាយនេះនឹងត្រូវបញ្ចប់ ហើយនឹងផ្ញើជូនគណៈរដ្ឋមន្ត្រីនាត្រីមាសទី២ ឆ្នាំ២០០៧ ។

***គោលដៅ*** : កសាងសង្គមមួយដែលមានសាមគ្គីភាពរឹងមាំ ប្រព័ន្ធអប់រំ និងវប្បធម៌ជឿនលឿន គ្មានភាពក្រីក្រ អនក្ខរភាព និងជម្ងឺដង្កាត់ និងបន្តអនុវត្តផែនការនារីរតនៈ (ស្ត្រីជារតនសម្បត្តិដ៏មានតំលៃ) ។

***សកម្មភាពចាំបាច់ :***

- បង្កើនចំនួនស្ត្រីសម្រាលបុត្រដោយឆ្មបជំនាញ
- បង្កើនអត្រាចុះឈ្មោះចូលរៀននៅថ្នាក់បឋមភូមិ (សរុប និងតាមភេទ)
- បង្កើនអត្រាឡើងថ្នាក់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦
- អនុវត្តផែនការជាតិប្រឆាំងអំពើហិង្សាលើស្ត្រី
- ពង្រីកវិសាលភាពនៃការទប់ស្កាត់ ថែរក្សា និងគាំទ្រ ព្រមទាំងវិធានការកាត់បន្ថយផលប៉ះពាល់នៃជំងឺអេដស៍ និងការប្រើប្រាស់គ្រឿងញៀន

៧៧- រាជរដ្ឋាភិបាលបានសម្រេចវឌ្ឍនភាពជាច្រើន ក្នុងការអនុវត្តន៍សូចនាករតាមដានរួមគ្នា ក្នុងវិស័យសុខាភិបាល ។ សមាមាត្រស្ត្រីសម្រាលបុត្រដោយឆ្មបជំនាញ បានកើនឡើងពី៣១,៨% ក្នុងឆ្នាំ២០០០ ដល់៤៣,៨% ក្នុងឆ្នាំ២០០៥ ។ វឌ្ឍនភាពនេះបានមកពីការប្រៀបធៀបរវាងអង្កេតសុខភាពប្រជាជនកម្ពុជាក្នុងឆ្នាំ២០០០ និងឆ្នាំ២០០៥ ។ តួលេខនេះតំណាងឱ្យការសម្រាលបុត្រដោយពេទ្យរដ្ឋ និងពេទ្យឯកជន ។ ប្រព័ន្ធព័ត៌មានសុខភាពរបស់ក្រសួងសុខាភិបាលមិនទាន់អាចផ្ដល់ព័ត៌មាននេះឱ្យបានទៀងទាត់នៅឡើយទេ ។ ការកំណត់សូចនាការដោយប៉ាន់ស្មាន នឹងអាចផ្ដល់ព័ត៌មានពីវឌ្ឍនភាពនៃសូចនាករនេះយ៉ាងទៀងទាត់ ។

៧៨- អត្រាសិស្សចូលរៀនសរុបបានធ្លាក់ចុះពី៩១,៩%ដល់៩១,៣%ក្នុងចន្លោះឆ្នាំសិក្សា២០០៤-២០០៥ និង ២០០៥-២០០៦ ។ នៅខណៈដែលអត្រាសិស្សចូលរៀនសរុបបានធ្លាក់ចុះនៅថ្នាក់ជាតិ ក្នុងចន្លោះឆ្នាំ ២០០៤-២០០៥ និង២០០៥-២០០៦ អត្រាសិស្សចូលរៀនសរុបក្នុងខេត្តចំនួន១៨នៃខេត្តទាំង២៤បានកើនជាមធ្យមសម្រាប់រយៈពេលដូចគ្នា ។ នេះមានន័យថា អត្រាសិស្សចូលរៀនសរុបបានធ្លាក់ចុះចំពោះតែខេត្តចំនួន៦ប៉ុណ្ណោះ ។ អត្រាចូលរៀនសរុបរបស់សិស្សស្រី បានធ្លាក់ចុះពី៩០,៧%ដល់៨៩,៧% ទោះបីជាអត្រាបច្ចុប្បន្នមានភាពប្រសើរជាង បើប្រៀបធៀបទៅនឹងអត្រាចូលរៀនសរុប ក្នុងឆ្នាំ២០០៣-២០០៤ ដែលមានត្រឹមតែ៩០,១% នៃអត្រាសិស្សចូលរៀនសរុប និង៨៨,៦%នៃអត្រាចូលរៀនសរុបរបស់សិស្សស្រី ។ ក្រៅពីនេះ អត្រាចូលរៀនសរុបរបស់សិស្សប្រុសបានកើនឡើងពី៩២,១% ដល់ ៩៣% ហើយអត្រាចូលរៀនសរុបរបស់សិស្សប្រុស នៅសាលាបឋមសិក្សា ក៏បានកើនឡើងផងដែរ ពី១១៩,៧%ដល់១២៤% ដែលបញ្ជាក់អំពីកំណើននៃការចុះឈ្មោះចូលរៀនរបស់កុមារ នៅបឋម សិក្សា ។ អត្រាឡើងថ្នាក់ពីថ្នាក់ទី១ដល់ថ្នាក់ទី៦ របស់សិស្សប្រុសក៏បានធ្លាក់ចុះពី៥២,៦% មក៤៨% ក្នុងចន្លោះឆ្នាំសិក្សា២០០៤-២០០៥ និង២០០៥-២០០៦ ។ ការធ្លាក់ចុះនៃអត្រាទូទៅក្នុងកំរិតថ្នាក់ជាតិ

អាចបណ្តាលមកពីការធ្លាក់ចុះនៅតាមបណ្តាខេត្តមួយចំនួន (ដូចជា កំពុងស្ពឺ ក្រុងកែប ក្រចេះ និង ក្រុងព្រះសីហនុ) ។ ទន្ទឹមនឹងនេះដែរ អត្រាឡើងថ្នាក់ពីថ្នាក់ទី១ដល់ថ្នាក់ទី៦របស់សិស្សស្រី បានធ្លាក់ចុះពី៥១,៧% មកត្រឹម៤៧,៥% ។ ដូចនេះ ត្រូវមានកិច្ចអន្តរាគមន៍យ៉ាងម៉ត់ចត់ក្នុងតំបន់ពិសេសមួយចំនួន ដើម្បីបង្កើនអត្រាសិស្សចូលរៀនសរុប និងអត្រាឡើងថ្នាក់ ។

៧៩- មូលហេតុចំបងនៃអត្រាធ្លាក់ចុះនេះ គឺការកើនឡើងនៃអត្រាត្រួតថ្នាក់ក្នុងឆ្នាំមុន ។ ទាំងនេះគឺជាបញ្ហាដែលក្រសួងអប់រំ យុវជន និងកីឡា ត្រូវយកចិត្តទុកដាក់ខ្ពស់ ក្នុងការត្រួតពិនិត្យឡើងវិញលើគោលនយោបាយនាពេលខាងមុខ ។ ការត្រួតពិនិត្យឡើងវិញលើគោលនយោបាយនឹងផ្អែកលើការសិក្សាដែលមានស្រាប់ និងទិន្នន័យអង្កេតផ្សេងៗទៀត ដើម្បីកំណត់យុទ្ធសាស្ត្រច្បាស់លាស់ សម្រាប់ទប់ស្កាត់ការបោះបង់ចោលសាលា និងកាត់បន្ថយការរៀនត្រួតថ្នាក់ឱ្យបានអប្បបរមា ដោយសង្ឃឹមថា យុទ្ធសាស្ត្រទាំងពីរនេះនឹងជួយកែលំអអត្រាប្រលងជាប់ពីថ្នាក់ទី១ដល់ថ្នាក់ទី៦ ។ យុទ្ធសាស្ត្រសំខាន់ៗសម្រាប់អន្តរាគមន៍រួមមានៈ ការអនុវត្តន៍ឱ្យបានឆាប់នូវកម្មវិធីពង្រឹងកុមារ និងកម្មវិធីត្រៀមជាស្រេចរបស់សាលា ការបញ្ឈប់ការបង់លុយតាមសាលា ការចុះឈ្មោះចូលរៀនត្រឹមត្រូវតាមអាយុនៅថ្នាក់ទី១ អនុវត្តការបង្រៀនឱ្យបានច្រើនថ្នាក់ និងអនុវត្តកម្មវិធីបង្រៀនមួយដែលអាចបត់បែនបាន ស្របតាមលក្ខណៈនៃតំបន់ដាច់ស្រយាល និងសហគមន៍ជនជាតិដើមភាគតិច ពង្រីកកម្មវិធីអាហារូបករណ៍ សម្រាប់សិស្សក្រីក្រ ពិសេសសម្រាប់សិស្សស្រីថ្នាក់ទី៥-៦ ចែកចាយសៀវភៅសិក្សាឱ្យបានទៀងទាត់ ការផ្តល់ទឹកស្អាតនិងបង្គន់អនាម័យ និងពង្រីកឱ្យបានដល់មធ្យមសិក្សាកម្រិត១ ។ គណៈរដ្ឋមន្ត្រីបានអនុមតិសេចក្តីព្រាងច្បាប់ស្តីពីការអប់រំ នាថ្ងៃទី០៩ ខែមិនា ឆ្នាំ២០០៧ និងបានស្នើជូនរដ្ឋសភាដើម្បី អនុមតិ ។

៨០- ផែនការជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ ត្រូវបានរៀបចំបញ្ចប់ ហើយបច្ចុប្បន្ន កំពុងស្ថិតក្នុងដំណើរការពិភាក្សា ដោយគ្រោងបញ្ចប់នៅឆ្នាំ២០០៧ នេះ ។

៨១- វិធានការចំបងៗត្រូវបានអនុវត្ត ដើម្បីពង្រីកវិសាលភាពនៃការទប់ស្កាត់ ការថែរក្សានិងគាំទ្រ ព្រមទាំងវិធានការកាត់បន្ថយផលប៉ះពាល់នៃជំងឺអេដស៍ និងការប្រើប្រាស់គ្រឿងញៀន ។ វិធានការទាំង នេះរួមមាន ÷

ក- រៀបចំក្របខ័ណ្ឌជាតិសម្រាប់កុមារកំព្រានិងកុមារគ្មានទីពឹង ដែលគ្រោងបញ្ចប់ក្នុងត្រីមាសទី១ ឆ្នាំ២០០៧ ។

ខ- កំពុងរៀបចំគោលការណ៍ណែនាំតាមបែបវិមជ្ឈការ សម្រាប់ឆ្លើយតបនឹងបញ្ហាអេដស៍ និងឥទ្ធិពលនៃផលប៉ះពាល់ក្នុងការកាត់បន្ថយការរីករាលដាលនៃជំងឺអេដស៍ ។

គ- កម្ពុជាមានបំណងចូលរួមកិច្ចប្រជុំ GFATM លើកទី៧ ដើម្បីពង្រីកវិសាលភាពនៃការទប់ ស្កាត់ការថែរក្សានិងគាំទ្រ ព្រមទាំងវិធានការកាត់បន្ថយផលប៉ះពាល់នៃជំងឺអេដស៍ និងការប្រើប្រាស់គ្រឿងញៀន ។

**គោលដៅ** : ធានាការប្រើប្រាស់ប្រកបដោយចីរភាពនូវធនធានធម្មជាតិ ដោយគិតគូរអំពីជីវភាព និងតម្រូវការរបស់សហគមន៍ជនបទ

***សកម្មភាពចាំបាច់ :***

- រៀបចំ និងអនុវត្តកម្មវិធីជាតិគ្រប់គ្រងព្រៃឈើ ដើម្បី ÷
  - ក- ពង្រឹងការអនុវត្តន៍ច្បាប់ព្រៃឈើ ពិសេសការលុបបំបាត់ការដុតបំផ្លាញដីព្រៃឈើ និងការទន្ទ្រានយកដីព្រៃ
  - ខ- ធ្វើសនិទានកម្ម និងចំណាត់ថ្នាក់ដីព្រៃឈើជាតិឡើងវិញ ដើម្បីធានាការប្រើប្រាស់ប្រកបដោយចីរភាព ដោយបន្តកំណត់ព្រំដែនដីព្រៃ និងតំបន់ព្រៃការពារ
  - គ- បញ្ចប់ការវាយតម្លៃតំបន់គ្របដណ្តប់ដោយព្រៃឈើ ឆ្នាំ២០០៥/២០០៦
  - ឃ- អនុវត្តកម្មវិធីសហគមន៍ព្រៃឈើ និងបន្តបង្កើតសហគមន៍ព្រៃឈើ
  - ង- អនុវត្តការកសាងសមត្ថភាពសម្រាប់កម្មវិធីខាងវិស័យព្រៃឈើ និងការដាំកូនឈើ សំរាប់បំរើឱ្យបុព្វហេតុសេដ្ឋកិច្ច និងសង្គមកិច្ច
  - ច- ការត្រួតពិនិត្យឯករាជ្យ ក្នុងវិស័យព្រៃឈើ (លុះត្រាតែមានជំនួយឥតសំណងពីដៃគូអភិវឌ្ឍន៍)

- ពង្រឹងតម្លាភាព ដោយផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពរបស់រាជរដ្ឋាភិបាល រួមមានព័ត៌មានស្តីពីដីសម្បទាន សម្រាប់ធនធានរ៉ែ និងតំបន់ហ៊ីកហ្វីនរបស់កងទ័ព ព័ត៌មានអំពីសកម្មភាពរបស់ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល ក្នុងគេហទំព័ររបស់ក្រុមការងារព្រៃឈើ
- រៀបចំ និងអនុវត្តគោលនយោបាយគ្រប់គ្រងដីធ្លី និងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធ ដើម្បីធានាការប្រើប្រាស់ដីធ្លីប្រកបដោយចីរភាព
- ពង្រីកវិសាលភាពនៃការចុះបញ្ជីដីធ្លី ÷
  - ក- ផ្តល់ប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លី ឱ្យបាន៣០០.០០០ ក្នុងឆ្នាំ២០០៦
  - ខ- បង្កើនករណីដោះស្រាយជំលោះដីធ្លីដោយគណៈកម្មាធិការសុរិយោដី ដោយត្រូវដោះស្រាយឱ្យចប់៤៥០ករណី ក្នុង៨០០ករណី ក្នុងឆ្នាំ២០០៦
  - គ- កែប្រែរចនាសម្ព័ន្ធនៃតម្លៃសំរាប់ផ្តល់សេវាចុះបញ្ជីដីធ្លី ដោយធ្វើការផ្សព្វផ្សាយអំពីតំលៃ និងពន្ធប្រថាប់ត្រាក្នុងការចុះបញ្ជីដីធ្លី
  - ឃ- រៀបចំផែនទីដីរដ្ឋក្នុងស្រុកចំនួន៥ និងផ្សព្វផ្សាយលទ្ធផលជាសាធារណៈ

៨២- រាជរដ្ឋាភិបាលបានសំរេចនូវវឌ្ឍនភាព ក្នុងការអនុវត្តន៍ឱ្យបានតាមគោលដៅនៃសូចនាករតាមដានរួម គ្នានៅក្នុងវិស័យព្រៃឈើ លើកលែងតែការត្រួតពិនិត្យដោយឯករាជ្យក្នុងវិស័យព្រៃឈើដោយគ្មានគាំទ្រខាងហិរញ្ញប្បទាន ។ វឌ្ឍនភាពទាំងនោះ រួមមាន ÷

- ពង្រឹងការអនុវត្តន៍ច្បាប់ព្រៃឈើ : ជាលទ្ធផល រាជរដ្ឋាភិបាលបាននឹងកំពុងរឹបអូសមកវិញ នូវដីព្រៃឈើចំនួន២០៧.៩៦០ហ.ត ពីក្រុមកាន់កាប់ដីខុសច្បាប់ ដោយរួមបញ្ចូលដីសម្បទានព្រៃ

ឈើចំនួន ៩.៣២៤ហ.ត ជាតំបន់ព្រៃលិចទឹក ។ ក្នុងឆ្នាំ២០០៦ បទល្មើសចំនួន៨៩៩ករណី ត្រូវបានរាយការណ៍ដោយអង្គភាពតាមដានបទល្មើសនៃរដ្ឋបាលព្រៃឈើ ។

- ការកំណត់ដែនព្រៃឈើ : ការកំណត់ដែនព្រៃឈើកំពុងបន្តអនុវត្ត ក្នុងតំបន់ដែនរដ្ឋបាលព្រៃឈើចំនួន១៥ ។ ផែនទីសម្រាប់តំបន់អភិរក្សចំនួន១៦ (សួនឧទ្យានជាតិ និងតំបន់អភិរក្ស សត្វព្រៃ) បាននិងកំពុងរៀបចំបង្កើត ហើយការងារស្តីពីការកំណត់ព្រំដែនតំបន់ទាំងនោះ ក៏ បាន និងកំពុងអនុវត្តផងដែរ ដោយរៀបចំឱ្យមានការដាក់ផ្លាកសញ្ញា ។ ការកំណត់ដែនដីព្រៃឈើត្រូវបានធ្វើឡើងក្នុងខេត្តសាកល្បងមួយចំនួន (ដែនដីព្រៃឈើចំនួន៣២០.០០០ហ.ត និងប្រវែង៦០០គ.ម ត្រូវបានកំណត់) ហើយគោលការណ៍ណែនាំស្តីពីការកំណត់ដែនដីព្រៃរបស់រដ្ឋបាលព្រៃឈើ ត្រូវបានរៀបចំឡើង និងសាកល្បងអនុវត្តនៅក្នុងឆ្នាំ២០០៧ ។
- ការអង្កេត និងវាយតំលៃតំបន់ព្រៃឈើ : ការងារស្តីពីការបកស្រាយ និងរៀបចំចំណាត់ថ្នាក់ប្រភេទព្រៃឈើ ត្រូវបានអនុវត្តបញ្ចប់ ។ ក្រុមហ៊ុន GRAS A/S កំពុងត្រួតពិនិត្យឡើងវិញ និងកែតំរូវទិន្នន័យអង្កេតខាងលើ ដែលការងារនេះនឹងត្រូវបញ្ចប់ក្នុងខែឧសភា ឆ្នាំ២០០៧នេះ ។
- កម្មវិធីសហគមន៍ព្រៃឈើ : គោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើត្រូវបានអនុមតិ ។ បានបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ។ មានការព្រមព្រៀងគាំទ្រចំពោះសហគមន៍ព្រៃឈើ ។ រីឯសកម្មភាពក៏ត្រូវបានយកចិត្តទុកដាក់អនុវត្តក្នុងតំបន់មួយចំនួន ។ គំរោងស្នើសុំតូចៗមួយចំនួនបានត្រូវរៀបចំ ហើយរង់ចាំការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ ។
- កម្មវិធីពង្រឹងសមត្ថភាព និងការដាំកូនឈើ : ការពង្រឹងសមត្ថភាពកំពុងអនុវត្តបន្ត ហើយការដាំកូនឈើ ត្រូវបានអនុវត្តលើផ្ទៃដីចំនួន ៣.៥០០ ហ.ត ។
- បានបង្កើតក្រុមការងារសម្រាប់កម្មវិធីព្រៃឈើជាតិ ហើយកំពុងជ្រើសរើសអ្នកសម្របសម្រួលថ្នាក់ជាតិម្នាក់ (កំពុងផ្សព្វផ្សាយជ្រើសរើស)។
- គេហទំព័ររបស់ក្រុមការងារសម្រាប់កំណែទម្រង់ព្រៃឈើបានដំណើរការល្អ ដោយត្រូវបានធ្វើ បច្ចុប្បន្នភាពជាប្រចាំ ។

៨៣- វិធានការជាច្រើនត្រូវបានអនុវត្ត ដើម្បីទទួលនិងបែងចែកព័ត៌មានស្តីពីដីសម្បទានសម្រាប់ធនធានរ៉ែ និងតំបន់ហ៊ីកហ៊ីនកងទ័ព ។ វិធានការទាំងនោះរួមមាន ÷

- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានផ្សព្វផ្សាយ និងបែងចែកព័ត៌មានស្តីពីដីសម្បទានសម្រាប់ធនធានរ៉ែ ។
- ក្រសួងការពារជាតិបានបញ្ជូនតំណាងធ្វើជាសមាជិកនៃក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់ការងារព្រៃឈើ និងបរិស្ថាន ។ ក្រសួងនេះក៏បានផ្សព្វផ្សាយព័ត៌មានស្តីពីតំបន់ហ៊ីកហ៊ីនកងទ័ពនៅក្នុងកិច្ចប្រជុំក្រុមបច្ចេកទេសចម្រុះផងដែរ ។

- ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ បានស្នើសុំឱ្យក្រសួងបរិស្ថាន ចែករំលែកព័ត៌មានស្ដីអំពីទិន្នន័យ GIS ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចែករំលែកព័ត៌មានស្ដីពីដីសម្បទានសេដ្ឋកិច្ច ។

៨៤- រាជរដ្ឋាភិបាលបានចាត់វិធានការជាច្រើន សម្រាប់រៀបចំ និងអនុវត្តគោលនយោបាយគ្រប់គ្រងដីធ្លី និងបទបញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ដើម្បីជំរុញការប្រើប្រាស់ដីធ្លីប្រកបដោយចីរភាព ។ អនុក្រឹត្យស្ដីពីការគ្រប់គ្រងដីរដ្ឋ ត្រូវបានរៀបចំ ហើយបច្ចុប្បន្ន កំពុងអនុវត្តតាមរយៈលិខិតបទដ្ឋានសម្រាប់អនុវត្តអនុក្រឹត្យនេះ ។

៨៥- សិក្ខាសាលាជាច្រើនត្រូវបានរៀបចំឡើង សម្រាប់បែងចែកព័ត៌មានស្ដីពីដំណើរការនៃការកំណត់អត្តសញ្ញាណ ការរៀបចំ និងការកំណត់ផែនទី ព្រមទាំងការរៀបចំចំណាត់ថ្នាក់ដីរដ្ឋ និងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធផ្សេងៗទៀត ។ សិក្ខាសាលាទាំងនេះចូលរួមដោយអភិបាលខេត្ត-ក្រុង បណ្ដាក្រសួង-ស្ថាប័ន មន្ត្រីបំរើការងារនៅខុទ្ទកាល័យអភិបាលខេត្ត-ក្រុង និងប្រធាន និងអនុប្រធាននាយកដ្ឋាននៃនាយកដ្ឋានគ្រប់គ្រងដីធ្លី នគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ។ នៅថ្នាក់ខេត្ត សិក្ខាសាលាត្រូវបានរៀបចំឡើងសម្រាប់មន្ត្រីមកពីមន្ទីរខេត្តពាក់ព័ន្ធ អជ្ញាធរស្រុក មន្ត្រីឃុំ-សង្កាត់នៃសមាជិកគ្រប់គ្រងដីធ្លី និងសុរិយោដី ក៏ដូចជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងខេត្តចំនួន ១៣ (ខេត្តតាកែវ ខេត្តកំពង់ចាម ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកណ្ដាល ខេត្តព្រះវិហារ ខេត្តកំពត ខេត្ត កំពង់ធំ ខេត្តព្រៃវែង ខេត្តពោធិសាត់ ខេត្តរតនគិរី ខេត្តមណ្ឌលគិរី និងក្រុងកែប) ។

៨៦- តាមទិដ្ឋភាពបច្ចេកទេស ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ បានសហការជាមួយនឹងដៃគូពាក់ព័ន្ធទាំងអស់ ដើម្បីបង្កើនល្បឿន ÷
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ស្រុក-ខ័ណ្ឌក្នុងស្រុក-ខ័ណ្ឌចំនួន១៥ គឺ ÷ ស្រុកកំពង់ត្រាច ស្រុកពញាក្រែក ស្រុកស្មោង ស្រុកភ្នំព្រែក ខ័ណ្ឌមានជ័យ ស្រុកពាមរ ស្រុកចន្ទ្រា ស្រុកស្អាង ស្រុកស្ទឹងត្រែង ស្រុកកោះធំ ស្រុកកែវសីមា ស្រុកជាំក្សាន ស្រុកអូរជ្រៅ និងស្រុកបរិបូណ៌ ។
- ផែនការប្រើប្រាស់ដីទីក្រុង ក្នុងស្រុក-ខ័ណ្ឌចំនួន១៣ គឺ ÷ អ្នកលឿង បាវិត កំពង់ត្រាច ក្រចេះ ឆ្លូង ស្ទឹងត្រង់ អន្លង់វែង ប៉ោយប៉ែត និមត្តិ មណ្ឌលសីមា ច្បារមន សំរោងទង និងខ័ណ្ឌ ស្ទឹងហាវ ។
- ផែនការប្រើប្រាស់ដីធ្លីតាមរយៈការចូលរួម ក្នុងក្របខ័ណ្ឌនៃគំរោងគ្រប់គ្រងធនធានធម្មជាតិនៅតាមសហគមន៍ និងកម្មវិធីសិលាក្នុងភូមិចំនួន២៨៤នៃឃុំចំនួន៤៥ រួមទាំងផែនទីបឋមស្ដីពីការប្រើប្រាស់ដីធ្លីក្នុងឃុំចំនួន៣៤៥ ។
- វគ្គបណ្ដុះបណ្ដាលស្ដីពីគំនូរសម្រាប់ផែនទីប្រើប្រាស់ដីក្នុងឃុំចំនួន៥៦ ។

៨៧- ចំពោះការចុះបញ្ជីដីធ្លី ការដោះស្រាយជម្លោះ ការកំណត់ថ្លៃឈ្នួលដី ការវាយតម្លៃដីធ្លី និងការធ្វើផែនទីដីរដ្ឋ វឌ្ឍនភាពមានដូចខាងក្រោម ÷

- *ផ្តល់ប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីយ៉ាងហោចណាស់ចំនួន៣០០.០០០ហ.ត* : ក្នុងឆ្នាំ២០០៦ បានរៀបចំប័ណ្ណកម្មសិទ្ធិសម្រាប់៣១៨.២៥៥ក្បាលដីរួចហើយ ។ ក្នុងចំនួននោះ ប័ណ្ណកម្មសិទ្ធិចំនួន ២៨២.២៧៦ បានផ្តល់ជូនប្រជាពលរដ្ឋ ហើយប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីដែលនៅសេសសល់ចំនួន៣៥.៩៧៩ បានត្រូវចុះហត្ថលេខារួចជាស្រេច ហើយកំពុងរៀបចំផ្តល់ជូនប្រជាជន ។
- *បង្កើនការដោះស្រាយជំលោះដីធ្លីឱ្យបានយ៉ាងតិច ចំនួន៤៥០ករណីនៃជំលោះដីធ្លីសរុបចំនួន ៨០០ករណីក្នុងឆ្នាំ២០០៦ តាមរយៈគណៈកម្មាធិការសុរិយោដី* : ជំលោះដីធ្លីចំនួន២៩១ករណី ត្រូវបានដោះស្រាយប្រកបដោយជោគជ័យ ឬស្មើនឹង៦៤,៦៧%នៃចំនួនជំលោះដីធ្លី ដែលបានកំណត់ ដែលក្នុងនោះក៏មានភាគីជំលោះខ្លះចង់ដោះស្រាយជំលោះហើយភាគីជំលោះខ្លះទៀតមិនចង់ដោះស្រាយជំលោះទេ ។ ចាប់ពីពេលបង្កើតគណៈកម្មាធិការសុរិយោដីរួចមក ករណីជំលោះដីធ្លី ដែលដោះស្រាយបានជោគជ័យ មានចំនួនរហូតដល់១.២៨៦ករណី សម្រាប់ ៦.៦៤១គ្រួសារ និងដីធ្លីមានជំលោះចំនួន២.៣៩៥ហត ។ ជាមួយនឹងចំនួនករណីជំលោះដីធ្លី ដែលបានដោះស្រាយតាមរយៈដំណើរការនៃការចុះបញ្ជីដីជាប្រព័ន្ធ ចំនួនករណីជំលោះដីធ្លី ដែលបានដោះស្រាយរួចហើយមានចំនួន២.៩៧៩ករណី សម្រាប់គ្រួសារចំនួនជាង១០.០០០ គ្រួសារ ។
- *ការកែប្រែរចនាសម្ព័ន្ធតម្លៃសម្រាប់ការចុះបញ្ជីដីធ្លី* : ក្របខ័ណ្ឌច្បាប់ខាងក្រោមត្រូវបានអនុមតិ និងផ្សព្វផ្សាយ : ១- គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងការប្រមូលតម្លៃសម្រាប់ការចុះបញ្ជី ដីធ្លី ។ ២- សេចក្តីសំរេចលេខ៥១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការផ្តល់សេវាចុះបញ្ជីដីធ្លី ។ ៣- សេចក្តីសំរេចលេខ៤២ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៦ ស្តីពីការបង្កើតយន្តការទទួលពាក្យបណ្តឹង និងដោះស្រាយជំលោះដីធ្លី សំរាប់គំរោងរដ្ឋបាលនិងការគ្រប់គ្រងដីធ្លី ។ និង៤- សេចក្តីសំរេចលេខ៤៣ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីក្រមសីលធមិសំរាប់មន្ត្រីបំរើការងារចុះបញ្ជីដីធ្លីក្នុងគំរោងរដ្ឋបាល និងការគ្រប់គ្រងដីធ្លី ។
- ដើម្បីធានាតម្លាភាពស្តីពីពន្ធប្រើប្រាស់ដីធ្លី ក្រុមប្រឹក្សាគោលនយោបាយដីធ្លីកំពុងរៀបចំសេចក្តីព្រាងគោលនយោបាយស្តីពីការវាយតំលៃដីធ្លី (ក្រុមការងារអន្តរក្រសួងមួយត្រូវបានបង្កើត ឡើង) ។
- ទន្ទឹមនេះ ក៏មានវឌ្ឍនភាពក្នុងការរៀបចំផែនទីដីរដ្ឋនៅស្រុកចំនួន៥ ។

**គោលដៅ** : បង្កើតបរិស្ថានអំណោយផលសម្រាប់កិច្ចអភិវឌ្ឍន៍វិស័យឯកជន

**សកម្មភាពចាំបាច់** :

- បញ្ចប់សេចក្តីព្រាងច្បាប់សម្បទានសម្រាប់ស្នើជូនរដ្ឋសភា ។ គ្រប់គម្រោងថ្មីស្តីពីការចូលរួមរបស់វិស័យឯកជនក្នុងហេដ្ឋារចនាសម្ព័ន្ធ ត្រូវអនុវត្តតាមគោលការណ៍តម្លាភាពនិងគណនេយ្យភាព ដូចមានក្នុងសេចក្តីព្រាងច្បាប់ ។
- ពង្រឹងការសម្រួលពាណិជ្ជកម្ម ដោយ ÷

  ក- អនុមតិ និងប្រើប្រាស់ឯកសាររដ្ឋបាលតែមួយ តាមប្រព័ន្ធ Asycuda

ខ- អនុមតិ និងផ្សព្វផ្សាយជាសាធារណៈស្តីពីកិច្ចព្រមព្រៀងរវាងស្ថាប័នពាក់ព័ន្ធនឹងនីតិវិធី និងគោលការណ៍ស្តីពីការត្រួតពិនិត្យ និងការអនុញ្ញាតការនាំចេញ- នាំចូលទំនិញ

គ- អនុវត្តសាកល្បង «ច្រកចេញ- ចូលតែមួយ» ដើម្បីសម្រួលពាណិជ្ជកម្ម នៅកំពង់ផែក្រុងព្រះសីហនុ

ឃ- រៀបចំ និងអនុមតិអនុក្រឹត្យស្តីពីការសម្រួលពាណិជ្ជកម្មតាមរយៈអភិក្រមគ្រប់គ្រងហានិភ័យក្នុងការត្រួតពិនិត្យ និងការអនុញ្ញាតការនាំចេញ- នាំចូលទំនិញ ដោយបញ្ជាក់ពីតួនាទីឈានមុខរបស់ទីចាត់ការគយនិងរដ្ឋាករ ក្នុងការត្រួតពិនិត្យប្រភេទទំនិញ (ត្រួតពិនិត្យលើឯកសារ ត្រួតពិនិត្យរូបវ័ន្ត និងដោយឧបករណ៍អេឡិចត្រូនិច)

- រៀបចំ និងអនុវត្តនីតិវិធី និងតម្រូវការឯកសារនានា បញ្ជាក់អំពីនីតិវិធីក្នុងការកែប្រែលក្ខន្តិកៈក្រុម ហ៊ុន បញ្ជាក់អំពីតម្រូវការអប្បបរមាសំរាប់ក្រុមហ៊ុនសាជីវកម្ម ដោយផ្អែកលើច្បាប់ស្តីពីក្រុមហ៊ុន ពាណិជ្ជកម្ម បញ្ជាក់ពីនីតិវិធីស្តីពី ការប្រកាសប្រចាំឆ្នាំ និងនីតិវិធីសម្រាប់ការធ្វើវិមជ្ឈការនៃការ ចុះបញ្ជីពាណិជ្ជកម្ម ព្រមទាំងសម្រួលការផ្តល់អាជ្ញាប័ណ្ណដល់សហគ្រាសធុនតូច និងមធ្យម ។
- ពង្រឹងនិងសម្រួលរាល់តម្រូវការស្តីពីការផ្តល់អជ្ញាប័ណ្ណដល់សហគ្រាសធុនតូច និងមធ្យម ។
- អនុមតិ និងអនុវត្តឱ្យបានពេញលេញ នូវយន្តការ «ច្រកចេញចូលតែមួយ» សម្រាប់តំបន់សេដ្ឋកិច្ចពិសេស ឱ្យបានស្របជាមួយនឹងកំណែទម្រង់ស្តីពីការសម្រួលពាណិជ្ជកម្ម ដើម្បីកាត់បន្ថយពេល វេលា និងចំណាយក្នុងការជំរះបញ្ជីពាណិជ្ជកម្ម រួមមានការអនុវត្តន៍ប្រព័ន្ធឯកសាររដ្ឋបាលតែមួយ និងអភិក្រមគ្រប់គ្រងហានិភ័យក្នុងការត្រួតពិនិត្យការនាំចូល- នាំចេញទំនិញ ។

៨៨- រាជរដ្ឋាភិបាលបានសំរេចវឌ្ឍនភាពជាច្រើន ក្នុងការសម្រេចគោលដៅនៃសូចនាករតាមដានរួមគ្នាស្តីពីការពង្រឹងវិស័យឯកជន ។ សេចក្តីព្រាងច្បាប់សម្បទានត្រូវបានរៀបចំ និងបានបញ្ជូនទៅសភារួចហើយ ។ ឯកសាររដ្ឋបាលតែមួយ និងឯកសារពន្យល់បានត្រូវអនុមតិដោយគណៈកម្មការចម្រុះ ។ ការសម្រួលពាណិជ្ជកម្ម តាមរយៈអភិក្រមគ្រប់គ្រងហានិភ័យក្នុងការត្រួតពិនិត្យ និងការអនុញ្ញាតការនាំចេញ- នាំចូលទំនិញ ត្រូវបានដាក់ឱ្យអនុវត្តតាមរយៈអនុក្រឹត្យ លេខ ២១ ចុះថ្ងៃទី០១ ខែមិនា ឆ្នាំ២០០៦ ។ កិច្ចព្រមព្រៀងរដ្ឋបាលអន្តរក្រសួង និងបទដ្ឋាននិងនីតិវិធីប្រតិបត្តិការក្នុងចំណោមស្ថាប័នពាក់ព័ន្ធ ស្តីពីនីតិវិធីនិងគោលការណ៍ណែនាំសម្រាប់ការត្រួតពិនិត្យ និងការអនុញ្ញាតឱ្យនាំចេញ- នាំចូលទំនិញ កំពុងត្រូវបានអនុវត្តបន្ទាប់ពីបានជ្រើសរើសក្រុមហ៊ុនផ្តល់ប្រឹក្សា ។ ទន្ទឹមនេះ ក៏មានភាពយឺតយ៉ាវខ្លះៗ ក្នុងការអនុវត្តន៍សាកល្បងយន្តការ «ច្រកចេញ- ចូលតែមួយ» សម្រាប់សម្រួលពាណិជ្ជកម្មនៅកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ។ រាជរដ្ឋាភិបាលបានសម្រេចឱ្យអនុវត្តយន្តការ «ច្រកចេញ- ចូលតែមួយ» ស្របតាមប្រតិទិនរបស់អាស៊ាន ឱ្យបានមុនឆ្នាំ២០១២ ។

៨៩- វិធានការជាច្រើនត្រូវបានអនុវត្ត សម្រាប់រៀបចំ និងអនុមតិបទបញ្ញត្តិនានាដែលពាក់ព័ន្ធនឹងនីតិវិធីចុះបញ្ជី និងតំរូវការឯកសារនានា នីតិវិធីសម្រាប់ការធ្វើវិសោធនកម្មមាត្រានៃច្បាប់សាជីវកម្ម ការបញ្ជាក់ពីតំរូវការអប្បបរមាសម្រាប់មាត្រានៃច្បាប់សាជីវកម្ម ដោយផ្អែកតាមច្បាប់ស្តីពីសហគ្រាស

ពាណិជ្ជកម្ម នីតិវិធីសម្រាប់ការប្រកាសប្រចាំឆ្នាំ និងការបង្កើតនីតិវិធីសម្រាប់វិមជ្ឈការនៃការចុះបញ្ជីការពាណិជ្ជកម្ម ។ វិធានការទាំងនោះរួមមាន ÷

- សេចក្តីប្រកាសលេខ ២១០៦ MOC/LAD ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០០៦ ដែលពាក់ព័ន្ធនឹងការអនុវត្តន៍ផែនការនៃកំណែទំរង់ក្រុមហ៊ុនសាជីវកម្ម និងវិមជ្ឈការនៃការចុះបញ្ជីការពាណិជ្ជកម្ម ។
- ប្រកាសលេខ ១២០ MOC/SM2006 ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៦ ដែលបញ្ជាក់អំពីនីតិវិធីនៃការធ្វើវិសោធនកម្មមាត្រានៃច្បាប់សាជីវកម្ម ។
- សេចក្តីប្រកាសលេខ ១៤១៥ MOC/SM2006 ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៦ ដែលបញ្ជាក់អំពីតំរូវការចាំបាច់ចំនួន ១៣ សម្រាប់មាត្រានៃសាជីវកម្ម ។
- ប្រកាសលេខ ១៤៩ MOC/SM2006 ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៦ ដែលបញ្ជាក់ពីតំរូវការ និងនីតិវិធីសម្រាប់ការធ្វើសេចក្តីប្រកាសប្រចាំឆ្នាំ ។

៩០- រាជរដ្ឋាភិបាលសំរេចបានវឌ្ឍនភាពជាច្រើនក្នុងផ្នែកសហគ្រាសធុនតូច និងមធ្យម ។ ក្នុងក្របខ័ណ្ឌស្តីពីការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ដែលបានអនុមតិដោយរាជរដ្ឋាភិបាលនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៥ អនុគណៈកម្មការសហគ្រាសធុនតូច និងមធ្យម បានផ្តល់សិទ្ធិឱ្យលេខាធិការដ្ឋានសហគ្រាសធុនតូច និងមធ្យម សម្រាប់ដឹកនាំការរៀបចំយន្តការត្រួតពិនិត្យការផ្តល់អាជ្ញាប័ណ្ណ ។ អនុគណៈកម្មការសហគ្រាសធុនតូច និងមធ្យម បានអនុមតិផែនការសកម្មភាពដើម្បីបង្កើតយន្តការត្រួតពិនិត្យការផ្តល់អាជ្ញាប័ណ្ណ និងបទបញ្ញត្តិណែនាំសម្រាប់ត្រួតពិនិត្យ នាថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៦ សម្រាប់ត្រួតពិនិត្យការផ្តល់អាជ្ញាប័ណ្ណ ។ ឯកសារទាំងនេះត្រូវបានអនុមតិដោយរាជរដ្ឋាភិបាល នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៦ ។ លក្ខខ័ណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណដែលមានចែងក្នុងផែនការនេះ ត្រូវអនុវត្តចំពោះគ្រប់ធុរៈកិច្ចទាំងអស់ មុនពេលចាប់ផ្តើមអនុវត្តសកម្មភាពរបស់ខ្លួន ។ បទបញ្ញត្តិណែនាំស្តីពីការត្រួតពិនិត្យការផ្តល់អាជ្ញាប័ណ្ណ គឺជាឧបករណ៍មួយដែលបានកំណត់អំពីលក្ខខ័ណ្ឌវិនិច្ឆ័យ និងវិធីសាស្ត្រសម្រាប់ត្រួតពិនិត្យការផ្តល់អាជ្ញាប័ណ្ណ ។ អនុគណៈកម្មាការសហគ្រាសធុនតូច និងមធ្យម ក៏បានរៀបចំយន្តការសម្រាប់ដោះស្រាយជំលោះដែលបណ្តាលមកពីការផ្តល់អាជ្ញាប័ណ្ណ និងការត្រួតពិនិត្យនេះ ព្រមទាំងត្រួតពិនិត្យលើការសំរេចចិត្តសម្រាប់ធុរៈកិច្ចទាំងអស់ ។

៩១- «ច្រកចេញ-ចូលតែមួយ» ក្នុងតំបន់សេដ្ឋកិច្ចពិសេស ត្រូវបានអនុវត្តនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស Manhattan នៅបាវិត ខេត្តស្វាយរៀង ដោយមានតំណាងស្ថាប័នចំនួន៥ធ្វើការក្នុងបន្ទប់រួមតែមួយ គឺ ÷ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា CED កាំកុងត្រូល ក្រសួងពាណិជ្ជកម្ម និងក្រសួងការងារ) ។ ច្រកចេញ-ចូលតែមួយនឹងបង្កើតបន្ថែមទៀត នៅតាមកន្លែងណាដែលតំបន់សេដ្ឋកិច្ចពិសេសបានចាប់ផ្តើមដំណើរការ ។

០០០០

# វឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នានៃកិច្ចប្រជុំពិគ្រោះយោបល់លើកទី៨ ថ្ងៃទី២-៣ ខែមិនា ឆ្នាំ២០០៦

## បច្ចុប្បន្នភាពរហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៧

| គោលដៅ | សកម្មភាពចាំបាច់ | លទ្ធផល |
|---|---|---|
| ១- តាមដានជារៀងរាល់ឆ្នាំការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | ១. រៀបចំនិងអនុវត្តក្របខ័ណ្ឌសម្រាប់តាមដានការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងពិនិត្យពីវឌ្ឍនភាពនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិជារៀងរាល់ឆ្នាំ | រាជរដ្ឋាភិបាលបានរៀបចំ និងអនុមតិក្របខ័ណ្ឌសម្រាប់ពិនិត្យការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ក្របខ័ណ្ឌនេះបានគូសបញ្ជាក់ពីការពិនិត្យផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយ :<br>• រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ<br>• ពិនិត្យយ៉ាងលំអិតលើវឌ្ឍនភាព (រហូតដល់ដំណាច់ឆ្នាំ២០០៩) ក្នុងការសំរេចបានកិច្ចអភិវឌ្ឍន៍ ដោយផ្តោតលើលទ្ធផល ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ឧទាហរណ៍ ការកាត់បន្ថយអត្រាភាពក្រីក្រសរុប ពីកំរិតបច្ចុប្បន្ន (ការវាយតំលៃក្នុងឆ្នាំ ២០០៥) នៅថ្នាក់ជាតិ ថ្នាក់ខេត្ត- ក្រុង និងឃុំ- សង្កាត់ និងសូចនាករគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជាដទៃទៀត ព្រមទាំងកំណត់កាលានុវត្តភាព និងបញ្ហាប្រឈម សម្រាប់ជាមគ្គុទេសន៍និងជាធាតុចូលដ៏សំខាន់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ (២០១១-២០១៥)។<br>**របាយការណ៍ប្រចាំឆ្នាំ២០០៦ ស្តីពីវឌ្ឍនភាពនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ :**<br>• ក្រសួងផែនការបានរៀបចំឯកសារទស្សនទានសម្រាប់រៀបចំរបាយការណ៍វឌ្ឍនភាព កាលពីខែសីហា ឆ្នាំ២០០៦<br>• ឯកសារទស្សនទាននេះត្រូវបានរៀបចំ និងអនុមតិនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៦ ក្នុងកិច្ចប្រជុំកំរិតខ្ពស់ រវាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈ-កម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា<br>• ឯកសារទស្សនទាននេះក៏ត្រូវបានចែកផ្សាយជាព័ត៌មានជូនក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ផែនការ និងការកាត់បន្ថយភាពក្រីក្រ<br>• នាពាក់កណ្តាលខែវិច្ឆិកា ឆ្នាំ២០០៦ ក្រសួងផែនការបានស្នើឱ្យបណ្តាក្រសួង/ ស្ថាប័នផ្តល់ធាតុចូលសំខាន់ៗ ដើម្បីរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ និងគោលការណ៍ណែនាំលំអិត សម្រាប់រៀបចំរបាយការណ៍នេះ<br>• ក្រសួងផែនការទទួលបានធាតុចូលទាំងនេះ នាចុងខែធ្នូ ឆ្នាំ២០០៦<br>• ក្រោមការដឹកនាំរបស់ឯកឧត្តម ទួន ថាវរៈ អគ្គនាយក និងមន្ត្រីនៃលេខាធិការដ្ឋានផែនការយុទ្ធសាស្ត្រ |

| គោលដៅ | សកម្មភាពចាំបាច់ | លទ្ធផល |
|---|---|---|
| | | អភិវឌ្ឍន៍ជាតិនៃក្រសួងផែនការបានបញ្ចប់សេចក្តីព្រាងឯកសារបឋម ស្របតាមឯកសារទស្សនទាន |
| ១- តាមដានជារៀងរាល់ឆ្នាំការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | ១. រៀបចំ និងអនុវត្តក្របខ័ណ្ឌសម្រាប់តាមដានការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងពិនិត្យពីវឌ្ឍនភាពនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិជារៀងរាល់ឆ្នាំ | • ក្នុងសប្តាហ៍នេះ សេចក្តីព្រាងបឋមបានផ្ញើជូនបណ្តាក្រសួង/ ស្ថាប័នរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីពិចារណា ផ្តល់យោបល់ កែតម្រូវ និងឬផ្តល់ធាតុចូលបន្ថែម ប្រសិនបើមាន ។ ក្រសួងផែនការបានសំណូមពរឱ្យផ្តល់អាទិភាពខ្ពស់បំផុតចំពោះកិច្ចការនេះ ដើម្បីទទួលបានធាតុចូលទាំងអស់ មុនថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៧ ។<br>• ផ្អែកលើធាតុចូលទាំងនេះ ក្រសួងផែនការរៀបចំសេចក្តីព្រាងចុងក្រោយដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីមុនថ្ងៃទី៣១ ខែមិនា ដើម្បីពិនិត្យ និងអនុមតិ ។ |
| ២- ពង្រឹងភាពជាដៃគូ ដើម្បីបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងគណនេយ្យភាពទ្វេទិស | ១. អនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ | • ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលបានអនុមតិដោយរាជរដ្ឋាភិបាលនៅខែមករា ឆ្នាំ២០០៦ បាននិងកំពុងអនុវត្ត ។ |
| | ២. រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆមាសស្តីពីការអនុវត្តន៍ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្ម | • ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់បានរាយការណ៍អំពីវឌ្ឍនភាពក្នុងការអនុវត្តន៍ផែនការសកម្មភាពរបស់ខ្លួន ចំនួនបីដងក្នុងមួយឆ្នាំ ។ របាយការណ៍វឌ្ឍនភាពនេះបានបង្ហាញក្នុងកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ។ |
| | ៣. ត្រួតពិនិត្យឡើងវិញ និងពង្រឹងយន្តការសម្របសម្រួល រួមមាន ÷ កិច្ចប្រជុំពិគ្រោះយោបល់ គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និងក្រុមការងារបច្ចេកទេសចម្រុះ | • ការពិនិត្យឡើងវិញនូវយន្តការគណៈកម្មាធិការសម្របសម្រួលរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ -ក្រុមការងារបច្ចេកទេសចម្រុះបានអនុវត្តនៅក្នុងចន្លោះខែមេសា- មិថុនា ឆ្នាំ២០០៦ ។<br>• ការពិភាក្សាលើលទ្ធផលនៃការពិនិត្យឡើងវិញនេះ នៅឆមាសទី២ ឆ្នាំ២០០៦ ។<br>• យោងតាមលទ្ធផលនៃការពិនិត្យឡើងវិញនូវយន្តការខាងលើ រាជរដ្ឋាភិបាលបានរៀបចំ និងអនុមតិឯកសារណែនាំសម្រាប់ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមការងារបច្ចេកទេសចម្រុះ នាថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៧ ។ |
| ៣- ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ | ១. រៀបចំបញ្ចប់ និងអនុមតិសេចក្តីព្រាងច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ស្របតាមបទដ្ឋានជាអន្តរជាតិ ព្រមទាំង :<br>ក. រៀបចំផែនការដើម្បីអនុវត្តច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ<br>ខ. ផ្សព្វផ្សាយជាទៀងទាត់៦ខែម្តងនូវព័ត៌មានស្តីពីករណីអំពើពុករលួយ និងការផ្តន្ទាទោស | • រង់ចាំរដ្ឋសភាអនុមតិក្រមព្រហ្មទ័ណ្ឌ ដើម្បីធានាឱ្យមានសង្គតិភាព ។ |

| គោលដៅ | សកម្មភាពចាំបាច់ | លទ្ធផល |
|---|---|---|
| ៤- កសាងប្រព័ន្ធយុត្តិធម៌និងតុលាការ ដំណើរការប្រកបដោយតម្លាភាព និងគណនេយ្យភាព ដែលការពារសិទ្ធិបុគ្គល ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ | ១. រៀបចំក្របខ័ណ្ឌច្បាស់លាស់ស្តីពីសិទ្ធិទទួលព័ត៌មាន | • ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចកំពុងរៀបចំដំណើរការ ។ |
| | ២. រៀបចំបញ្ចប់សេចក្តីព្រាងច្បាប់ដែលនៅសេសសល់ ដើម្បីអនុមតិ (ក្រមស្តីពីនីតិវិធីព្រហ្មទ័ណ្ឌ ក្រមព្រហ្មទ័ណ្ឌ ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តិទៅរបស់តុលាការ) | • ក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានប្រកាសអោយប្រើប្រាស់នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ។<br>• ក្រមរដ្ឋប្បវេណីបានផ្ញើជូនរដ្ឋសភានៅថ្ងៃទី១២ ខែមករា ឆ្នាំ២០០៧ ។<br>• ក្រមនីតិវិធីព្រហ្មទណ្ឌកំពុងពិនិត្យឡើងវិញដោយគណៈកម្មាធិការច្បាប់នៃរដ្ឋសភា ។<br>• សេចក្តីព្រាងក្រមព្រហ្មទណ្ឌកំពុងត្រូវបានពិនិត្យឡើងវិញ ក្នុងកិច្ចប្រជុំអន្តរក្រសួង មុននឹងបញ្ជូនទៅគណៈរដ្ឋមន្ត្រី<br>• ក្រសួងយុត្តិធម៌កំពុងបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់តុលាការ ។ ក្រសួងពាណិជ្ជកម្ម កំពុងរៀបចំសេចក្តីព្រាងច្បាប់បង្កើតតុលាការពាណិជ្ជកម្ម ។<br>• សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម បានរៀបចំដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងបានផ្ញើទៅក្រសួងយុត្តិធម៌នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៦ ។ សេចក្តីព្រាងច្បាប់នេះកំពុងពិនិត្យដោយក្រសួងយុត្តិធម៌ ។ |
| | ៣. រៀបចំកាលបរិច្ឆេទ ដើម្បីបញ្ចប់សេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋាននានា ដែលជាតម្រូវការចាំបាច់សម្រាប់បំពេញតម្រូវការនៃអង្គការពាណិជ្ជកម្មពិភពលោក និងអនុវត្តការងារតាមកាលបរិច្ឆេទដែលបានកំណត់ | • សេចក្តីព្រាងច្បាប់ស្តីពីប្រតិបត្តិការដែលអាចធានាបាន អាចអនុមតិនៅពាក់កណ្តាលឆ្នាំ២០០៧ ។<br>• ច្បាប់ស្តីពីអាជ្ញាកណ្តាលពាណិជ្ជកម្ម ត្រូវបានប្រកាសឱ្យប្រើប្រាស់ នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៦ ។<br>• ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ត្រូវបានប្រកាសឱ្យប្រើប្រាស់ នៅខែមិថុនា ឆ្នាំ២០០៦ ។<br>• អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងថ្មីមួយ ដើម្បីអនុវត្តការប្តេជ្ញាចិត្តក្នុងអង្គការពាណិជ្ជកម្មពិភពលោក បានត្រូវអនុមតិនៅថ្ងៃទី៧ ខែមិនា ឆ្នាំ២០០៧ ។<br>• អនុក្រឹត្យស្តីពីការអនុវត្តន៍ច្បាប់ស្តីពីផ្លាកសញ្ញាពាណិជ្ជកម្ម ពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មើភាព បានត្រូវអនុមតិ នៅខែកក្កដា ឆ្នាំ២០០៦ ។<br>• អនុក្រឹត្យស្តីពីតំបន់សេដ្ឋកិច្ចពិសេស បានត្រូវអនុមតិនៅខែធ្នូ ឆ្នាំ២០០៥ ។ |
| | ៤. រៀបចំកាលបរិច្ឆេទ សម្រាប់រៀបចំសេចក្តីព្រាងច្បាប់ ការពិនិត្យពិភាក្សា និងការអនុមតិច្បាប់ថ្មីៗ និងការធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានដែលមានស្រាប់ ព្រមទាំងអនុវត្តការងារតាមកាលបរិច្ឆេទដែលបានកំណត់ | • ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានរៀបចំផែនសកម្មភាពអាទិភាព ដែលមានបញ្ចូលនូវសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យ និងការទទួលព័ត៌មាន ។ |
| | ៥. នៅពេលដែលកំពុងរៀបចំបញ្ជីច្បាប់អាទិភាព គួរយកចិត្តទុកដាក់លើ :<br>ក. បញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងការជួញដូរផ្លូវភេទ ដើម្បីផ្ញើជូនគណៈរដ្ឋមន្ត្រី | • សេចក្តីព្រាងច្បាប់ស្តីពីការលុបបំបាត់ការជួញដូរមនុស្ស និងការជួញដូរផ្លូវភេទ កំពុងកែតម្រូវដើម្បីធានាឱ្យមានសង្គតិភាពជាមួយនឹងពិធីសារ Palermo និងក្រមព្រហ្មទ័ណ្ឌកម្ពុជា ។ |

| គោលដៅ | សកម្មភាពចាំបាច់ | លទ្ធផល |
|---|---|---|
| ៤- កសាងប្រព័ន្ធយុត្តិធម៌និងតុលាការ ដំណើរការប្រកបដោយតម្លាភាព និងគណនេយ្យភាព ដែលការពារ សិទ្ធិបុគ្គល ដូចមានចែងក្នុង រដ្ឋធម្មនុញ្ញ | ខ. បញ្ចប់និងអនុមតិផែនការជាតិសម្រាប់អនុវត្តច្បាប់ស្តីពីការប្រឆាំងនឹង អំពើហឹង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ | • ផែនការជាតិសម្រាប់អនុវត្តច្បាប់ស្តីពីការប្រឆាំងនឹងអំពើហឹង្សាក្នុងគ្រួសារ នឹងត្រូវបញ្ចប់នៅក្នុងឆ្នាំ ២០០៧ ។ |
| | គ. បញ្ចប់លិខិតបទដ្ឋានសម្រាប់អនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ | • ប្រកាសលេខ៤២ ចុះថ្ងៃទី១០ ខែមិនា ឆ្នាំ២០០៦ ស្តីពីអត្តសញ្ញាណដីរដ្ឋ និងផែនទីដីរដ្ឋ និងការធ្វើ ចំណាត់ថ្នាក់ដីរដ្ឋ ។<br>• សេចក្តីសំរេចលេខ៥២ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីលក្ខខ័ណ្ឌវិនិច្ឆ័យសម្រាប់ធ្វើចំណាត់ថ្នាក់ដីរដ្ឋ ។<br>• សេចក្តីព្រាងប្រកាសរួម (រវាងក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់) ស្តីពីផែនការប្រើប្រាស់ដីរដ្ឋ- ឯកជន និងបទដ្ឋានស្តីពីការបញ្ជាក់ទិដ្ឋភាពបច្ចេកទេសនៃការរៀបចំ ផែនទី និងទិន្នន័យដីរដ្ឋ ។ |
| | ឃ. អនុវត្តមាត្រា១៨ នៃច្បាប់ភូមិបាល | • គណៈរដ្ឋមន្ត្រី បានអនុមតិសារាចរស្តីពីវិធានការប្រឆាំងនឹងការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ នៅថ្ងៃ ទី៩ ខែកុម្ភៈ ឆ្នាំ២០០៧ ។ |
| | ង. អនុមតិយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលស្តីពីជនជាតិភាគតិច | • សេចក្តីព្រាងយុទ្ធសាស្ត្របឋមបានរៀបចំបញ្ចប់ ។<br>• សិក្ខាសាលាពិគ្រោះយោបល់ត្រូវបានរៀបចំឡើង ក្នុងពេលថ្មីៗនាខែកុម្ភៈ ឆ្នាំ២០០៧ ហើយផ្អែកតាម លទ្ធផលនៃសិក្ខាសាលានេះ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លីកំពុងកែសម្រួល ។<br>• សេចក្តីព្រាងគោលនយោបាយបានកែតម្រូវតាមយោបល់និងអនុសាសន៍ និងត្រូវផ្ញើជូនគណៈរដ្ឋមន្ត្រី ។ |
| ៥- បន្តពង្រឹងរដ្ឋបាលសាធារណៈដើម្បី បំរើផលប្រយោជន៍ប្រជាពលរដ្ឋ និងក្លាយជាដៃគូសំរាប់កិច្ចអភិវឌ្ឍន៍ | ១. អនុវត្តយុទ្ធសាស្ត្ររួមរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍"ស្តីពីការឈប់ អនុវត្តជាជំហានៗ នូវការផ្តល់ប្រាក់បៀវត្សរ៍បន្ថែម ដោយ :<br>ក. អនុវត្តផែនការសកម្មភាពតាមវិស័យដែលបានឯកភាព និង<br>ខ. បង្កើតកន្សោមអាទិភាព និងអនុវត្តប្រព័ន្ធប្រាក់បៀវត្សរ៍ស្របតាម ប្រសិទ្ធភាពការងារនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង សុខាភិបាល និងយ៉ាងតិចបំផុតនៅក្រសួង/ ស្ថាប័នមួយទៀត | • ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបានបំពេញកំរងសំនួរស្តីពីការអនុវត្តផ្តល់ប្រាក់ឧបត្ថម្ភ។<br>• មធ្យោបាយដើម្បីទទួលបានទិន្នន័យ និងវិភាគទិន្នន័យពុំត្រូវបានធានានៅឡើយ។<br>• ការងារអនុវត្តយុទ្ធសាស្ត្រ ត្រូវរង់ចាំជំហានទី១ សិន។<br>• ប្រព័ន្ធប្រាក់បៀវត្សរ៍តាមប្រសិទ្ធភាពការងារ បានត្រូវចាប់ផ្តើមអនុវត្តនៅចុងឆ្នាំ២០០៥។<br>• កំពុងរៀបចំប្រព័ន្ធប្រាក់បៀវត្សរ៍ស្របតាមប្រសិទ្ធភាពការងារ សំរាប់ក្រសួងសុខាភិបាល ។<br>• កំពុងពិភាក្សាប្រព័ន្ធប្រាក់បៀវត្សរ៍ស្របតាមប្រសិទ្ធភាពការងារ សំរាប់ក្រសួងពាណិជ្ជកម្ម ។ |
| | ២. កែលំអការផ្តល់ប្រាក់បៀវត្សរ៍ និងលក្ខខ័ណ្ឌការងាររបស់មន្ត្រីរាជការ :<br>ក. រៀបចំយុទ្ធសាស្ត្រនិងផែនការរយៈពេលមធ្យមសម្រាប់កែលំអបៀវត្សរ៍<br>ខ. រៀបចំគោលនយោបាយ និងផែនការសកម្មភាពស្តីពីការពង្រាយ មន្ត្រីរាជការ | • របាយការណ៍សិក្សាចំនួនពីរ ដើម្បីផ្តល់ជាដំណឹងពីសេចក្តីសំរេចលើគោលនយោបាយកែលំអបៀវត្សរ៍ និង ការពង្រាយមន្ត្រីរាជការត្រូវបានបញ្ចប់ ហើយបច្ចុប្បន្នកំពុងត្រូវបានផ្សព្វផ្សាយ។<br>• រៀបចំឯកសារទស្សនទានស្តីពីគោលនយោបាយរយៈពេលមធ្យមសម្រាប់កែលំអបៀវត្សរ៍ និង ដំណើរការគោលនយោបាយជ្រើសរើសមន្ត្រីរាជការ។ |
| | ៣. រៀបចំ និងអនុវត្តគោលនយោបាយ និងផែនការសកម្មភាពស្តីពីការគ្រប់ | • ឯកសារទស្សនទានស្តីពីការគ្រប់គ្រងធនធានមនុស្ស និងការពង្រឹងធនធានមនុស្ស ត្រូវបានរៀបចំ |

| គោលដៅ | សកម្មភាពចាំបាច់ | លទ្ធផល |
|---|---|---|
| ៥- បន្តពង្រឹងរដ្ឋបាលសាធារណៈដើម្បីបំរើផលប្រយោជន៍ប្រជាពលរដ្ឋ និងក្លាយជាដៃគូសំរាប់កិច្ចអភិវឌ្ឍន៍ | គ្រងធនធានមនុស្ស ដោយប្រើប្រាស់មគ្គុទេសក៏ស្តីពីការគ្រប់គ្រងធនធានមនុស្ស និងប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស សម្រាប់មន្ត្រីរាជការស៊ីវិល | និងបានផ្ញើជូនក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទំរង់រដ្ឋបាលសាធារណៈ នាខែតុលា ឆ្នាំ ២០០៦ ។ ប៉ុន្តែ ពុំទាន់ទទួលបានយោបល់កែលំអ ឬអនុសាសន៍ឡើយ ។<br>• ការពិភាក្សាអន្តរក្រសួងស្តីពីគោលនយោបាយគ្រប់គ្រងធនធានមនុស្សនឹងរៀបចំក្នុងពេលឆាប់ៗនេះ ។<br>• ការផ្តល់ហិរញ្ញប្បទានសម្រាប់ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្សត្រូវបានធានា ។ |
| | ៤. កែលំអការផ្តល់សេវា តាមរយៈការបង្កើតយន្តការបញ្ជរតែមួយ និងពង្រឹងក្របខ័ណ្ឌច្បាប់ ដោយបង្កើតបញ្ជរតែមួយ ឱ្យបានយ៉ាងតិចបំផុត៥កន្លែងទៀតនៅទូទាំងប្រទេស | • គោលនយោបាយស្តីពីការផ្តល់សេវាត្រូវបានអនុមតិដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៦ ។<br>• បានរៀបចំសេចក្តីព្រាងគោលនយោបាយស្តីពីសេវាច្រកចេញចូលតែមួយ ។ |
| ៦- រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលស្តីពីកំណែទំរង់វិមជ្ឈការនិងសហវិមជ្ឈការ និងបន្តរៀបចំជំហានបឋម ដើម្បីឈានទៅអនុវត្តឱ្យបានពេញលេញ | ១. បញ្ចប់សេចក្តីព្រាងច្បាប់អង្គការស្តីពីការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ខេត្ត ស្រុក និងឃុំ ដើម្បីដាក់ជូនរដ្ឋសភា | • សេចក្តីព្រាងបឋមនៃច្បាប់អង្គការ ត្រូវបានបញ្ចប់ដោយក្រសួងមហាផ្ទៃក្នុងឆ្នាំ២០០៦ និងបច្ចុប្បន្ន កំពុងពិភាក្សា ។ |
| | ២. រៀបចំក្របខ័ណ្ឌសម្រាប់អនុវត្តច្បាប់អង្គការស្តីពីកំណែទំរងវិមជ្ឈការនិងវិសហមជ្ឈការ (បន្ទាប់ពីការអនុម័តដោយរដ្ឋសភា) | • បានរៀបចំក្របខ័ណ្ឌបឋមសម្រាប់អនុវត្ត ហើយបានអនុមតិដោយគណៈកម្មាធិការជាតិដឹកនាំការងារកំណែទំរងវិមជ្ឈការនិងវិសហមជ្ឈការ ហើយបានផ្សព្វផ្សាយសមាសធាតុនៃដំណាក់កាលត្រៀម ។ |
| | ៣. ពិនិត្យ និងរៀបចំកម្មវិធីគាំទ្រវិមជ្ឈការនិងវិសហមជ្ឈការ សម្រាប់កំណែទំរង់ និងការវិនិយោគសម្រាប់កិច្ចអភិវឌ្ឍន៍មូលដ្ឋាន | • កម្មវិធីជាតិស្តីពីការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យនៅក្រោមថ្នាក់ជាតិ នឹងត្រូវបញ្ចប់មុនឆ្នាំ២០០៧ ។<br>• គំរោងគាំទ្រការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យ នៅក្រោមថ្នាក់ជាតិតាមរយៈវិមជ្ឈការនិងវិសហមជ្ឈការត្រូវបានអនុមតិដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ក្នុងខែមករា ឆ្នាំ២០០៧ ។ |
| ៧- អនុវត្តកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ១. បន្តអនុវត្តកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (បញ្ចប់ដំណាក់កាលទី១- កន្សោមទី១ និងចាប់ផ្តើមដំណាក់កាលទី២) និងតាមដានលទ្ធផលតាមរយៈសូចនាករដែលបានឯកភាព | **<u>សកម្មភាពចាំបាច់ក្នុងការសំរេចឱ្យបាននូវជំហានទីមួយ :</u>**<br>• ការប្រមូលធនធានថវិកាដែលមានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយ ។<br>• ការព្យាករណ៍ចំណូល និងគោលនយោបាយប្រមូលចំណូល ។<br>• កែលំអការគ្រប់គ្រងក្របខ័ណ្ឌសារពើពន្ធ និងការព្យាករណ៍ធនធានថវិកា<br>• ការគ្រប់គ្រងបំណុល<br>• ពង្រឹងបែបបទនៃការចំណាយ<br>• ការគ្រប់គ្រងសាច់ប្រាក់<br>• ការពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារ<br>• ការពង្រឹងគណនីធនាគាររដ្ឋ<br>• លទ្ធកម្ម<br>**<u>ការងាររៀបចំសម្រាប់ជំហានបន្ទាប់ :</u>**<br>• រៀបចំចំណាត់ថ្នាក់ថវិកាថ្មី និងប្លង់គណនេយ្យ |

| គោលដៅ | សកម្មភាពចាំបាច់ | លទ្ធផល |
|---|---|---|
| | | • វដ្តថវិកាថ្មី និងកាលបរិច្ឆេទនៃថវិកា<br>• វិមជ្ឈការសារពើពន្ធ<br>• ការបង្កើតសវនកម្មផ្ទៃក្នុង<br>• អនុវត្តសាកល្បងថវិកានីយកម្មកម្មវិធី<br>• ការងាររៀបចំប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ<br>**<u>ការពង្រឹងសមត្ថភាព និងយន្តការលើកទឹកចិត្ត</u> :**<br>• ការពង្រឹងសមត្ថភាព<br>• ការអនុវត្តន៍ផែនការប្រព័ន្ធប្រាក់បៀវត្សរ៍ស្របតាមប្រសិទ្ធភាពការងារ |
| ៨- លើកកំពស់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ និងកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ និងពង្រឹងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដូចមានក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ | ១. រៀបចំយុទ្ធសាស្ត្ររយៈពេលមធ្យមសម្រាប់វិស័យកសិកម្ម និងការស្រោចស្រព ដោយផ្អែកតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រដែលមានស្រាប់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម | • ពង្រាងយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងការស្រោចស្រព (២០០៦-២០១០) ត្រូវបានរៀបចំ និងផ្ញើជូនរាជរដ្ឋាភិបាល ដើម្បីអនុមតិ ។ |
| | ២. បង្កើតយន្តការផ្សព្វផ្សាយព័ត៌មានស្តីពីសម្បទានដីសេដ្ឋកិច្ច ផ្អែកតាមសេចក្តីសម្រេចរបស់សម្តេចនាយករដ្ឋមន្ត្រី កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៥ | • ពត៌មានស្តីពីសម្បទានដីសេដ្ឋកិច្ច មានក្នុងគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ |
| | ៣. ចាត់វិធានការសមស្របដើម្បីឆ្លុះបញ្ចាំងអំពីអាទិភាពវិស័យជលផល ក្នុងផែនការអភិវឌ្ឍន៍ខេត្ត ស្រុក និងឃុំ ព្រមជាមួយកំរិតនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការសំដៅលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ជនបទ | • ច្បាប់ជលផលត្រូវបានផ្សព្វផ្សាយ ហើយវគ្គបណ្តុះបណ្តាលត្រូវបានរៀបចំ សម្រាប់ភ្នាក់ងារពាក់ព័ន្ធនឹងវិស័យជលផល ។<br>• ប្រកាសស្តីពីតួនាទី និងការប្រព្រឹត្តទៅរបស់រដ្ឋបាលជលផល ត្រូវបានអនុមតិដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។<br>• វេទិកាជលផល និងវេទិកាជលផលស្តីពីស្ត្រីក្នុងការងារជលផល ត្រូវបានរៀបចំឡើង ។<br>• ទិដ្ឋភាពខាងស្ថាប័ននាយកដ្ឋានជលផល និងតួនាទីនៃរដ្ឋបាលជលផលមូលដ្ឋានក្នុងការផ្តល់សេវាកម្មត្រូវបានពិនិត្យឡើងវិញ ។<br>• ស្នើសុំការគាំទ្រពីសម្តេចនាយករដ្ឋមន្ត្រី លើអាទិភាពក្នុងវិស័យជលផល ។ ទន្ទឹមនេះ សំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបានផ្ញើជូនបណ្តាក្រសួងពាក់ព័ន្ធ អភិបាលក្រុង ដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រលើវិស័យជលផល និងដើម្បីសំរេចឱ្យបាននូវសូចនាករដែលបានកំណត់ ។<br>• ហិរញ្ញប្បទានសម្រាប់វិស័យជលផល និងផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះ |

| គោលដៅ | សកម្មភាពចាំបាច់ | លទ្ធផល |
| --- | --- | --- |
| | | សម្រាប់ការងារជលផលត្រូវបានធានាតាមរយៈអនុសារណៈយោគយល់គ្នាជាមួយ DANIDA ។<br>• ការអភិរក្ស និងការកំណត់ព្រំដែនតំបន់ព្រៃលិចទឹក ។<br>• ការអភិរក្សតំបន់មាត់សមុទ្រៈ ផែនការសកម្មភាពស្តីពីផ្កាថ្ម និងសារាយសមុទ្រ សំរាប់រយៈពេល១០ឆ្នាំ ត្រូវបានអនុមតិដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។<br>• សហគមន៍អ្នកនេសាទ និងទីជម្រកត្រីសហគមន៍ៈ បច្ចុប្បន្នសហគមន៍អ្នកនេសាទមាន ចំនួន ៥០៩ ហើយទីជម្រកត្រីសហគមន៍មានចំនួន ៦២ ។ |
| | ៤. ដើម្បីលើកកំពស់ជីវភាពជនក្រីក្រ ។ ជនក្រីក្រ៥០០គ្រួសារនឹងទទួលបានដីសម្បទានសង្គមកិច្ច រួមជាមួយការគាំទ្រខាងជីវភាពរស់នៅ ព្រមទាំងរក្សាដីយ៉ាងតិចបំផុត១០.០០០ហិចតា សម្រាប់ធ្វើជាដីសម្បទានសង្គមកិច្ច | • មានគំរោងសាកល្បងចំនួន ២ ជាមួយគំរោង LASED<br>• តាមរយៈក្រុមការងារអន្តរក្រសួង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កំពុងធ្វើការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ចំនួន ៥០០ ដើម្បីទទួលបានដីសម្បទានសង្គមកិច្ច ។<br>• ដីព្រៃឈើមួយចំនួនដែលបានរឹបអូសពីការកាន់កាប់ដីខុសច្បាប់ ត្រូវរក្សាទុកជាដីសម្បទានសង្គមកិច្ច។<br>• ដីមួយចំនួនបានមកពីដីសម្បទានសេដ្ឋកិច្ចដែលបានលុបចោល ត្រូវរក្សាទុកជាដីសម្បទានសង្គមកិច្ច។ |
| ៨- លើកកំពស់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ និងកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ និងពង្រឹងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដូចមានក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ | ៥. រៀបចំគោលនយោបាយសុវត្ថិភាពសង្គម ដើម្បីធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់ក្រុមជនងាយរងគ្រោះ | • គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានឆ្លើយតបទៅនឹងវិបត្តិស្បៀង និងអាហារូបត្ថម្ភក្នុងទូទាំងប្រទេស ។<br>• គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានរៀបចំការពិគ្រោះយោបល់នានា ។ ត្រូវឱ្យមានគំរោងសុំមូលនិធិ សម្រាប់ជួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងការរៀបចំ និងអនុវត្តយន្តការធ្វើអន្តរាគមន៍ខ្នាតធំ (មូលនិធិពីដៃគូអភិវឌ្ឍន៍ពុំទាន់ត្រូវបានធានានៅឡើយ)។<br>• ក្នុងអំឡុងឆ្នាំ២០០៦ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានទទួលបន្ទុកជាអ្នកឆ្លើយតបជំនួសមុខឱ្យរាជរដ្ឋាភិបាល ចំពោះការផ្ទុះឡើងនូវជំងឺគ្រុនផ្តាសាយបក្សី បន្ថែមទៅលើការទទួលខុសត្រូវលើគ្រោះមហន្តរាយធម្មជាតិ ។ គួរតែបន្ថែមអន្តរាគមន៍ថែមទៀតលើកិច្ចការសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។ ដោយមើលឃើញពីហានិភ័យនៃជំងឺគ្រុនផ្តាសាយបក្សី ក្រុមការងារបច្ចេកទេសចម្រុះបានសំណូមពរឱ្យកែលំអការឆ្លើយតបនឹងតម្រូវការបន្ទាន់ និងកែលំអសមត្ថភាពរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។ ធាតុពិត បញ្ហានេះលើសពីការទទួលខុសត្រូវរបស់ក្រុមការងារបច្ចេកទេសចម្រុះ ។ ដោយយល់ឃើញពីសារៈសំខាន់នៃបញ្ហា ក្រុមការងារបច្ចេកទេសចំរុះសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ បានផ្តល់អនុសាសន៍ថា សូចនាករតាមដានរួមគ្នាគួរតែកែសំរួល ហើយដាក់ឱ្យនៅក្រោមការទទួលខុសត្រូវរបស់ក្រុមការងារបច្ចេកទេសចម្រុះផ្សេងវិញ ។ |

| គោលដៅ | សកម្មភាពចាំបាច់ | លទ្ធផល |
|---|---|---|
| | ៦. រៀបចំប្រព័ន្ធតាមដានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ | • សេចក្តីព្រាងគំរោងស្នើសុំ ត្រូវបានរៀបចំឡើង និងបានពិភាក្សាគ្នានៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅខែសីហា ឆ្នាំ ២០០៦ ។ ក្រុមការងារស្តីពីប្រព័ន្ធត្រួតពិនិត្យតាមដានអាហារូបត្ថម្ភ បានរៀបចំកិច្ចប្រជុំផ្សេងៗជាបន្តបន្ទាប់ ។ សិក្ខាសាលាមួយ បានប្រារព្ធនៅក្នុងខែវិច្ឆិកា ដោយមានការចូលរួមពីភ្នាក់ងារពាក់ព័ន្ធសំខាន់ៗ ។<br>• ភ្នាក់ងារពាក់ព័ន្ធដែលចូលរួមក្នុងការរៀបចំប្រព័ន្ធត្រួតពិនិត្យតាមដានអាហារូបត្ថម្ភ សម្រាប់ត្រួតពិនិត្យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ បានបញ្ជាក់ពីតំរូវការជាច្រើន ។ ការរៀបចំប្រព័ន្ធត្រួតពិនិត្យតាមដានអាហារូបត្ថម្ភដ៏ទូលំទូលាយបែបនេះនឹងត្រូវចំណាយខ្ពស់ ។<br>• ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ បានផ្តល់យោបល់ថា ការពង្រឹងប្រព័ន្ធត្រួតពិនិត្យតាមដានអាហារូបត្ថម្ភ ដើម្បីត្រួតពិនិត្យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មិនគួរជា សូចនាករតាមដានរួមគ្នាទៀតទេ ។ គួរគាំទ្រលើការពង្រឹងយន្តការដែលមានស្រាប់ តាមរយៈវិទ្យាស្ថាន ស្ថិតិជាតិ និងយន្តការផ្សេងៗ និងគាំទ្រកិច្ចខិតខំប្រឹងប្រែងនានា ដើម្បីពង្រឹងសន្តិសុខស្បៀង និង អាហារូបត្ថម្ភ ដែលពាក់ព័ន្ធនឹងប្រព័ន្ធតាមដានត្រួតពិនិត្យ ។ |
| ៩- បន្តស្តារនិងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីអនុវត្តឱ្យបានសំរេចនូវកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ | ១. សម្រេចឱ្យបាននូវកិច្ចព្រមព្រៀងស្តីពីយន្តការច្បាស់លាស់ និងតម្លាភាពក្នុងការវិភាជន៍ថវិកា និងការប្រើប្រាស់ថវិកា និងត្រួតពិនិត្យការជួសជុល និងថែរក្សាផ្លូវថ្នល់ | • គណៈកម្មការអន្តរក្រសួងនៃក្រសួងសាធារណៈការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានបង្កើតក្នុងខែកញ្ញា ឆ្នាំ២០០៦ ដើម្បីសម្របសម្រួលបញ្ហាថែទាំផ្លូវថ្នល់ ។ |
| | ២. រៀបចំ និងស្នើច្បាប់ស្តីពីផ្លូវថ្នល់ជូនគណៈរដ្ឋមន្ត្រីអនុមតិ | • សេចក្តីព្រាងច្បាប់ផ្លូវថ្នល់ត្រូវបានផ្ញើជូនគណៈរដ្ឋមន្ត្រី ។ |
| | ៣. រៀបចំ និងស្នើសេចក្តីព្រាងច្បាប់ស្តីពីទូរគមនាមគន៍ជូនគណៈរដ្ឋមន្ត្រីអនុមតិ | • សេចក្តីព្រាងច្បាប់ទូរគមនាគមន៍បានផ្ញើជូនរដ្ឋសភា ។ |
| | ៤. រៀបចំ និងស្នើសេចក្តីព្រាងច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកនិងអនាម័យជូនគណៈរដ្ឋមន្ត្រីអនុមតិ | • សេចក្តីព្រាងច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកនិងអនាម័យ ត្រូវបានផ្ញើជូនគណៈរដ្ឋមន្ត្រី នៅខែមិនា ឆ្នាំ ២០០៥ ហើយបច្ចុប្បន្ន កំពុងត្រូវបានកែលំអ ។<br>• សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ត្រូវបានផ្ញើជូនរដ្ឋសភាដើម្បីអនុមតិ ។ |
| | ៥. រៀបចំសេចក្តីព្រាងគោលនយោបាយជាតិ និងស្ថិតិស្តីពីថាមពលដែលមានប្រភពពីឈើ | • ក្រុមការងារមួយក្រុម ត្រូវបានបង្កើតឡើងនៅខែកុម្ភៈ ឆ្នាំ២០០៦ ដើម្បីពិនិត្យបញ្ហានេះ ។<br>• សេចក្តីព្រាងគោលនយោបាយជាតិនេះត្រូវបានបញ្ចប់ និងផ្ញើជូនគណៈរដ្ឋមន្ត្រីនៅត្រីមាសទី១ នៃ ឆ្នាំ ២០០៧ ។ |
| ១០- កសាងសង្គមមួយដែលមានសាមគ្គីភាពរឹងមាំ ប្រព័ន្ធអប់រំ និងវប្បធម៌ជឿនលឿន គ្មានភាពក្រីក្រ | ១. បង្កើនចំនួនស្ត្រីសម្រាលបុត្រដោយឆ្មបជំនាញ | • ស្ត្រីសម្រាលបុត្រដោយឆ្មបជំនាញ កើនឡើងពី ៣១.៨% ក្នុងឆ្នាំ២០០០ ដល់៤៣.៨% ក្នុងឆ្នាំ២០០៥ ។ |
| | ២. បង្កើនអត្រាចុះឈ្មោះចូលរៀននៅថ្នាក់បឋមភូមិ (សរុប និងតាមភេទ) | • អត្រានៃការចូលរៀនសរុបបានធ្លាក់ចុះពី៩១.៩% មក៩១.៣% ក្នុងឆ្នាំសិក្សា ២០០៤/០៥-២០០៥/០៦ ។<br>• អត្រាចូលរៀនសរុបរបស់សិស្សស្ត្រី បានធ្លាក់ចុះពី៩០.៧% មកត្រឹម៨៩.៧% ក្នុងឆ្នាំសិក្សា២០០៤/០៥- |

| គោលដៅ | សកម្មភាពចាំបាច់ | លទ្ធផល |
|---|---|---|
| អនក្ខរភាព និងជម្ងឺដង្កាត់ និងបន្តអនុវត្តផែនការនារីរតនៈ | | ២០០៥/០៦ ។ |
| | ៣. បង្កើនអត្រាឡើងថ្នាក់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ | • អត្រាសិស្សឡើងថ្នាក់បានធ្លាក់ចុះពី៥២,៦% មកត្រឹម៤៨,១% ក្នុងឆ្នាំសិក្សា ២០០៤/០៥-២០០៥/០៦ ។<br>• អត្រាសិស្សស្រ្តីឡើងថ្នាក់បានធ្លាក់ចុះពី៥១,៧% មក៧,៥% ក្នុងឆ្នាំសិក្សា ២០០៤/០៥-២០០៥/០៦ ។ |
| | ៤. អនុវត្តផែនការជាតិប្រឆាំងអំពើហិង្សាលើស្រ្តី | • ផែនការជាតិទប់ស្កាត់ និងប្រឆាំងអំពើហិង្សាក្នុងគ្រួសារ នឹងត្រូវបញ្ចប់នៅក្នុងឆ្នាំ២០០៧ ។ |
| | ៥. ពង្រីកវិសាលភាពនៃការទប់ស្កាត់ ថែរក្សា និងគាំទ្រ ព្រមទាំងវិធានការកាត់បន្ថយផលប៉ះពាល់នៃជំងឺអេដស៍ និងការប្រើប្រាស់គ្រឿងញៀន | • ក្របខ័ណ្ឌជាតិសម្រាប់កុមារកំព្រានិងកុមារគ្មានទីពឹង កំពុងរៀបចំ ហើយអាចនឹងបញ្ចប់ក្នុងត្រីមាសទី១ នៃ ឆ្នាំ២០០៧ ។<br>• កំពុងរៀបចំឯកសារណែនាំពីវិមជ្ឍការសម្រាប់ឆ្លើយតបជាពហុវិស័យទៅនឹងបញ្ហាអេដស៍ និងផលប៉ះពាល់ ក្នុងការកាត់បន្ថយការរាលដាលនៃជំងឺអេដស៍ ។<br>• កម្ពុជាមានបំណងចូលរួមកិច្ចប្រជុំ GFATM លើកទី៧ ដើម្បីពង្រីកវិសាលភាពនៃការទប់ស្កាត់ ថែរក្សា និងគាំទ្រ ព្រមទាំងវិធានការកាត់បន្ថយផលប៉ះពាល់នៃជំងឺអេដស៍ ។ |
| ១១- ធានាការប្រើប្រាស់ប្រកបដោយចីរភាពនូវធនធានធម្មជាតិ ដោយគិតគូរអំពីជីវភាព និងតម្រូវការរបស់សហគមន៍ជនបទ | ១. រៀបចំ និងអនុវត្តកម្មវិធីជាតិគ្រប់គ្រងព្រៃឈើដើម្បី :<br>ក. ពង្រឹងការអនុវត្តន៍ច្បាប់ព្រៃឈើ ពិសេស ការលុបបំបាត់ការដុតបំផ្លាញដីព្រៃឈើ និងការទន្ទ្រានយកដីព្រៃ | • រដ្ឋាភិបាលបាន និងកំពុងរឹបអូសមកវិញ នូវដីព្រៃឈើចំនួន២០៧.៩៦០ហ.ត ដោយរួមបញ្ចូលទាំងតំបន់ព្រៃលិចទឹក ចំនួន៩.៣២៤ហ.ត ពីក្រុមកាន់កាប់ដីខុសច្បាប់ ។ ក្នុងឆ្នាំ២០០៦ បទល្មើសចំនួន៨៩៩ករណី ត្រូវបានរាយការណ៍ដោយអង្គភាពតាមដានបទល្មើសនៃរដ្ឋបាលព្រៃឈើ ។ |
| | ខ. ធ្វើសនិទានកម្ម និងចំណាត់ថ្នាក់ដីព្រៃឈើជាតិឡើងវិញ ដើម្បីធានាការប្រើប្រាស់ប្រកបដោយចីរភាព ដោយបន្តកំណត់ព្រំដែនដីព្រៃ និងតំបន់ព្រៃការពារ | • ការកំណត់ព្រំដែនព្រៃឈើកំពុងតែបន្ត ក្នុងតំបន់រដ្ឋបាលព្រៃឈើចំនួន១៥ ។<br>• ការកំណត់ដែនដី ព្រៃឈើត្រូវបានធ្វើឡើងក្នុង ខេត្តសាកល្បងមួយចំនួន (ដែនដីព្រៃឈើចំនួន៣២០.០០០ហ.ត និងប្រវែង ៦០០គ.ម ត្រូវបានកំណត់) ហើយគោលការណ៍ណែនាំស្តីពីការកំណត់ដែនដីព្រៃរបស់រដ្ឋបាលព្រៃឈើ ត្រូវបានរៀបចំឡើង និងសាកល្បងអនុវត្តនៅក្នុងឆ្នាំ២០០៧ ។<br>• ផែនទីនៃតំបន់អភិរក្សចំនួន ១៦ (សួនឧទ្យានជាតិ និងតំបន់អភិរក្សសត្វព្រៃ) បាន និងកំពុងរៀបចំ ហើយការងារកំណត់ព្រំដែននៃតំបន់ទាំងនោះ បាននិងកំពុងអនុវត្តផងដែរ ដោយរៀបចំឱ្យមានការដាក់ផ្លាកសញ្ញាត្រឹមត្រូវ ។ |
| | គ. បញ្ចប់ការវាយតម្លៃតំបន់គ្របដណ្តប់ដោយព្រៃឈើ ២០០៥/២០០៦ | • ការបកស្រាយ និងការដាក់ចំណាត់ថ្នាក់ប្រភេទព្រៃឈើ បានបញ្ចប់ ។ ក្រុមហ៊ុន GRAS A/S កំពុងពិនិត្យទិន្នន័យវាយតំលៃឡើងវិញ ហើយក្រុមហ៊ុននឹងត្រូវបញ្ចប់ក្នុងខែឧសភា ឆ្នាំ២០០៧ ។ |
| | ឃ. អនុវត្តកម្មវិធីសហគមន៍ព្រៃឈើ និងបន្តបង្កើតសហគមន៍ព្រៃឈើ | • គោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើត្រូវបានអនុមតិ ។ គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិត្រូវបានបង្កើតឡើង ។ មានការព្រមព្រៀងគាំទ្រចំពោះសហគមន៍ព្រៃឈើ ។ គំរោងស្នើសុំតូចៗមួយចំនួនបានត្រូវរៀបចំ និងកំពុងស្វែងរកការផ្តល់ហិរញ្ញប្បទាន ។ |

| គោលដៅ | សកម្មភាពចាំបាច់ | លទ្ធផល |
| --- | --- | --- |
| | ង. អនុវត្តការកសាងសមត្ថភាពសម្រាប់កម្មវិធីខាងវិស័យព្រៃឈើ និងការដាំកូនឈើសម្រាប់បំរើបុព្វហេតុសេដ្ឋកិច្ច និងសង្គមកិច្ច | • ការពង្រឹងសមត្ថភាពកំពុងអនុវត្តបន្ត ហើយបានដាំកូនឈើលើផ្ទៃដីចំនួន៣.៥០០ ហ.ត ។ |
| | ច. ការត្រួតពិនិត្យឯករាជ្យក្នុងវិស័យព្រៃឈើ (លុះត្រាតែមានហិរញ្ញប្បទានសហប្រតិបត្តការពីដៃគូអភិវឌ្ឍន៍) | • គ្មានថវិកាសម្រាប់គាំទ្រសកម្មភាពការងារនេះទេ ។ |
| | ២. ពង្រឹងតម្លាភាព ដោយផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពរាជរដ្ឋាភិបាល រួមមានព័ត៌មានស្តីពីដីសម្បទានសម្រាប់ធនធានរ៉ែ និងតំបន់ហ៊្វីកហ៊្វីនកងទ័ព ព័ត៌មានអំពីសកម្មភាពរបស់ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល ក្នុងគេហទំព័ររបស់ក្រុមការងារព្រៃឈើ | • ក្រសួងឧស្សាហកម្មរ៉ែ និងថាមពលបានផ្តល់ព័ត៌មានពីតំបន់ដែលមានធនធានរ៉ែ ។<br>• ក្រសួងការពារជាតិបានបញ្ជូនតំណាងចូលជាសមាជិកនៃក្រុមការងារបច្ចេកទេសចម្រុះ និងផ្តល់ព័ត៌មានស្តីពីតំបន់ហ៊្វីកហ៊្វីនកងទ័ព ក្នុងកិច្ចប្រជុំនៃក្រុមការងារបច្ចេកទេសចម្រុះ ។<br>• ក្រសួងបរិស្ថានត្រូវចែករំលែកទិន្នន័យ GIS ដល់ដៃគូអភិវឌ្ឍន៍ ។<br>• ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តល់ព័ត៌មានស្តីពីដីសម្បទានសេដ្ឋកិច្ច ។ |
| | ៣. រៀបចំ និងអនុវត្តគោលនយោបាយគ្រប់គ្រងដីធ្លី និងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធ ដើម្បីកែលំអការប្រើប្រាស់ដីធ្លីប្រកបដោយចីរភាព | • អនុក្រឹត្យស្តីពីការគ្រប់គ្រងដីធ្លីបានចូលជាធរមាន ។<br>• សិក្ខាសាលាផ្សព្វផ្សាយព័ត៌មានបានត្រូវធ្វើឡើងសម្រាប់អភិបាលខេត្ត- ក្រុង បណ្តាក្រសួង- ស្ថាប័ន មន្ត្រីខុទ្ទកាល័យខេត្ត- ក្រុង និងប្រធាន និងអនុប្រធាននាយកដ្ឋាននៃមន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត- ក្រុង ។<br>• នៅថ្នាក់ខេត្ត បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយព័ត៌មាន សម្រាប់មន្ត្រីមកពីមន្ទីរខេត្តពាក់ព័ន្ធ អាជ្ញាធរស្រុក និងមន្ត្រីឃុំ- សង្កាត់ សមាជិករៀបចំដីធ្លី និងសុរិយោដី ក៏ដូចជាសមាជិកក្រុមប្រឹក្សាឃុំ- សង្កាត់ក្នុងខេត្តចំនួន១៣ ។<br>• ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ស្រុក- ខ័ណ្ឌ ចំនួន១៥ ។<br>• រៀបចំផែនការប្រើប្រាស់ដីក្រុង ក្នុងខ័ណ្ឌចំនួន១៣ ។<br>• ផែនការប្រើប្រាស់ដីធ្លីតាមរយៈការចូលរួម ក្នុងក្របខ័ណ្ឌនៃគំរោងគ្រប់គ្រងធនធានធម្មជាតិនៅតាមសហគមន៍ និងកម្មវិធីសីលាក្នុងភូមិចំនួន២៨៤ នៃឃុំចំនួន ៤៥ រួមទាំងផែនទីប្រើប្រាស់ដីធ្លីបឋមក្នុងឃុំចំនួន៣៤៥ ។ |
| | ៤. ពង្រីកវិសាលភាពនៃការចុះបញ្ជីដីធ្លី :<br>ក. ផ្តល់ប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីឱ្យបាន៣០០.០០០ក្នុងឆ្នាំ២០០៦<br>ខ. បង្កើនករណីដោះស្រាយជំលោះដីធ្លីដោយគណៈកម្មការសុរិយោដី : ត្រូវដោះស្រាយឱ្យចប់៤៥០ករណីក្នុង៨០០ករណីក្នុងឆ្នាំ២០០៦ | • ក្នុងឆ្នាំ ២០០៦ បានផ្តល់ប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីចំនួន ៣១៨.២៥៥ ។<br>• ក្នុងឆ្នាំ២០០៦ បានដោះស្រាយជំលោះដីធ្លីចំនួន ២៩១ ករណី ។ |

| គោលដៅ | សកម្មភាពចាំបាច់ | លទ្ធផល |
|---|---|---|
| | គ. កែប្រែរចនាសម្ព័ន្ធនៃតម្លៃសម្រាប់ផ្តល់សេវាចុះបញ្ជីដីធ្លី ដោយធ្វើការផ្សព្វផ្សាយអំពីតំលៃ និងពន្ធប្រថាប់ត្រាក្នុងការចុះបញ្ជីដីធ្លី | • ឯកសារណែនាំស្តីពីការគ្រប់គ្រងថ្លៃចុះបញ្ជីដីធ្លី ។<br>• សេចក្តីសំរេចលេខ៥១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការផ្តល់សេវាចុះបញ្ជីដីធ្លី ។<br>• សេចក្តីសំរេចលេខ៤២ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៦ ស្តីពីការបង្កើតយន្តការទទួលពាក្យបណ្តឹង និងដោះស្រាយជំលោះដីធ្លី សម្រាប់គំរោងស្តីពីរដ្ឋបាល និងការគ្រប់គ្រងដីធ្លី LMAP<br>• សេចក្តីសំរេចលេខ៤៣ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីក្រមសីលធម៌សម្រាប់មន្ត្រីបំរើការក្នុងគំរោង LMAP ។ |
| | ឃ. រៀបចំផែនទីស្តីពីដីរដ្ឋក្នុងស្រុក៥ និងបានផ្សព្វផ្សាយលទ្ធផលជាសាធារណៈ | • ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងជំហានទី៤ (នៃជំហានទាំង ៥) បានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ស្រុក- ខ័ណ្ឌ ក្នុងស្រុកចំនួន ៥ ។ |
| ១២- បង្កើតបរិយាកាសអំណោយផលសម្រាប់កិច្ចអភិវឌ្ឍន៍វិស័យឯកជន | ១. បញ្ចប់សេចក្តីព្រាងច្បាប់សម្បទានសម្រាប់ស្នើជូនរដ្ឋសភា ។ គ្រប់គំរោងថ្មីស្តីពីការចូលរួមរបស់វិស័យឯកជនក្នុងហេដ្ឋារចនាសម្ព័ន្ធ ត្រូវអនុវត្តតាមគោលការណ៍តម្លាភាពនិងគណនេយ្យភាព ដូចមានក្នុងសេចក្តីព្រាងច្បាប់ | • សេចក្តីព្រាងច្បាប់សម្បទានបានផ្ញើជូនរដ្ឋសភា ។ |
| | ២. ពង្រឹងការសម្រួលពាណិជ្ជកម្ម :<br>ក. អនុមតិ និងប្រើប្រាស់ឯកសាររដ្ឋបាលតែមួយ តាមប្រព័ន្ធ Asycuda<br>ខ. អនុមតិ និងផ្សព្វផ្សាយជាសាធារណៈស្តីពីកិច្ចព្រមព្រៀងរវាងស្ថាប័នពាក់ព័ន្ធនីងនីតិវិធី និងគោលការណ៍ស្តីពីការត្រួតពិនិត្យ និងការអនុញ្ញាតការនាំចេញ-នាំចូលទំនិញ<br>គ. អនុវត្តសាកល្បងនូវច្រកចេញចូលតែមួយ ដើម្បីសម្រួលពាណិជ្ជកម្មនៅកំពង់ផែក្រុងព្រះសីហនុ<br>ឃ. រៀបចំ និងអនុមតិអនុក្រឹត្យស្តីពីការសម្រួលពាណិជ្ជកម្ម តាមរយៈអភិក្រមគ្រប់គ្រងហានិភ័យក្នុងការត្រួតពិនិត្យ និងជំរះបញ្ជីការនាំចេញនិងនាំចូលទំនិញ ដោយបញ្ជាក់ពីតួនាទីឈានមុខរបស់ទីចាត់ការគយនិងរដ្ឋាករ ក្នុងការត្រួតពិនិត្យគ្រប់ប្រភេទ (ត្រួតពិនិត្យលើឯកសារត្រួតពិនិត្យរូបវ័ន្ត និងដោយឧបករណ៍អេឡិចត្រូនិច) | • ឯកសាររដ្ឋបាលតែមួយ និងកំណត់ហេតុ ត្រូវបានអនុមតិដោយគណៈកម្មការអន្តរក្រសួង ។<br>• បន្ទាប់ពីបានជ្រើសរើសក្រុមហ៊ុនផ្តល់ប្រឹក្សាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រួចមក កិច្ចព្រមព្រៀងអន្តរភ្នាក់ងារ និងនីតិវិធីប្រតិបត្តិស្តង់ដារ កំពុងត្រូវបានរៀបចំ ។<br>• ភាពយឺតយ៉ាវដោយសារជំហរខុសគ្នារវាងរាជរដ្ឋាភិបាល និងធនាគារពិភពលោក<br>• អនុក្រឹត្យលេខ ២១ អនក្រ.អក ចុះថ្ងៃទី០១ ខែមិនា ឆ្នាំ២០០៦ |
| | ៣. រៀបចំ និងអនុវត្តនីតិវិធី និងតម្រូវការឯកសារនានា បញ្ជាក់ពីនីតិវិធីក្នុងការកែប្រែលក្ខន្តិកៈក្រុមហ៊ុន បញ្ជាក់ពីតម្រូវការអប្បបរមាសម្រាប់ក្រុមហ៊ុនសាជីវកម្ម ដោយផ្អែកលើច្បាប់ស្តីពីក្រុមហ៊ុនពាណិជ្ជកម្ម | • សេចក្តីប្រកាសលេខ ២៧០៦ MOC/LAD ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៦ ដែលឆ្លើយតបនឹងការអនុវត្តន៍ផែនការនៃកំណែទំរង់ក្រុមហ៊ុនសាជីវកម្ម និងវិមជ្ឈការនៃការចុះបញ្ជីពាណិជ្ជកម្ម ។<br>• ប្រកាសលេខ ១២០ MOC/SM2006 ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៦ ដែលបញ្ជាក់ពីនីតិវិធីនៃការធ្វើ |

| គោលដៅ | សកម្មភាពចាំបាច់ | លទ្ធផល |
|---|---|---|
| | បញ្ជាក់ពីនីតិវិធីស្តីពីការប្រកាសប្រចាំឆ្នាំ និងនីតិវិធីសម្រាប់ការធ្វើវិមជ្ឈការនៃការចុះបញ្ជីពាណិជ្ជកម្ម ព្រមទាំងសម្រួលដំណើរនៃការផ្តល់អាជ្ញាប័ណ្ណដល់សហគ្រាសធុនតូច និងមធ្យម | វិសោធនកម្មមាត្រានៃច្បាប់សាជីវកម្ម ។<br>• សេចក្តីប្រកាសលេខ ១៨១៥ MOC/SM2006 ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៦ ដែលបញ្ជាក់ពីតម្រូវការសំខាន់ៗចំនួន១៣ សម្រាប់មាត្រានៃច្បាប់សាជីវកម្ម ។<br>• ប្រកាសលេខ ១៤៩ MOC/SM2006 ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៦ ដែលបញ្ជាក់ពីតម្រូវការ និងនីតិវិធីសម្រាប់ប្រកាសប្រចាំឆ្នាំ ។ |
| | ៤. ពង្រឹងនិងសម្រួលរាល់តម្រូវការស្តីពីការផ្តល់អាជ្ញាប័ណ្ណ ដល់សហគ្រាសធុនតូច និងមធ្យម | • អនុគណៈកម្មការសហគ្រាសធុនតូច និងមធ្យម បានអនុមតិផែនការសម្រាប់បង្កើតយន្តការត្រួតពិនិត្យការផ្តល់អាជ្ញាប័ណ្ណ នៅខែកក្កដា ។<br>• រាជរដ្ឋាភិបាលបានអនុម័តឯកសាររួបវន្ត សម្រាប់អនុវត្តការត្រួតពិនិត្យការផ្តល់អាជ្ញាប័ណ្ណ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៦<br>• អនុគណៈកម្មការសហគ្រាសធុនតូច និងមធ្យម ក៏បានអនុមតិផងដែរ នូវយន្តការពាំនឹងសម្រាប់ធុរៈកិច្ច ដើម្បីរៀបចំសំណុំបែបបទពីបញ្ហាប្រឈមនានា តបទៅនឹងលទ្ធផលជំលោះនៃការផ្តល់អាជ្ញាប័ណ្ណ និងការត្រួតពិនិត្យ ព្រមទាំងមានការត្រួតពិនិត្យលើការសំរេចចិត្ត ។ |
| | ៥. អនុមតិ និងអនុវត្តឱ្យពេញលេញនូវយន្តការច្រកចេញ- ចូលតែមួយ សម្រាប់តំបន់សេដ្ឋកិច្ចពិសេសឱ្យបានស្របជាមួយនឹងកំណែទម្រង់ស្តីពីការសម្រួលពាណិជ្ជកម្ម ដើម្បីកាត់បន្ថយពេលវេលា និងចំណាយក្នុងការជំរះបញ្ជីពាណិជ្ជកម្ម រួមមាន ការអនុវត្តន៍ប្រព័ន្ធឯកសាររដ្ឋបាលតែមួយ និងការគ្រប់គ្រងហានិភ័យ ក្នុងការត្រួតពិនិត្យការនាំចូល- នាំចេញទំនិញ | • បានអនុមតិយន្តការច្រកចេញ- ចូលតែមួយ សម្រាប់អនុវត្តនៅតំបន់សេដ្ឋកិច្ចពិសេស ។ |